**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royalede Droitet des SciencesEconomiques

ROYAL UNIVERSITY OF LAW AND ECONOMICS

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីរឿងក្តីព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី-ខេត្ត

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៧ ខែមេសា ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


រៀបរៀងឡើងដោយ

និស្សិតឈ្មោះ: លោក **ជា ចិត្រា**

កញ្ញា **ខន ស្រីម៉ី**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ហោ សុភ័ណ្ឌ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ពួកយើងខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះសាស្ត្រាចារ្យ ហោ សុភ័ណ្ឌ ដែលបានបង្រៀននៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានជម្រុញនិងណែនាំជាគន្លឹះដល់ក្រុមយើងខ្ញុំឲ្យមានការសិក្សាស្រាវជ្រាវឯកសារឲ្យយកមកចងក្រងឲ្យលេចចេញជាសៀវភៅនេះឡើង។ ក្រុមនិស្សិតយើងខ្ញុំសូមអរគុណខ្លាំងណាស់ចំពោះលោកគ្រូ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការអាននិងគាំទ្រការស្រាវជ្រាវមួយនេះ។ ការអានច្រើនបង្កើនគំនិតបណ្តុះប្រាជ្ញាធ្វើឲ្យយើងមានការទុកចិត្តលើខ្លួនឯងក្រុមយើងខ្ញុំគិតថាការស្រាវជ្រាវមួយនេះក៏ជាគន្លឹះមួយចង្អុលទៅរកភាពជោគជ័យមួយកម្រិតផងដែរ។ យ៉ាងណាមិញក៏សុំអរគុណផងដែរនូវឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរងប្រធានការិយាល័យ បណ្ឌិត សាស្ត្រាចារ្យ ព្រមទាំងបុគ្គលិកទាំងអស់ ដែលបានបម្រើការនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានយកចិត្តទុកដាក់សិស្សនិស្សិតគ្រប់រូបដែលបានរៀននៅទីនេះអោយមានចំណេះដឹងទូលំទូលាយ ជាកន្លែងថ្នាលសាបព្រោះចំណេះដឹង បង្រៀននៅវិជ្ជាជីវៈយ៉ាងច្បាស់លាស់ ពិតប្រាកដល់ពួកយើងខ្ញុំ ។

ជាពិសេសយើងខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកមានគុណទាំងពីរដែលបានបង្កើតចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចយ៉ាងលំបាករហូតដល់ធំដឹងក្តីថែមទាំងផ្តត់ផ្តងតម្រង់ផ្លូវកូនៗអោយបន្តការសិក្សារហូតដល់ចប់ថ្នាក់បរិញ្ញាបត្រនេះទោះអ្នកមានគុណមិនមានលទ្ធភាព សម្រាប់ផ្គងផ្គង់គ្រប់យ៉ាងរាល់ការចំណាយលើការសិក្សានិងការរស់នៅក៏អ្នកមានគុណមិនដែលបង្អាក់ដំណើរឬហាមឃាតកូនមិនអោយធ្វើការសិក្សាដែរថែមទាំងបានជម្រុញទឹកចិត្តអោយពួកកូនប្រឹងប្រែងបន្តអោយអស់ពីលទ្ធភាពដើម្បីទទួលបានភាពជោគជ័យព្រមជាមួយចំណេះដឹងទៀតផង។ កូនៗសូមថ្លែងអំណរគុណ នឹកគុណ និងដឹងគុណលោកឪពុកអ្នកម្តាយយ៉ាងក្រៃលែងសូមអោយអ្នកមានគុណទាំងពីរសុខភាពល្អ និងសំណាងល្អ ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំសូមអភ័យទោសចំពោះកំហុសឆ្គងដោយអចេតនាក្នុងការប្រើប្រាស់ពាក្យពេចន៍ក៏ដូចជាចំណុចណាដែលខ្វះខាតក្រុមយើងខ្ញុំនឹងចាំទទួលយកមតិរិះគន់ព្រមទាំងកែតម្រូវត្រង់ចំណុចណាដែលមិនសមហេតុសមផលពីលោកគ្រូអ្នកគ្រូមិត្តនិស្សិតដែលអង្គុយនៅទីនេះ។យើងខ្ញុំសូមអរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះសមាជិកក្រុមទាំងអស់គ្នាដែលបានខិតខំប្រឹងប្រែងក្នុងការខិតខំជួយស្រាវជ្រាវកិច្ចការនិងរៀបរៀងឡើងដោយមានសាមគ្គីភាព។

សមាជិកក្រុមខ្ញុំមាន៖

១. ជា ចិត្រា

២. ខន ស្រីម៉ី

# អារម្ភកថា

កិច្ចការសារណាមួយនេះកើតឡើងចេញពីការប្រមូលផ្តុំនូវឯកសារអត្ថបទស្រាវជ្រាវដែលជាសមិទ្ធផលនៃការខិតខំប្រឹងប្រែងរបស់ក្រុមយើងខ្ញុំដែលបានរៀបរៀងឡើងក្នុងគោលបំណងជាឯកសារជំនួយបន្ថែមសម្រាប់និស្សិតសិស្សប្អូនជំនាន់ក្រោយដែលបានរៀនសូត្របន្តមានការយល់ដឹងបន្ថែម។ជាច្រើនសប្តាហ៍កន្លងមកដែលក្រុមយើងខ្ញុំបានខិតខំប្រឹងប្រែងស្រាវជ្រាវឯកសារមួយទាក់ទងនឹង នីតិវិធីរឿងក្តីព្រហ្មទណ្ឌនៃសាលាដំបូងរាជធានីខេត្តយកមកចងក្រងដើម្បីយកមកបង្ហាញជូនដល់ លោក លោកស្រី អ្នកនាងកញ្ញា និងមិត្តនិស្សិតក៏ដូចជាអ្នកសិក្សាអ្នកស្តាប់អ្នកអានអ្នកស្រាវជ្រាវទាំងអស់ដើម្បីចែករំលែកចំណេះដឹង ដែលយើងខ្ញុំបានស្រាវជ្រាវនេះចែកជូនអ្នកទាំងអស់គ្នាបានដឹង ក៏ដូចជាបំពេញបន្ថែមនូវចំណេះដឹងនូវចន្លោះដែលខ្វះខាតកន្លងមក ។ ក្រុមយើងខ្ញុំពិតជាមានមោទនភាពខ្លាំងណាស់ដែលបានសិក្សានូវមុខជំនាញនីតិនីតិសាស្ត្រជាពិសេសគឺមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌដែលជាមុខវិជ្ជាដ៏សំខាន់ណាស់ដែរនៅក្នុងការសិក្សាជំនាញនីតិសាស្ត្រ ពីព្រោះវាគឺជាមុខវិជ្ជាមួយដែលសិក្សាអំពីនីតិវិធីនៃការការអនុវត្តរឿងក្តីដែលមានលក្ខណៈ ជារឿងព្រហ្មទណ្ឌដឹងពីនីតិវិធីអនុវត្តរឿងក្តីតាំងពីការស៊ើបអង្កេតរហូតដល់នីតិវិធីចុងក្រោយគឺការជំនុំជម្រះព្រមទាំងដឹងពីការធ្វើបណ្តឹងតវ៉ាក្នុងរឿងក្តីដែលយើងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់តុលាការផងដែរ។ ក្រុមយើងខ្ញុំមានការជឿជាក់ថាកិច្ចការសារណាមួយនេះប្រាកដជាមានកំហុសខ្វះខាត និងកំហុសឆ្គងទាំងពាក្យពេចន៍និងអត្ថន័យ និងអក្ខរសជាមិនខានឡើយ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំពិតជាមានសោមនស្សរីករាយ និងស្វាគមន៍នូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោកគ្រូអ្នកគ្រូ និងមិត្តអ្នកស្រាវជ្រាវអ្នកអានទាំងអស់ដើម្បីកែតម្រូវកិច្ចការសារណាមួយនេះប្រកបដោយលក្ខណៈគ្រប់គ្រាន់ទៅឡើងប្រសើរជាងនេះ។ ជាចុងក្រោយយើងខ្ញុំសូមគោរពជូនពរដល់លោកគ្រូអ្នកគ្រូ និង មិត្តនិស្សិត ដែលបានអានកិច្ចការស្រាវជ្រាវទាំងអស់ឲ្យជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្ដីផ្ដើម**........................................................................................................**១**

## ជំពូកទី១
## ដំណាក់កាលស៊ើបអង្កេត និងការចោទប្រកាន់របស់នគរបាលយុត្តិធម៌និង ព្រះរាជអាជ្ញា

**ផ្នែកទី១ អំពីនគរបាលយុត្តិធម៌** ..................................................................................**២**

**កថាខណ្ឌទី១ សមាសភាពនគរបាលយុត្តិធម៌** ...........................................................**២**

**១.មន្ត្រីនគរបាលយុត្តិធម៌**.......................................................................................**២**

**២. ភ្នាក់ងារនគរបាលយុត្តិធម៌**....................................................................................**៥**

**៣. មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត**.............................................................**៦**

**កថាខណ្ឌទី២ សមត្ថកិច្ចរបស់នគរបាលយុត្តិធម៌**.............................................................**៦**

**១. សមត្ថកិច្ចដែនដី** ...................................................................................................**៦**

**២ សមត្ថកិច្ចសម្ភារៈ** ..................................................................................................**៧**

**កថាខណ្ឌទី៣ អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត** ..............................**៧**

**១. ការស៊ើបអង្កេតករណីជាក់ស្តែង**...............................................................................**៧**

១.១ និយមន័យនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង.............................................................. ៧

១.២ ការឆែកឆេរ .............................................................................................................. ៨

១.៣ ការចាប់យកវត្ថុតាង.................................................................................................. ៩

១.៤ ការស្តាប់ចម្លើយ ........................................................................................................ ៩

១.៥ ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ......................................................... ៩

១.៦ ការចាប់ខ្លួន............................................................................................................. ៩

១.៧ ការបញ្ជូនខ្លួន ......................................................................................................... ១០

**២. ការស៊ើបអង្កេតបឋម ឬករណីមិនជាក់ស្តែង**.............................................................**១១**

១.អត្ថន័យមិនជាក់ស្តែង.................................................................................................១១

២.ការបើកការស៊ើបអង្កេតបឋម........................................................................................១១

៣.មោឃភាពនៃការមិនគោរពវិធាន....................................................................................១១

៤.ការឆែកឆេរ.............................................................................................................១១

៥.ការឃាត់ខ្លួនជនជាប់សង្ស័យ........................................................................................................១២
៦.កំណត់ហេតុក្នុងការស្តាប់ចម្លើយ.................................................................................................១២
**ផ្នែកទី២ អំពីស្ថាប័នអយ្យការ .................................................................................................១២**
**កថាខណ្ឌទី១ និយមន័យ និងការរៀបចំអង្គការអយ្យការ ........................................................................១២**
**១. និយមន័យនៃព្រះរាជអាជ្ញា ........................................................................................................១២**
**២. ការជ្រើសរើសព្រះរាជអាជ្ញា.......................................................................................................... ១៣**
**កថាខណ្ឌទី២ សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា ................................................................................... ១៣**
**១ . ការចោទប្រកាន់ ...................................................................................................................... ១៣**
**២. ការតម្កល់រឿងទុកឥតចាត់ ..........................................................................................................១៤**
**៣. សេចក្តីសម្រេចក្នុងការចោទប្រកាន់...................................................................................................១៥**
៣.១ បើកការស៊ើបសួរ (ព្រះរាជអាជ្ញាចេញដីការសន្និដ្ឋានអោយស៊ើបសួរ)...................................... ១៦
៣.២ បញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់.........................................................................................................១៧
៣.៣ នីតិវិធីនៃការបង្ហាញខ្លួនភ្លាម...........................................................................................................១៧

## ជំពូកទី២ ការស៊ើបសួរ

**ផ្នែកទី១ ដំណាក់កាលចៅក្រមស៊ើបសួរ.........................................................................................១៨**
**កថាខណ្ឌទី១ ការបើកការស៊ើបសួរ ...............................................................................................១៨**
**១.ការស៊ើបសួរដាក់បន្ទុក ................................................................................................................១៩**
**២.ការស៊ើបសួរដោះបន្ទុក ...............................................................................................................១៩**
**៣.ការស៊ើបសួរជំនួស.......................................................................................................................១៩**
**កថាខណ្ឌទីពីរ វិធានការនិរន្តរាយ .................................................................................................២០**
**១.ដីកាបង្គាប់ឲ្យចូលខ្លួន ...............................................................................................................២០**
**២. ដីកាបង្គាប់ឲ្យនាំខ្លួន....................................................................................................................២១**
**៣.ដីកាបង្គាប់ឲ្យចាប់ខ្លួន ..................................................................................................................២១**
**៤. ដីកាបង្គាប់ឲ្យឃុំខ្លួន.....................................................................................................................២២**
**៥. ដីកាសម្រេចឲ្យជនជាប់ចោទស្ថិតក្រោមការពិនិត្យរបស់តុលាការ ................................................ ២៣**
**កថាខណ្ឌទី៣ ព្រំដែននៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ...........................................................២៥**
**១. តាមការស្នើរបស់ព្រះរាជអាជ្ញា.......................................................................................................២៥**
**២.តាមការស្នើរបស់ជនត្រូវចោទ ឬ មេធាវីការពារជនត្រូវចោទ ............................................................២៥**
**៣.ការស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណី ឬ មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី..........២៦**

**ផ្នែកទី២ ការបិទការស៊ើបសួរ និងដីការដំណោះស្រាយ ..................................................២៦**
**កថាខណ្ឌទី១ ការបិទការស៊ើបសួរ..................................................២៦**
**កថាខណ្ឌទី២ ដីកាដំណោះស្រាយ..................................................២៧**
**១. ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ..................................................២៧**
**២.ដីកាលើកលែងចោទប្រកាន់ ..................................................២៧**


## ជំពូកទី៣ដំណាក់កាលកាលជំនុំជម្រះក្តី

**ផ្នែកទី១ ដំណាក់កាលសវនាការ..................................................២៩**
**១. សមត្ថកិច្ចរបស់តុលាការ..................................................២៩**
**២. នីតិវិធីពេលសវនាការ..................................................៣០**
២.១ សមាសភាពនាពេលសវនាការ..................................................៣០
២.២ នីតិវិធិនិងដំណាក់កាលនៃការជំនុំជម្រះ ..................................................៣០
២.៣ ការកំណត់ពេលបើកសវនាការ..................................................៣១
២.៤ ការចូលរួមនីតិវិធីសវនាការ..................................................៣១
**៣. ការពិភាក្សាដេញដោល ..................................................៣២**
**៤. ការប្រកាសសាលក្រម ..................................................៣៣**
៤.១ សាលក្រមចាត់របៀប..................................................៣៤
៤.២ សាលក្រមលើអង្គសេចក្តី..................................................៣៤
**ផ្នែកទី២ បណ្តឹងទាស់ ..................................................៣៥**
**១. ទម្រង់នៃបណ្តឹងទាស់..................................................៣៥**
**២. រយៈពេលនៃការប្តឹងទាស់..................................................៣៥**
**៣. អានុភាពនៃបណ្តឹងទាស់..................................................៣៥**
៣.១ បណ្តឹងទាស់ដោយពិរុទ្ធជន..................................................៣៥
៣.២ បណ្តឹងទាស់ដោយដើមបណ្តឹងរដ្ឋប្បវេណី ..................................................៣៦
**៤. សាលក្រមសម្រេចលើបណ្តឹងទាស់..................................................៣៦**
**សេចក្តីសន្និដ្ឋាន..................................................៣៨**
**អនុសាសន៍..................................................៤០**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

នៅក្នុងនីតិព្រហ្មទណ្ឌដែលមានរឿងរ៉ាវជាច្រើនដែលយើងត្រូវតែដោះស្រាយ។ ដើម្បីដើរឲ្យទាន់សភាពការណ៍ទាំងនោះក្រសួងយុត្តិធម៌ ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងដើម្បីសហការណ៍ជាមួយអង្គការនានាជាពិសេសជាមួយបារាំង និងជប៉ុនដែលជាដៃគូសហការក្នុងការរៀបចំបទដ្ឋានគតិយុត្តិឲ្យមានរបៀបរបបនិងដើរទាន់សភាពការណ៍នៃរឿងរ៉ាវទាំងនោះ។យ៉ាងណាមិញនៅក្នុងសៀវភៅសារណាដែលសរសេរអំពីដំណាក់កាលទាំងបួននៃរឿងក្តីព្រហ្មទណ្ឌស្ថិតក្នុងទីនេះយើងខ្ញុំជានិស្សិតច្បាប់បានខិតខំស្រាវជ្រាវយកមកចងក្រងពាក់ព័ន្ធនឹងនីតិវិធីជាពិសេសពាក់ព័ន្ធ នឹងមុខងារតួនាទីរបស់បុគ្គលសំខាន់ៗមួយចំនួនក្នុងរឿងក្តីព្រហ្មទណ្ឌមកលាតត្រដាងបង្ហាញដល់សាធារណជនដើម្បីឲ្យយល់កាន់តែច្បាស់និងស៊ីជម្រៅនិងកាន់តែលំអិតពាក់ព័ន្ធនិងវិស័យច្បាប់ជាពិសេសទាក់ទងទៅនឹងរឿងក្តីព្រហ្មទណ្ឌ។ ដើម្បីឲ្យដឹងថាតើមូលហេតុអ្វីខ្លះដែលនាំឲ្យមានបទល្មើស និងថាតើមានវិធីបែបណាដើម្បីដោះស្រាយបទល្មើសនិងបង្ការបទល្មើសទាំងនោះកុំឲ្យកើតមាន? គោលបំណងដែលធ្វើឲ្យក្រុមយើងខ្ញុំសម្រេចចិត្តលើកយកប្រធានបទនេះមកបកស្រាយគឺ ដើម្បីផ្តោតទៅលើការស្វែងយល់ពីមូលហេតុនៃរឿងរ៉ាវ ទ្រឹស្តីច្បាប់ និងកិច្ចនៃនីតិវិធីព្រហ្មទណ្ឌ។ ហើយក៏បានបង្ហាញអំពីស្ថាប័ន ភាគី តួអង្គសំខាន់ៗ ក្នុងដំណើការនៃរឿងក្តីព្រហ្មទណ្ឌ។ជាងនេះទៅទៀត នៅក្នុងដំណាក់កាលនគរបាលយុត្តិធម៌ គឺបានរៀបរាប់ពីដំណើរការស៊ើបអង្កេតទាំងករណីជាក់ស្តែង និងករណីមិនជាក់ស្តែងផងដែរ ហើយមានការបកស្រាយយ៉ាងក្បោះក្បាយអំពីដំណាក់កាលទាំងនោះ ដើម្បីឲ្យដឹងអំពីភាពខុសគ្នារវាងករណីទាំងនោះ។ ក្រៅពីតួនាទី ភារកិច្ច មុខងារ និងកិច្ចការសំខាន់ៗ របស់នគរបាលយុត្តិធម៌ និងអង្គការអយ្យការ ជាពិសេស ស្វែងរកអំពីបញ្ហាប្រឈម និងដំណោះស្រាយជាដើម។ ហើយចំពោះដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ គឺបានរៀបរាប់អំពីដំណើរនៃការស៊ើបសួរ ការចោទប្រកាន់ ការសម្រេចសេចក្តី និងកិច្ចការដែលចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះត្រូវបំពេញទៅតាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់។

នៅក្នុងសៀវភៅសារណានេះក្រុមរបស់ខ្ញុំនឹងលើកយកមកបង្ហាញនូវចំណុចសំខាន់នៃរឿងក្តីព្រហ្មទណ្ឌដែលមានបង្ហាញចាប់ពីនគរបាលយុត្តិនិងព្រះរាជអាជ្ញាដែលយកមកបកស្រាយនៅជំពូកទី១ ចៅក្រមស៊ើបសួរជំពូកទី២ និង ស្ថាប័នជំនុំជម្រះនៅក្នុងជំពូកទី៣ ដែលមានការសរសេរបកស្រាយដូចតទៅ។

# ជំពូកទី១
# ដំណាក់កាលស៊ើបអង្កេត និង ការចោទប្រកាន់របស់នគរបាលយុត្តិធម៌ និង ព្រះរាជអាជ្ញា

# ជំពូកទី១

# ដំណាក់កាលស៊ើបអង្កេត និងការចោទប្រកាន់របស់នគរបាលយុត្តិធម៌ និង ព្រះរាជអាជ្ញា

នៅក្នុងដំណាក់កាលទាំងបួន នៃរឿងក្តីព្រហ្មទណ្ឌនៅក្នុងសាលាដំបូងរាជធានីខេត្ត ដំណាក់កាលស៊ើបអង្កេត និង ការចោទប្រកាន់នេះ ជាដំណាក់កាលដំបូងគេ ដែលនៅក្នុងជំពូកនេះយើងនឹងរៀបរាប់អំពីចំណុចសំខាន់ៗ ដែលមានដូចខាងក្រោម។

## ផ្នែកទី១ អំពីនគរបាលយុត្តិធម៌

បន្ទាប់ពីមានបទល្មើសកើតឡើងរួចហើយ ឬកំពុងកើតឡើង ឬនឹងកើតឡើងនាពេលខាងមុខ ស្ថាប័នដែលពាក់ព័ន្ធដែលជួយដោះស្រាយរឿងក្តីនេះដំបូងគេគឺ នគរបាលយុត្តិធម៌[1]។ ខាងក្រោមនេះគឺជាការរៀបរាប់អំពីសមាសភាពរបស់នគរបាលយុត្តិធម៌ដែលមានការបែងចែកជាបីគឺ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត។

### កថាខណ្ឌទី១ សមាសភាពនគរបាលយុត្តិធម៌

#### ១.មន្ត្រីនគរបាលយុត្តិធម៌

បើតាមមាត្រា៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា នគរបាលយុត្តិធម៌គឺជាជំនួយរបស់អំណាចតុលាការ ហើយនគរបាលយុត្តធម៌នេះមានភារកិច្ចធ្វើការត្រួតពិនិត្យបទល្មើសឧក្រិដ្ឋ បទមជ្ឈិម និងបទលហុកំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាងផងដែរ[2]។

ចំពោះការទទួលបាននូវគុណសម្បត្តិរបស់មន្ត្រីនគរបាលយុត្តិធម៌នគរបាលយុត្តិធម៌ ចែកចេញជាបីចំណុចដែលមានដូចជា[3]៖

- ការទទួលបានតាមរយៈការប្រឡងប្រជែងមានន័យថា គឺជាការប្រឡងយកសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ជាមុនសិន ទើបអាចក្លាយទៅជាមន្ត្រីនគរបាលយុត្តិធម៌បាន។ ដើម្បីប្រឡងយកសញ្ញាបាលយុត្តិធម៌ត្រូវបំពេញលក្ខខណ្ឌដូចដែលមានចែងនៅក្នុងមាត្រា៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-មន្ត្រីនគរបាលជាតិមានឋានន្តរសក្តិចាប់ពីអនុសនីយ៍ត្រីឡើងទៅ ដែលបានបម្រើការងារយ៉ាងតិចពីរឆ្នាំ នៅក្នុងនគរបាលជាតិរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

-នាយទាហាននៃកងរាជអាវុធហត្ថ ដែលបានបម្រើការងារយ៉ាងតិចពីរឆ្នាំ ក្នុងកងរាជអាវុធហត្ថរួច

[1] ដកស្រង់ចេញពីសៀវភៅនគរបាលយុត្តិធម៌របស់សាស្ត្រាចារ្យ កៅ សីហា

[2] មាត្រា៥៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[3] មាត្រា៦០នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

ទាំងនេះនៅពេលដែលពួកគាត់ប្រឡងជាប់សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌រួចហើយ ពេលនោះពួកគាត់ នឹងក្លាយទៅជាមន្ត្រីនគរបាលយុត្តិធម៌ហើយ។ ហើយដើម្បីប្រឡងយកសញ្ញាប័ត្រត្រូវបំពេញនូវវិញ្ញាសាប្រឡងដូចជា មុខវិជ្ជានីតិព្រហ្មទណ្ឌទូទៅ នីតិវិធីព្រហ្មទណ្ឌ និងករណីយកិច្ចសាស្ត្រដូចដែលមានចែងនៅក្នុងក្រមសីលធម៌ដែលគាត់តែងឡើងដោយអង្គការសហប្រជាជាតិ[4]។

សម្រាប់គណៈមេប្រយោគនៃការប្រឡងវិញ ត្រូវស្ថិតនៅក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬក៏ចៅក្រមអយ្យការអមតុលាការកំពូលដែលទទួលនូវមុខងារនេះ។ សមាសភាពនៃគណៈប្រយោគមានដូចជា ចៅក្រមស៊ើបសួរមួយរូបដែលតែងតាំងដោយប្រធានតុលាការកំពូល ចៅក្រមអយ្យការមួយរូបតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល និងតំណាងពីររូបមកពីក្រសួងមហាផ្ទៃ ឬក្រសួងការពារជាតិទាំងនេះគឺអាស្រ័យទៅតាមការប្រលងរបស់ខាងមន្ត្រីនគរបាលជាតិឬក៏ខាងយោធិននៃកងរាជអាវុធហត្ថ[5]។ នៅពេលដែលពួកគាត់ប្រឡងជាប់ទទួលបានសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌រួចហើយសញ្ញាប័ត្រនេះនឹងត្រូវបានសញ្ញេ និងមានបោះត្រារួមផងដែរដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធមានន័យថា បើជាមន្ត្រីនគរបាលយុត្តិធម៌ដែលចេញមកពីខាងនគរបាលជាតិ គឺចុះហត្ថលេខា និងបោះត្រាដោយរដ្ឋមន្ត្រីករសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តែបើសិនជាមកពីខាងកងរាជអាវុធហត្ថ គឺចុះហត្ថលេខា និងបោះត្រាដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមួយរដ្ឋមន្ត្រីក្រសួងការពារជាតិ[6]។

- ការទទួលបានតាមរយៈឋានន្តរសក្តិ និងមុខងារ

ចំពោះឋានន្តរសក្តិ និងមុខងារនេះ ត្រូវបានផ្តល់ឲ្យដោយការតែងតាំងពីសំណាក់ព្រះមហាក្សត្រ គឺ ព្រះរាជក្រឹត្យ ឬប្រមុខរាជរដ្ឋាភិបាល គឺអនុក្រឹត្យ ឬប្រកាសរបស់ប្រធានស្ថាប័ន ឬក្រសួង។ ប៉ុន្តែដោយយល់ឃើញថា មាត្រា ៦០នៃក្រមនិតិវិធីព្រហ្មទណ្ឌត្រង់វាក្យខណ្ឌទី៣ កថាខណ្ឌទីមួយដែលពាក់ព័ន្ធទៅនឹងការទទួលបាននូវ គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តធម៌តាមឋានន្តរសក្តិ និងមុខងារបានចែងយ៉ាងដូច្នេះថា មានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ចំពោះអ្នកមានឋានន្តរសក្តិ និងមុខងារដូចខាងក្រោម៖

ក. អភិបាល និងអភិបាលរងរាជធានី ខេត្តក្រុង , អភិបាល និងអភិបាលរងស្រុកខ័ណ្ឌ , និងមេឃុំ ចៅសង្កាត់។

ខ. ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ និងប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាន

[4] មាត្រា ៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[5] មាត្រា ៦២នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[6] សៀវភៅ នគរបាលយុត្តិធម៌របស់សាស្ត្រាចារ្យ កៅ សីហា

នគរបាលជាតិ។

គ. ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឪវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តលនៃសណ្តាប់ធ្នាប់សាធារណៈ។

ឃ.ប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន អនុប្រធានផ្នែកនេះ៖

- នាយកដ្ឋាននគរបាលព្រំដែន
- មន្ទីរប្រឆាំងគ្រឿងញៀន
- នាយកដ្ឋាននគរបាលទេសចរណ៍
- ស្នងការពិសេសការពារបេតិកភ័ណ្ឌ

ង.ស្នងការ និង ស្នងការរងនគរបាលខេត្តក្រុង

ច.ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្តក្រុងដែលមានដូចជា៖

- ការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់ និងការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល
- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន
- ការិយាល័យនគរបាលសេដ្ឋកិច្ច
- ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រវិទ្យាសាស្ត្រព្រហ្មទណ្ឌ
- ការិយាល័យប្រឆាំងគ្រឿងញៀន
- ការិយាល័យប្រឆាំភេរវកម្ម និង
- ការិយាល័យជនបរទេស។

ឆ. អធិការ អធិការង ប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលស្រុកខណ្ឌ។

ជ. ប្រធាន និងអនុប្រធាននគរបាលចរាចរណ៍ ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរណ៍ ចំពោះបទល្មើសចរាចរណ៍។ ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះនិងប្រធាននិងអនុប្រធានផ្នែកនៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ ចំពោះបទល្មើសអាវុធជាតិផ្ទុះ។ ប្រធាន និងអនុប្រធានអង្គភាព ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ និងប្រធាននិងអនុប្រធានផ្នែកនៃការិយាល័យនគរបាលទេសចរណ៍។

ឈ. ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ ចំពោះបទល្មើសព្រហ្មទណ្ឌ

ញ. មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ

ដ. មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំខេត្តក្រុង ដែលទទួលបន្ទុកកិច្ចកាព្រហ្មទណ្ឌ

ឋ. មេបញ្ជាការ និងមេបញ្ជាការរង នៃកងរាជអាវុធហត្ថប្រចាំស្រុកខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឌ. ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឍ. ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀតដែលទទួលបន្ទុកស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់[7]។

➢ ការទទួលបានដោយស្វ័យប្រវត្តិចំពោះនាយនគរបាលជាតិ ដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សា ស្ដីមន្ត្រីនគរនគរបាលយុត្តិធម៌ ដែលចេញឲ្យដោយសាលាភូមិន្ទនគរបាលនៅមុនពេលក្រមថ្មីនេះចូលជាធរមានត្រូវទទួលបានដោយស្វ័យប្រវត្តិនូវសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌។ បច្ចុប្បន្នសាលាភូមិន្ទនគរបាល បានប្ដូរឈ្មោះ ទៅជាសាលាបណ្ឌិត្យសភានគរបាលវិញហើយ[8]។ ចំពោះនាយទាហាននៃកងរាជអាវុធហត្ថ ដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាស្ដីពី មន្ត្រីប៉ូលីសតុលាការ មុនពេលក្រមនីតិវិធីព្រហ្មទណ្ឌថ្មីចូលជាធរមានត្រូវទទួលបានដោយស្វ័យប្រវត្តិនូវសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌។

នៅពេលដែលរដ្ឋមន្ត្រីក្រសួងសាមីជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានចេញប្រកាសរួមតែងតាំងគាត់មន្ត្រីនគរបាលយុត្តិធម៌ គឺត្រូវទៅធ្វើសម្បថនៅមុខសាលាឧទ្ធរណ៍
ទើបអាចទៅបំពេញការងារបាន។ ប៉ុន្តែសម្បថនេះមិនចាំបាច់ធ្វើទៀតឡើយ នាពេលដែលទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត។[9]

**២. ភ្នាក់ងារនគរបាលយុត្តិធម៌**

ពាក់ព័ន្ធនឹងការទទួលបាននូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ យើងសូមធ្វើការបែងចែកអ្នកដែលមានគុណសម្បត្តិចំនួន២ គឺ[10]៖

ក. ចំពោះនគរបាលជាតិ

បើយើងពិនិត្យទៅលើចំណុចទី១ និងទី២ ត្រង់មាត្រា៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌគឺសំដៅទៅលើនាយនគរបាល ឬក៏នាយនគរបាលរងនៃក្រសួងមហាផ្ទៃដែលមិនមែនជាមន្ត្រីនគរបាលយុត្តិធម៌។ មួយទៀតគឺភ្នាក់ងារនគរបាលជាតិផ្សេងទៀតដែលគាត់មិនមែនបំពេញការងារជាមន្ត្រីនគរបាលយុត្តិធម៌។

ខ. ចំពោះកងរាជអាវុធហត្ថ

[7] មាត្រា ៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[8] សៀវភៅនគរបាលយុត្តិធម៌របស់សាស្ត្រាចារ្យ កៅ សីហា

[9] មាត្រា ៦៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[10] សៀវភៅនគរបាលយុត្តិធម៌របស់សាស្ត្រចារ្យ កៅ សីហា

បើពិនិត្យទៅលើចំណុចទី៣ និងចំណុចទី៤ ត្រង់មាត្រា៧៦ នៃក្រមនីតិវិធីថ្មីនេះ គឺសំដៅទៅលើនាយទាហានកងរាជអាវុធហត្ថនៃក្រសួងការពារជាតិ ដែលមិនមែនជាមន្ត្រីនគរបាលយុត្តិធម៌។ មួយទៀតគឺយោធិននៃកងរាជអាវុធហត្ថផ្សេងទៀត ដែលគាត់មិនមែនបំពេញការងារជាមន្ត្រីនគរបាលយុត្តិធម៌[11]។

នៅពេលដែលក្រសួងដែលជាអាណាព្យាបាល និងក្រសួងយុត្តិធម៌បានចេញសេចក្តីប្រកាសរួមតែងតាំងរួច ភ្នាក់ងាននគរបាលយុត្តិធម៌ មិនអាចទៅបំពេញមុខងារបានភ្លាមនោះទេ គឺគាត់ត្រូវឆ្លងដមណាក់កាលមួយផ្សេងទៀត គឺការធ្វើសម្បថ ដែលសម្បថនេះគឺធ្វើនៅមុខសាលាដំបូង មិនមែនមុខសាលាឧទ្ធរណ៍ដូចមន្ត្រីនគរបាលយុត្តិធម៌ឡើយ[12]។

### ៣. មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

យោងតាមប្រសាសន៍របស់ឯកឧត្តម ហ៊ឺ សោភាបានឲ្យដឹងថាការទទួលបាននូវនីតិសម្បទាតាមរយៈច្បាប់ដោយឡែកមានចំនួនច្រើនណាស់ដូចជាមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ច្បាប់ស្តីពីទេសចរណ៍ តាមរយៈច្បាប់ស្តីពីព្រៃឈើជាដើម។

បន្ទាប់ពីមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះ ទទួលបាននូវនីតិសម្បទារួចហើយ ពួកគាត់ត្រូវទទួលបានការតែងតាំងជាមុនសិន ដែលការប្រកាសតែងតាំងនេះគឺត្រូវចេញដោយប្រកាសរួម រវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមួយនឹងរដ្ឋមន្ត្រីពាក់ព័ន្ធ។បន្ទាប់ពីមានការតែងតាំងរួចហើយគាត់ត្រូវទៅធ្វើសម្បថមុខសាលាដំបូងរាជធានី ខេត្ត។ រីឯរូបមន្តនៃសម្បថត្រូវត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## កថាខណ្ឌទី២ សមត្ថកិច្ចរបស់នគរបាលយុត្តិធម៌

ចំពោះសមត្ថកិច្ចរបស់នគរបាលយុត្តិធម៌ត្រូវបានបែងចែកជាពីរប្រភេទគឺ

### ១. សមត្ថកិច្ចដែនដី

មន្ត្រីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីអង្គភាពដែលខ្លួនត្រូវបានចាត់តាំងឲ្យទៅបម្រើការងារ។ ការកំណត់ពីមណ្ឌលរដ្ឋបាលដែលជាដែនដីសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ មានបញ្ជាក់នៅក្នុងសេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌នោះ។ ហេតុនេះមន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានចាត់តាំងឲ្យទៅបម្រើការងារនៅស្រុកណាមួយនៃខេត្តណាមួយ មានសមត្ថកិច្ចដែនដីត្រឹមនោះប៉ុណ្ណោះ។ ហើយមានករណីលើកលែងមួយចំនួនគឺ នៅរាជធានីភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌ គឺមានវិសាលភាពសមត្ថកិច្ចនៃរាជធានីទាំងមូល។ ការអនុញ្ញាតឲ្យប្រតិបត្តិការលើដែនដីជាតិទាំងមូល ដោយព្រះរាជអាជ្ញាជាលាយល័ក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ក្នុងករណីបទល្មើសជាក់ស្តែង ឬក៏ការអនុញ្ញាតឲ្យបំពេញប្រតិបត្តិការនៅលើវិសាល

[11] មាត្រា ៧៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[12] មាត្រា ៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ភាពនៃដែនដីទាំងមូលដោយចៅក្រមស៊ើបសួរ នៅក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួស។ ក្នុងករណីដែលមានករពន្លាតសមត្ថកិច្ច មន្ត្រីនគរបាលយុត្តិធម៌ ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ច។ ចៅក្រមត្រូវជូនពត៌មានតាមតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដីនោះ[13]។

**២ សមត្ថកិច្ចសម្ភារៈ**

តាមក្រមនីតិវិធីព្រហ្មទណ្ឌ កងរាជអាវុធហត្ថក៏ជាមន្ត្រីនគរបាលយុត្តិធម៌ដែរ។ ព្រោះហេតុនេះហើយកងរាជអាវុធហត្ថ អាចបំពេញមុខងារជានគរបាលយុត្តិធម៌នៅក្នុងបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ។ ប៉ុន្តែចំពោះបទល្មើសយោធា មានតែកងរាជងាវុធហត្ថទេ ដែលមានគុណសម្បត្តិចាមន្ត្រីនគរបាលយុត្តិធម៌ យោងតាមមាត្រា ៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[14]។

ក្រៅពីនេះរដ្ឋបាលព្រៃឈើ មានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ ហើយមិនអាចស៊ើបអង្កេតបទល្មើសផ្សេងទៀតបានទេ។ ចំពោះសមត្ថកិច្ចសម្ភារៈនេះ យើងអាចហៅបានថាជាសមត្ថកិច្ចតាមសាច់រឿងក៏បានដែរ។

## កថាខណ្ឌទី៣ អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត

តាមក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំណាច របស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមក្របខ័ណ្ឌនៃការស៊ើបអង្កេតថាតើ ជាករណីស៊ើបអង្កេតករណីជាក់ស្តែង ឬចាការស៊ើងអង្កេតបឋម។

**១. ការស៊ើបអង្កេតករណីជាក់ស្តែង**

១.១ និយមន័យនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

នៅក្នុងមាត្រា៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺ៖

ទី១ បទល្មើសដែលកំពុងប្រព្រឹត្ត។

ទី២ បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម។ ហើយក៏បានបញ្ជាកបន្ថែមថា ត្រូវចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងថា កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក។

ទី៣ ជនដែលគេសង្ស័យ ត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ ចាប់ប្រភីង

ទី៤ បុគ្គលដែលត្រូវគេរកឃើញថាមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថា បុគ្គលនោះបាប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។ [15]ហេតុនេះស្ថានភាពដែលមានដូចនៅក្នុងមាត្រា៨៦នេះ គឺជាស្ថានភាពនៃករណីបទល្មើសជាក់ស្តែង។ នៅក្នុងករណីដែល

[13] ដកស្រង់ពីសៀវភៅ នីតិវិធីព្រហ្មទណ្ឌរបស់សាស្ត្រាចារ្យ អៀង សំណាង

[14] មាត្រា ៨១នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[15] មាត្រា ៨៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ

បទល្មើសប្រព្រឹត្តនៅក្នុងស្ថានភាពណាមួយ នៃស្ថានភាពដែលមានចែងក្នុងមាត្រា៨៦នេះ គឺក្នុងករណីនោះ យើងចាត់ទុកថា ជាបទល្មើសជាក់ស្តែងហើយនគរបាលយុត្តិធម៌ គាត់អាចបើកការស៊ើបអង្កេតជាក់ស្តែងបាន។

ក៏ជាលក្ខខណ៍នៃការស៊ើបអង្កេតជាក់ស្តែងផងដែរ គឺមានចែងចែងក្នុងមាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ គឺការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ។ មាត្រានេះបានចែងថា ត្រូវចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ ទោះបីស្ថិតនៅក្រៅករណីមាត្រា៨៦ ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណា ដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែង ដែលអ្នកកាន់កាប់ទីកន្លែងនោះ សុំឲ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលនៅជិតទីកន្លែងនោះ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជាបន្ទាន់ជូនមន្ត្រីនគរបាលយុត្តិធម៌។ ឧទាហរណ៍៖ មានបុរសម្នាក់គាត់បានទៅលេងចម្ការរបស់គាត់មួយកន្លែង ដែលនៅឆ្ងាយពីភូមិស្រុករបស់គាត់ ស្រាប់តែទៅដល់គាត់ក៏ប្រទះឃើញសាកសពមួយដែលបានស្លាប់ប្រហែលពីរ បីថ្ងៃមកហើយ ភ្លាមនោះគាត់ក៏បានទៅរាយការណ៍ភ្លាមដល់មន្ត្រីនគរបាលដែលនៅជិតនោះបំផុត ។ ដូចនេះ ក្នុងករណីបែបនេះ គឺគេចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ។[16]

១.២ ការឆែកឆេរ

ការឆែកឆេរ គឺត្រូវគោរពឲ្យបានតឹងតែងបំផុត ទៅលើលក្ខខណ្ឌ និងនីតិវិធីដែលមានចែងក្នុងមាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មាត្រានេះបានបញ្ជាក់ជូនថា មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន។ តែក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌មិនចាំបាច់មានដីកាពីតុលាការទេ ប៉ុន្តែគាត់ត្រូវមានការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា ហើយការអនុញ្ញាតអាចធ្វើដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍ អក្សរ។ ដូចនេះនៅពេលដែលគាត់ទទួលការអនុញ្ញាតពីព្រះរាជអាជ្ញា គឺមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើរការឆែកឆេរបាន ដែលការឆែកឆេរត្រូវគោរពលក្ខខណ្ឌមួយចំនួនដូចជា ការឆែកឆេរត្រូវធ្វើជាទូទៅមុខអ្នកកាន់កាប់ទីកន្លែង ប៉ុន្តែប្រសិនបើគ្មានអ្នកកាន់កាប់ទីកន្លែងទេ ការឆែកឆេរត្រូវធ្វើនៅមុខសាក្សីពីររូប ដែលសាក្សីនេះត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលបានចុះដឹកនាំប្រតិបត្តិការ។ យោងតាមគោលការណ៍ដែលមានចែងនេះ គឺត្រូវជ្រើសរើសអ្នក ដែលមិនមានជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការ មានន័យថាសាក្សីមិនអាចជាមន្ត្រីនគរបាលយុត្តិធម៌ ឬជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ។ ដូចនេះសាក្សីត្រូវជ្រើសរើសចេញពីអ្នកដែលមិនបានចូលរួមប្រតិបត្តិការនៃការឆែកឆេរ។[17]

[16] មាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[17] មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

១.៣ ការចាប់យកវត្ថុតាង

បើសិនបើការបិទស្លាកបោះត្រាលើវត្ថុថាបើសិននៅក្នុងក្របខ័ណ្ឌនៃការចាប់យកវត្ថុតាង មន្ត្រីនគរបាលយុត្តិធម៌បានរកឃើញវត្ថុមួយដែលគួរឲ្យសង្ស័យគាត់មានសិទ្ធិមនុស្សចាប់យកវត្ថុតាងនោះបាន។ ពាក្យនេះជាពាក្យថ្មីដែលប្រើក្នុងក្រមព្រហ្មទណ្ឌនីតិវិធីព្រហ្មទណ្ឌពីការចាប់យកវត្ថុតាងដែលពីមុនទាំង លោកថាការរឹបអូសពីលើនេះបានន័យថាគាត់ចាប់ផ្តើមប្រតិបត្តិការ និងការឆែកឆេរបានរកឃើញវត្ថុតាងផ្សេងៗទាក់ទងបទល្មើសគាត់អាចយកវត្ថុតាងទាំងនោះត្រូវគេចាប់យកនោះហើយគាត់ត្រូវវេចខ្ចប់ភ័ស្តុតាងនេះទុក។ ជាទូទៅបើមើលឲ្យបានលម្អិតក្នុងក្រមនីតិវិធីព្រហ្មទណ្ឌក៏មានលក្ខណៈពិសេសខ្លាំងណាស់មានន័យថា គាត់ត្រូវបង្ហាញសាក្សីពីរនាក់ ឬលក្ខន្តិកៈចែងថាគាត់បានចាប់យកវត្ថុទាំងនោះហើយគាត់បានចាប់ផ្តើមវេចខ្ចប់ខ្ចប់ហើយមានបិទស្លាកនិងបោះត្រានិងឯកសារថាមិនមានការលួចដូរនៅឡើយ មិនត្រឹមតែប៉ុណ្ណោះ ពេលដែលគាត់បញ្ឈប់ប្រតិបត្តិការរបស់ខ្លួនគាត់ត្រូវធ្វើបញ្ជីសារពើភណ្ឌនៃវត្ថុតាងទាំងឡាយ ដែលបានទទួលខុសត្រូវភ្ជាប់ជាមួយកំណត់ហេតុនៃការឆែកឆេរមួយទៀត។ កំណត់ហេតុនេះត្រូវកំណត់ឲ្យបានច្បាស់អំពីការអនុញ្ញាតនៅវេលាម៉ោងដែលព្រមព្រៀងនេះក៏ផ្តល់ការអនុញ្ញាតឲ្យថាការអនុញ្ញាតជាលាយលក្ខណ៍អក្សរនិងផ្ទាល់មាត់។ អ្នកចូលរួមមានន័យថាសំដៅជាពិសេសផ្តល់លក្ខខណ្ឌថាទីកន្លែងឬសាក្សីពីររូប ដែលមានវត្ថុមានហើយដាច់ខាតត្រូវមានចុះហត្ថលេខារបស់គាត់ផ្តិតម្រាមដៃ[18]។

១.៤ ការស្តាប់ចម្លើយ

នៅក្នុងក្របខ័ណ្ឌនៃការស្រង់ចម្លើយក្រមនីតិវិធីព្រហ្មទណ្ឌ ពុំបានបែងចែកអំណាចឲ្យខុសគ្នាខ្លាំងទេព្រោះជាគោលការណ៍គឺមានតម្លៃដូចគ្នា។ក្នុងករណីដែលអ្នកដែលបានកោះហៅមិនចេះអក្សរខ្មែរ នោះមន្ត្រីនគរបាលយុត្តិធម៌អាចហោះរកអ្នកបកប្រែដែលបានស្បថទៅតាមសាសនា និងជំនឿរបស់ខ្លួនបាន។[19]

១.៥ ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ប្រសិនបើត្រូវការជំនាញខាងផ្នែកបច្ចេកទេសឬវិទ្យាសាស្ត្រ សម្រាប់ត្រៀមធ្វើការពិនិត្យបច្ចេកទេសឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បានអាចពឹង បុគ្គលគ្រប់រូប ដែលមានមុខជំនាញធ្វើការពិនិត្យផ្នែកបច្ចេកទេសនិង វិទ្យាសាស្ត្រទៅលើភ័ស្តុតាងដែលគាត់បានទទួលសិទ្ធិបានតែមួយគត់ដែលស្វែងរកភ័ស្តុតាងបន្តទៀតសម្រាប់បុគ្គលនោះមិនទាន់បានចុះឈ្មោះក្នុងបញ្ជីអ្នកជំនាញទេ។

១.៦ ការចាប់ខ្លួន

ការឃាត់ខ្លួនក្នុងការស៊ើបអង្កេតករណីជាក់ស្តែងមានចែងចាប់ពីមាត្រា៩៦ ដល់មាត្រា១០២។ ដូច្នេះ

[18] ដកស្រង់ចេញពីសៀវភៅនគរបាលយុត្តិធម៌របស់សាស្ត្រាចារ្យ កៅ សីហា

[19] មាត្រា ៩៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ

យើងត្រូវគោរពតាមជាកំហិតចំពោះការឃុំខ្លួនយើងនឹងលើកឧទាហរណ៍មកបញ្ជាក់ឲ្យឃើញ ទីមួយលក្ខខណ្ឌដែលត្រូវគោរពដើម្បីធ្វើការឃាត់។ ដើម្បីឆ្លើយតបតម្រូវការចាំបាច់នៃការស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស គួរបញ្ជាក់ថាគាត់ជាប់ឃុំគួរតែផ្តល់ព័ត៌មានអំពីរឿងហេតុនោះដែរ ប្រសិនបើជននោះប្រកែកមិនព្រមផ្តល់ព័ត៌មាននិងមានការយល់ព្រមជាលាយលក្ខណ៍អក្សរធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។ ទីពីររយៈពេលនៃការឃាត់ខ្លួនទាក់ទងនឹងរយៈពេលឃាត់ខ្លួនចិរវេលា៤៨ម៉ោងប៉ុណ្ណោះព្រោះនេះជាពេលវេលាដែលច្បាប់អនុញ្ញាតចំពោះបទឧក្រិដ្ឋ ហើយមើលទៅឃើញថាបុគ្គលដែលឃាត់ខ្លួននោះមានតម្រុយច្រើនបង្ហាញថាបុគ្គលពាក់ព័ន្ធនឹងបទឧក្រិដ្ឋ រយៈពេលនេះអាចសុំពន្យារបានចំនួនម្តងទៀតតែពន្យារមិនឲ្យលើសពី២៤ម៉ោងបានទេនឹងត្រូវសុំអនុញ្ញាតពី ព្រះរាជអាជ្ញាថែមទៀតផង នៅពេលមានការសុំព្រះរាជអាជ្ញាគាត់និងផ្ទៀងផ្ទាត់មើលថា តើការសុំពន្យារពេលរបស់មន្ត្រីនគរបាលយុត្តិធម៌មានមូលហេតុសមស្របដែរឬទេ ប្រសិនបើយើង មើលមូលកភាពមានន័យថាពិនិត្យទៅលើលក្ខណៈសមស្របណាទេ ការឃាត់ខ្លួនចំពោះអនីតិជន អនីតិជនយើងត្រូវចែកជាបីប្រភេទទៅតាមអាយុរបស់អនីតិជនធ្វើការឃាត់ខ្លួនយកទៅនោះមានអាយុក្រោម១៤ឆ្នាំនិង១៤ដល់១៦ឆ្នាំ និងពី១៦ឆ្នាំដល់ក្រោម១៨ឆ្នាំ ចំពោះអនីតិជនមានអាយុពី១៤ដល់ក្រោម១៦ឆ្នាំត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋមកដល់ឃុំខ្លួន៣៦ម៉ោងឡើយ ។ ចំពោះអនីតិជនអាយុពី១៦ ដល់ក្រោម១៨ឆ្នាំត្រូវចៅក្រមក៏បង្គាប់ឲ្យឃុំខ្លួនហួស រយៈពេល៤៨ម៉ោងឡើយ អនីតិជនដែលមានអាយុពី១៤ឆ្នាំដល់ក្រោម១៦ឆ្នាំចោទប្រកាន់ពីបទមជ្ឈិមមិនអាចឃុំខ្លួនហួសម្ភៃបួនម៉ោងឡើយ។ អនីតិជនដែលមានអាយុពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំដែលត្រូវចោទប្រកាន់ពីបទមជ្ឈិមមិនអាចឃុំខ្លួនហួស៣៦ម៉ោងឡើយ[20]។ កំណត់ហេតុស្តីពីការឃាត់ខ្លួន កំណត់ហេតុត្រូវធ្វើជាបន្ទាន់អំពីសេចក្តីសម្រេចចិត្តរបស់ខ្លួនដល់បុគ្គលដែលត្រូវឃាត់ខ្លួន។ កំណត់ហេតុស្តីពីការឃាត់ខ្លួនជាបន្ទាន់ដោយមានចុះសេចក្តីដូចតទៅៈ ឈ្មោះនិងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យឃាត់ខ្លួន សញ្ញាណនៃបុគ្គលដែលឃាត់ខ្លួន មូលហេតុនៃការឃាត់ខ្លួន ថ្ងៃខែឆ្នាំនិងម៉ោងដែលផ្តើមឃាត់ខ្លួន ហើយក៏ដំណឹងអំពីសិទ្ធិដែលបាន មួយចំនួនមានមេធាវីក្នុងពេលឃាត់ខ្លួនក្នុងរឿងនេះផងដែរ។

១.៧ ការបញ្ជូនខ្លួន

បើសិនគេដឹងថារយៈពេលនៃការឃាត់ខ្លួនក្រោយឈានទៅដល់៤៨ម៉ោងមក ទោះបីរយៈពេលដែលច្បាប់អនុញ្ញាតជាអតិបរមា៤៨ម៉ោងហើយបើគាត់គ្រាន់តែ ឃើញថាមានតម្រុយពន្យារបានម្ភៃបួនម៉ោងនេះគ្រាន់តែជារយៈពេលអតិបរមាមិនមែនកំណត់ថាទាល់តែ៤៨ម៉ោងបានគេបញ្ជូនកូនគេទៅទេ ។មន្ត្រីនគរបាល

[20] មាត្រា ៩៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ

យុត្តិធម៌ឃាត់ខ្លួនតែប្រាំម៉ោងឬតិចជាងពេលនេះគាត់បញ្ជូនទៅព្រះរាជអាជ្ញាក៏បានដែរ ព្រោះនៅពេលផុតរយៈពេលនេះគឺគាត់ត្រូវតែបញ្ជូនខ្លួននោះទៅមុខព្រះរាជអាជ្ញាតែម្តង [21]។

**២. ការស៊ើបអង្កេតបឋម ឬករណីមិនជាក់ស្តែង**

ការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង ក្រៅពីការសង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងករណីបទល្មើសជាក់ស្តែង ក្នុងការធ្វើការស៊ើបអង្កេតក្នុងករណីបទល្មើសមិនជាក់ស្តែងបានតែត្រូវគោរពនីតិវិធីមួយចំនួនដូចខាងក្រោម ៖

១. អត្ថន័យមិនជាក់ស្តែង

ករណីមិនជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តទៅតាមគោលការណ៍ ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចែងថាត្រូវធ្វើរបៀបណា។ សូមជម្រាបជូនថាអំណាចធ្វើការស៊ើបអង្កេតបឋមនេះគឺខុសពីអំណាចក្នុងការស៊ើបអង្កេតករណីមិនជាក់ស្តែង។

២.ការបើកការស៊ើបអង្កេតបឋម

ការបើកការស៊ើបអង្កេតបឋម ទាក់ទងនឹងការបើកការស៊ើបអង្កេតបឋមមានភាពខុសគ្នាទៅនឹងការស៊ើបអង្កេតករណីជាក់ស្តែង ដូចមានចែងក្នុងមាត្រា១១១ថា ការមិនបានដឹងពីអំពើដែលជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេតតាមការសុំរបស់ព្រះរាជអាជ្ញា [22]។

៣.មោឃភាពនៃការមិនគោរពវិធាន

ចំពោះវិធានដែលត្រូវអនុវត្តនៅក្នុងករណីស៊ើបអង្កេតបឋម និងយើងសង្កេតឃើញថាមិនសូវជាខុសគ្នាប៉ុន្មានទេ ទាក់ទងនិងការស៊ើបអង្កេតករណីជាក់ស្តែងព្រោះមាត្រា១១២បានបញ្ជាក់យ៉ាងច្បាស់ថាបទប្បញ្ញត្តិនៃទាំងនេះមោឃៈភាពនៃការមិនគោរពវិធានផ្ទៃក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋមដែលរួមមាន មាត្រា៩០ ៩៥ ១០៥ ១០៧ និងមាត្រា១០៨ នេះនឹងនាំឲ្យមានមោឃភាពនៃនីតិវិធីមានន័យថានីតិវិធីច្បាប់ មានលក្ខណៈដាច់ខាតត្រូវតែគោរពតាមវិធានទាំងនឹង។[23]

៤.ការឆែកឆេរ

ការឆែកឆេរ នៅក្នុងការស៊ើបអង្កេតបឋមថ្វីត្បិតតែមានចំណុចមួយចំនួនដូចគ្នានឹងការស៊ើបអង្កេតជាក់ស្តែងគឺផ្ទុយទៅវិញក៏នៅតែមានចំណុចមួយ ចំនួនមិនដូចគ្នាថាទាក់ទងនឹងប៉ះពាល់ដែលត្រូវគោរពសិទ្ធិមនុស្ស និងមន្ត្រីនគរបាលយុត្តិធម៌ត្រូវគោរពគឺមាន ដូចតទៅ កាលណា ការស៊ើបអង្កេតបឋមនោះទាក់ទងនឹងបទឧក្រិដ្ឋ

[21] មាត្រា ១០៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[22] មាត្រា ១១១នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[23] មាត្រា ១១២នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ឬបទមជ្ឈិមមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេត និងចាប់យកវត្ថុតាង។ការឆែកឆេរជាបឋមមន្ត្រីគាត់ផ្ទាល់ត្រូវទទួលការយល់ព្រមច្បាស់លាស់ពីម្ចាស់គ្រប់ទីកន្លែង ធ្វើការយល់ព្រមទាំងធ្លាប់ធ្វើជាលាយលក្ខណ៍អក្សរសរសេរផ្ទាល់ដៃរបស់កាន់កាប់ប្រសិនបើអ្នកនឹងអត់ចេះអក្សរត្រូវសរសរសេរឲ្យច្បាស់លាស់ក្នុងកំណត់ហេតុថាអ្នកទាំងពីរមិនចេះអក្សរប៉ុន្តែយល់ព្រមឆែកឆេរ [24]។

៥.ការឃាត់ខ្លួនជនជាប់សង្ស័យ

បុគ្គលគ្រប់រូបត្រូវបានសង្ស័យថាបានចូលរួមក្នុងការប្រព្រឹត្តបទល្មើសគឺ នឹងអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបានបុគ្គលនោះត្រូវបានកោះហៅថាជាចូលមកបង្ហាញខ្លួនក្នុងករណីដែលបុគ្គលនោះរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ជូនដំណឹងដល់ព្រះរាជអាជ្ញាចេញ បញ្ជាចូលខ្លួន ហើយបញ្ជានេះនេះត្រូវមានអត្តសញ្ញាណបុគ្គលពាក់ព័ន្ធកាលបរិច្ឆេទនិងចុះហត្ថលេខាដោយប្រធាននិងមានបោះត្រាផង។ បញ្ជាឲ្យចូលខ្លួននេះអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ ប្រើកងកម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះចូលបង្ហាញខ្លួន ។ការឃាត់ខ្លួនជនជាប់សង្ស័យយោងតាមមាត្រា១១៦ បញ្ជាក់ថាកាលណាការស៊ើបអង្កេតប្រភពទាក់ទងទៅនឹងបទឧក្រិដ្ឋឬបទមជ្ឈិមនិងបទប្បញ្ញត្តិនៃជំពូកទីបីស្តីពីការឃាត់ខ្លួន ក្នុងគន្ថីទីបីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវអនុវត្តដូចគ្នា ។

៦.កំណត់ហេតុក្នុងការស្តាប់ចម្លើយ

ដូចគ្នាទាក់ទងនឹងការឃាត់ខ្លួនជនជាប់សង្ស័យក្នុងការស៊ើបអង្កេតបឋម ក្នុងកំណត់ហេតុក្នុងការស្តាប់ចម្លើយរបស់គាត់ស្តាប់ចម្លើយទាំងអស់ធ្វើមន្ត្រីនគរបាលយុត្តិធម៌ គឺចាំបាច់ត្រូវគោរពឲ្យបានត្រឹមត្រូវតាមមាត្រា១១៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មាត្រា១១៥ចែងច្បាស់ថាការសួរចម្លើយៗត្រូវធ្វើកំណត់ហេតុហើយកំណត់គោលដៅដ៏ត្រឹមត្រូវតាមចម្លើយរបស់បុគ្គលដែលពាក់ព័ន្ធក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ រកអ្នកបកប្រែដែលបានស្បថតាមជំនឿរបស់ខ្លួនថាខ្លួននឹងបកប្រែបានត្រឹមត្រូវ។ អ្នកបកប្រែមិនត្រូវបានជ្រើសរើសក្នុងចំណោម នគរបាលយុត្តិធម៌ កងរាជអាវុធហត្ថឬបុគ្គលដែលពាក់ព័ន្ធនៅក្នុងរួមជាមួយទេ[25]។

## ផ្នែកទី២ អំពីស្ថាប័នអយ្យការ

### កថាខណ្ឌទី១ និយមន័យ និងការរៀបចំអង្គការអយ្យការ

#### ១. និយមន័យនៃព្រះរាជអាជ្ញា

មានតែអយ្យការទេ ដែលមានសិទ្ធិបណ្តឹងអាជ្ញា ។ ព្រះរាជអាជ្ញាគឺជាអ្នកទទួលបន្ទុក ស្វែងរកបទល្មើសព្រហ្មទណ្ឌ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងជាអ្នកសុំអោយ អនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការ

[24] មាត្រា ១១៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[25] មាត្រា៧៤ កថាខណ្ឌទី៤នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា

ស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ [26]។

**២. ការជ្រើសរើសព្រះរាជអាជ្ញា**

ការជ្រើសរើសព្រះរាជអាជ្ញាដោយការប្រឡងដោយបំពេញលក្ខណ្ឌដូចជា ៖

I. ត្រូវមានសញ្ជាតិខ្មែរពីកំណើត

II. មានអាយុ៣៥ឆ្នាំយ៉ាងច្រើន ចំពោះនិស្សិតនិងមានអាយុ៤០ ឆ្នាំយ៉ាងច្រើន ចំពោះមន្ត្រីរាជការ

III. ត្រូវមានសញ្ញាបត្រ័ចាប់ពីបរិញ្ញាច្បាប់ឡើងទៅ

IV. មិនដែលមានទោសពីបទមជ្ឍឹម ឬឧក្រឹដ្ឋ

V. ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន ។

ការកំណត់នៃករជ្រើសរើសព្រះរាជអាជ្ញា ត្រូវធ្វើឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានពិភាក្សាព ពិគ្រោះយោបល់របស់សមាជិកទាំងអស់នៃអង្គចៅក្រម ។

បេក្ខជនដែលប្រឡងជាប់ព្រះរាជអាជ្ញាត្រូវបណ្តុះបណ្តាលដោយវិជ្ជាជីវៈ និងរៀបចំដោយក្រសួងយុត្តិធម៌។ ការរៀបចំនិងកាបណ្តុះបណ្តាលនេះនឹងត្រូវប្រកាសដោយរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ។

បែបបទនីតិវិធី កាលបរិច្ឆេទ និងទីកន្លែងព្រមទាំងគណៈមេប្រយោគនៃការប្រឡងប្រ ជែងជ្រើសរើសសិស្សព្រះរាជអាជ្ញាឬមេធាវីនឹងត្រូវប្រកាសដោយរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ។

ការជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌមេធាវី អាចធ្វើឡើងតាមរយៈការប្រឡងផ្ទៃក្នុង របស់មន្ត្រីរាជការ និងក្រឡាបញ្ជី អាចប្រឡងបានចាប់ពីបរិញ្ញាបត្រ័ឡើងទៅ និងមិនអាចលើសពីអាយុ៤៥ឆ្នាំ គិតចាប់ពីថ្ងៃប្រឡង[27]។

**កថាខណ្ឌទី២ សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា**

**១ . ការចោទប្រកាន់**

ព្រះរាជអាជ្ញាជាអ្នកដឹកនាំ និងសម្របសម្រួលដល់នគរបានយុត្តិធម៌ ជម្រុញនិងអនុញ្ញាតអោយមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស៊ើបអង្កេតស្រាវជ្រាវ ការអនុញ្ញាតអោយធ្វើការឆែកឆេរ ការអនុញ្ញាតអោយធ្វើការឃាត់ខ្លួន ដឹកនាំការឆែកឆេរនិងការអោយយោបល់នានា នៅពេលនគរបាលយុត្តិធម៌សុំយោបល់ពីព្រះរាជអាជ្ញា ។

នៅក្នុងមាត្រា ៤០នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាធ្វើការថ្លឹងថ្លែងពីចំណាត់ការ នៅលើបណ្តឹងផ្សេងៗដែលទទួលដោយផ្ទាល់ ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌ដែលបាន បញ្ជូនមក[28] ។ ព្រះរាជអាជ្ញាអាចធ្វើការតម្កល់រឿងទុកឥតចាត់ការ ប្រសិនបើខ្លួនយល់ឃើញថាករណីនោះមិនមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ដើម្បី

[27] ជំពូកទី៣ មាត្រា៨០ ១៩ ២០ ២១ ២២ ២៣នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា

[28] មាត្រា ៤០នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ធ្វើជាមូលដ្ឋានសម្រាប់ធ្វើការចោទប្រកាន់ ឬអាចធ្វើការចោទប្រកាន់ពីបទល្មើសណាមួយបាន ។ ករណីខ្លួនយល់ឃើញថា បទល្មើសនោះមានធាតុផ្សំគ្រប់គ្រាន់អាចធ្វើការចោទប្រកាន់ទៅជនដែលបានប្រព្រឹត្តិនោះបាន ។ មានន័យថា គោលការណ៍នៃមាត្រានេះបង្ហាញពីការកំណត់នូវកាលានុវត្តភាពនៃការចោទប្រកាន់ ។ តាមរយៈគោលការណ៍នេះផ្តល់អោយព្រះរាជអាជ្ញាសេរីភាពនិងឆន្ទានុសិទ្ធិ ក្នុងការវាយតម្លៃថាតើគួរធ្វើការចោទប្រកាន់ឬមិនធ្វើការចោទប្រកាន់ដោយផ្អែកលើទម្ងន់ទោសនិងមូលហេតុផ្សេងៗ អាចធ្វើជាធាតុផ្សំសំខាន់ៗ សម្រាប់ធ្វើការចោទប្រកាន់ព្រមទាំងធាតុផ្សំដទៃទៀត ដូចជាកាលៈទេសៈនៃការប្រព្រឹត្តិ និងភាពរឹករវដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយនៅក្នុងសង្គម ព្រមទាំងធាតុផ្សំមួយចំនួនទៀត ដែលអាចប្រមូលបានពីការស៊ើបអង្កេតនោះ ។

ម្យ៉ាងទៀតគោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់នេះក៏បានផ្តល់សិទ្ធិដោយអនុញ្ញាអោយព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការដែរទោះបីអំពើដែលបរិហានោះជាបទល្មើសក៏ដោយព្រោះគ្មានមូលហេតុគ្រប់គ្រាន់អាចចាត់ទុកជាធាតុផ្សំបទល្មើស ។

**២. ការតម្កល់រឿងទុកឥតចាត់**

យោងតាមមាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថាកាលណាបណ្តឹងណាមួយ ត្រូវតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់អ្នកប្តឹងអំពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេលពីរខែ គិតចាប់ពីថ្ងៃចុះពាក្យបណ្តឹង ក្នុងបញ្ជីបណ្តឹងដែលបញ្ជីបណ្តឹងនេះគឺតែងតែមាននៅតុលាការជាន់ដំបូងនីមួយៗ ត្រូវបានបង្កើតអោយមានបញ្ជីអយ្យការមួយសម្រាប់ចុះបណ្តឹងដែលប្តឹងដោយផ្ទាល់ដល់ព្រះរាជអាជ្ញា ឬបញ្ជូនមកតាមរយៈមន្ត្រីនគរបាលយុត្តិធម៍[29] ។

គ្រប់បណ្តឹងត្រូវតែចុះក្នុងបញ្ជីដែលមានខ្លឹមសារដូចជា ៖

- អត្តសញ្ញាណរបស់អ្នកប្តឹង
- កាលបរិច្ឆេទដែលអយ្យការបានទទួលពាក្យបណ្តឹង
- ប្រភពនៃបណ្តឹងបណ្តឹងផ្ញើរមកដោយផ្ទាល់ចំពោះព្រះរាជអាជ្ញាឬបញ្ជូនមកដោយមន្ត្រីគរបាលយុត្តិធម៍
- ប្រភេទនៃរឿងហេតុ ដែលអ្នកប្តឹងបានរាយការណ៍
- ចំណាត់ការលើពាក្យប្តឹង ការសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬចោទប្រកាន់ពីបទល្មើសណាមួយ ។

[29] មាត្រា ៤១នៃក្រមនីតិវិធីព្រហ្មទណ្ឌ

បញ្ជីនៃពាក្យប្តឹងត្រូវកាន់កាប់ដោយលេខាធិការរបស់អយ្យការក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។ បញ្ជីនេះ អាចត្រូវបានបើកមើលដោយអាជ្ញាធរតុលាការទាំងអស់ ។

យោងតាមគោលការណ៍កាលានុវត្តភាពនៃបណ្តឹងអាជ្ញានេះអានុញ្ញាតអោយព្រះរាជអាជ្ញា អាចរឿងទុកឥតចាត់ការបាន ទោះបីអំពើដែលបានប្តឹងឬបរិហារមកនោះ ជាបទល្មើសព្រហ្មទណ្ឌក៏ដោយ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា អំពើនោះមិនមានភាពរីករាលដល់សង្គមឬប៉ះពាល់ដល់សណ្តាប់ធ្នាប់ធ្ងន់ធ្ងរ ឬមួយជាការប្រព្រឹត្តិក្នុងកាលៈទេសៈពិសេសណាមួយដែលគួរអនុគ្រោះបាន ។

ជម្រើសមិនចោទប្រកាន់នេះបានស្តែងចេញតាមរយៈសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកលើការវាយតម្លៃរបស់ព្រះរាជអាជ្ញាតែមួយគត់ ។ ម្យ៉ាងទៀតទោះបីជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចមានសិទ្ធិលើ អធិបញ្ជាអោយព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយដែលខ្លួនបានដឹងក៏ដោយ ប៉ុន្តែមិនអាចធ្វើអធិបញ្ជាអោយតម្កល់រឿងទុកឥតចាត់ការឡើយ [30]។

### ៣. សេចក្តីសម្រេចក្នុងការចោទប្រកាន់

នៅពេលដែលមានភស្តុតាងល្មមអាចជឿបានថា ជនសង្ស័យអាចនឹងប្រព្រឹត្តិអំពើដែលគេប្តឹងមកនោះមែន ព្រះរាជអាជ្ញានឹងចាប់ផ្តើមធ្វើការចោទប្រកាន់។

ក្នុងករណីដែលមន្ត្រីរាជការណាម្នាក់ដែលតុលាការបានធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវធ្វើការជូនដំណឹងអំពីការចោទប្រកាន់ទៅប្រធានស្ថាប័នសាមី ក្នុងរយៈពេល ៧២ម៉ោងយ៉ាងយូរ (មាត្រា៥១នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល) ។ ការធ្វើការចោទប្រកាន់ចំពោះអនីតិជនត្រូវជូន ត្រូវជូនដំណឹងទៅអនីតិជនជាប់សង្ស័យ និងឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជននោះ ។

ទាក់ទងនឹងអនីតិជន ដែលជាជនជាប់សង្ស័យ សេចក្តីណែនាំអំពីការអនុវត្តគោលការណ៍នានា របស់ថ្នាក់ជាតិ និងអន្តរជាតិ ដែលកំពុងចូលជាធរណីមានតាក់ទងនឹងយុត្តិធម៌អនីតិជន ចេញដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចុះថ្ងៃទី ០៩ មិថុនា ២០០៥ បានកំណត់ថា៖ ប្រសិនបើមានភាពមិនច្បាស់លាស់អំពីអាយុរបស់អនីតិជនជាប់សង្ស័យនោះទេ ព្រះរាជអាជ្ញាគប្បីធ្វើការស៊ើបអង្កេតថែម ដើម្បីស្វែងរកការពិតអាយុរបស់អនីតិជនដែលជាប់សង្ស័យនោះ ។

ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបឋមឃើញថា អាយុរបស់អនីតិជនដែលជាប់សង្ស័មានអាយុតិចជាង ១៣ឆ្នាំ ព្រះរាជអាជ្ញាគប្បីចេញដីការតម្កល់រឿងទុកឥតចាត់ការ ហើយអោយដំណឹងទៅភាគីបណ្តឹងរដ្ឋ

[30] មាត្រា ២៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ប្បវេណី ។ តែបើលទ្ធផលនៃការស៊ើបអង្កេតឃើញថា អាយុរបស់អនីតិជនជាប់សង្ស័យនោះ ច្រើនជាង១៣ឆ្នាំតែតិចជាង១៨ឆ្នាំ ព្រះរាជអាជ្ញាអាចចោទប្រកាន់បាន ។

ការចាប់ផ្តើមធ្វើការចោទប្រកាន់នេះ គឺអាចធ្វើតាមវិធី៣យ៉ាង (មាត្រា៤៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ដែលរួមមានដូចជា ៖

៣.១ បើកការស៊ើបសួរ (ព្រះរាជអាជ្ញាចេញដីការសន្និដ្ឋានអោយស៊ើបសួរ)

ដីការសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ គឺជាដីការដែលព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរ អោយធ្វើការស៊ើបសួរលើអង្គហេតុ ដែលមានចែងក្នុងដីការសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ។

ដីការបញ្ជូនអោយស៊ើបសួរត្រូវមាននិទ្ទេស ដូចកំណត់ក្នុងមាត្រា៤៤ នៃនីតិវិធីក្រមព្រហ្មទណ្ឌពោលគឺ[31] ៖

## ក. សេចក្តីសង្ខេបអង្គហេតុ

ខេត្តរតនគិរី ៖ បុរសម្នាក់ត្រូវជាប្តីកំពុងតែកាប់ដើមឈើមិនបានមើលជុំវិញក្បែរខាង ស្រាប់តែរលំ ត្រូវចំក្បាលប្រពន្ធយ៉ាងធ្ងន់ធ្ងររហូតដល់ស្លាប់ភ្លាមៗនៅនឹងកន្លែងកើតហេតុ។ បុរសកាប់ដើមឈើ រលំត្រូវក្បាលប្រពន្ធស្លាប់នោះបានកើតឡើងនៅវេលាម៉ោង២ និង៣០នាទី ថ្ងៃសុក្រ ២រោច ខែមាឃ ឆ្នាំ រកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០២ ខកុម្ភៈ ឆ្នាំ២០១៨ ត្រង់ចំណុចអូរល្អះតូច ស្ថិតនៅភូមិ៥ ឃុំត្រពាំងច្រេស ស្រុកកូនមុំ ខេត្តរតនគិរី។

ប្រភពពីសមត្ថកិច្ចស្រុកកូនមុំបានឱ្យដឹងថាស្ត្រីរងគ្រោះមានឈ្មោះ មេង រឹម អាយុ២១ឆ្នាំ ជនជាតិខ្មែរ។ បុរសត្រូវជាប្តីដែលជាអ្នកកាប់ដើមឈើរលំ បណ្តាលឱ្យមាន គ្រោះថ្នាក់ដល់ប្រពន្ធរហូតដល់ស្លាប់នោះមានឈ្មោះ នួន អាយុ២៤ឆ្នាំ ជនជាតិខ្មែរ រស់នៅភូមិកើតហេតុ ខាងលើ។ តាមការរៀបរាប់របស់ប្តីជនរងគ្រោះប្រាប់ដល់សមត្ថកិច្ចថា រូបគាត់កំពុងតែកាប់ដើមឈើ មិនបានដឹងថាប្រពន្ធមកឈរក្បែរនោះទេ លុះដល់ពេលដើមឈើរលំទៅហើយ ទើបដឹងថាប្រពន្ធនៅក្បែរ ហើយរងគ្រោះរហូតដល់ស្លាប់បែបនេះ។ សមត្ថកិច្ចធ្វើការត្រួតពិនិត្យរួចរាល់ក៏បានប្រគល់សាកសព ឲ្យសាច់ញាតិយកទៅធ្វើបុណ្យតាមប្រពៃណីផងដែរ៕

## ខ. ការកំណត់ឈ្មោះបទល្មើស

បទមនុស្សឃាតដោយអចេតនា ។

## គ. ការបង្ហាញអត្ថបទច្បាប់ដែលបានកំណត់

បទមនុស្សឃាតដោយអចេតនា (មាត្រា២០៧នៃក្រមព្រហ្មទណ្ឌ) កំណត់ទោសដាក់ពន្ធនាគារ ពី ១ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២ ទៅ ៦លានរៀល[32]។

[31] មាត្រា ៤៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[32] មាត្រា ២០៧នៃក្រមព្រហ្មទណ្ឌ

**ឃ. ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើមាន**

នៅក្នុងករណីមិនអាចកំណត់បាន តំណាងអយ្យការអាចបើកការស៊ើបសួរ ប្រឆាំងទៅនិងអញ្ញតជន ពោលគឺជនមិនស្គាល់ ។

**ង. ចុះកាលបរិច្ឆេទ និងហត្ថលេខា**

ព្រះរាជអាជ្ញាមានសមត្ថកិច្ចធ្វើដីការនេះ ស្នើរអោយចៅក្រមស៊ើបសួរដាក់អោយស៊ើបសួរក្នុងករណីដូចខាងក្រោមនេះ ៖

- បទល្មើសឧក្រិដ្ឋជាក់ស្តែង ឬមិនជាក់ស្តែង
- បទល្មើសមជ្ឈឹមដែលព្រះរាជអាជ្ញាត្រូវមានការស៊ើបសួរ ។

៣.២ បញ្ជូនរឿងទៅជុំនុំជម្រះផ្ទាល់

ក្នុងករណីនេះព្រះរាជអាជ្ញា ចេញដីការបញ្ជូបរឿងទៅជំនុំជម្រះផ្ទាល់ ហើយត្រូវចេញដីការកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ។ដូច្នេះ ជំនុំរឿងនឹងត្រូវបញ្ជូនទៅចៅក្រមជំនុំជម្រះ ។

ការបញ្ជូនទៅជំនុំជម្រះផ្ទាល់អាចធ្វើបានតែបទមជ្ឈឹម (មាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ) និងបទលហុ មាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌតែប៉ុណ្ណោះ ។

ចំពោះបទមជ្ឈឹមដែលព្រះរាជអាជ្ញាយល់ឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីអោយតុលាការធ្វើការជំនុំជម្រះវិនិច្ឆ័យលើរឿងក្តីនេះបាន ព្រះរាជអាជ្ញានិងប្រើវិធីនេះ ។

៣.៣ នីតិវីធីនៃការបង្ហាញខ្លួនភ្លាម

ប្រសិនបើលក្ខខណ្ឌនៃមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានបំផ្លាញ ព្រះរាជអាជ្ញាអាចប្រើប្រាស់នីតិវិធីនេះបានដោយធ្វើកំណត់ហេតុនីតិវិធីបង្ហាញខ្លួនភ្លាមតែប៉ុណ្ណោះពុំមានចេញដីការសន្និដ្ឋានអ្វីនោះទេ ដែលលក្ខខណ្ឌរួមមាន ៖

- បទល្មើសមជ្ឈឹមជាក់ស្តែង ។
- បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធធនាគាយ៉ាងតិច១ឆ្នាំ យ៉ាងយូរ៥ឆ្នាំ ។

ជាក់ស្តែងបទល្មើសដែលបានលើកឡើងខាងលើជាបទល្មើសមជ្ឈឹមជាក់ស្តែង មាត្រា២០៧នៃក្រមព្រហ្មទណ្ឌ) កំណត់ទោសដាក់ពន្ធនាគារ ពី ១ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២ ទៅ ៦លានរៀល ។

ឧទាហរណ៍៖ បទល្មើសលួច (យោងតាមមាត្រា ៣៥៦នៃក្រមព្រហ្មទណ្ឌបទលួចត្រូវផ្តន្ទាទោសដាក់ពន្ធធនាគារ ពី ៦ខែ ទៅ៣ឆ្នាំ វាអាចជាចន្លោះបទមជ្ឈឹមដូច្នេះព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់តាមវិធីនេះបាន[33] ។

[33] សារណានីតិវិធីព្រហ្មទណ្ឌដំណាក់កាលទាំង៤នៃរឿងក្តីព្រហ្មទណ្ឌរាជធានីខេត្តរៀបរៀងដោយ វណ្ណថា ជាតវណ្ណ

# ជំពូកទី២

# ការសើបសួរ

# ជំពូកទី២ ការស៊ើបសួរ

## ផ្នែកទី១ ដំណាក់កាលចៅក្រមស៊ើបសួរ

ដោយយោងតាមជំនឿលើប្រព័ន្ធវិស័យយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជាចៅក្រមស៊ើបសួរមានតួនាទីសំខាន់ណាស់ក្នុងការចូលរួមចំណែកស្វែងរកយុត្តិធម៌ដល់គូភាគី។ តួនាទីសារៈសំខាន់របស់ចៅក្រមស៊ើបសួរគឺការសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្នបានជាសេចក្ដីសម្រេចមានលក្ខណៈប៉ះពាល់យ៉ាងខ្លាំងទៅនឹងសិទ្ធិសេរីភាពរបស់បុគ្គលមានន័យថាចៅក្រមស៊ើបសួរ មិនត្រឹមតែធ្វើការស៊ើបសួរនោះទេគឺត្រូវស្វែងរកភស្តុតាងដោះបន្ទុក និងដាក់បន្ទុកផងដែរ។

### កថាខណ្ឌទី១ ការបើកការស៊ើបសួរ

ចៅក្រមស៊ើបសួរមិនអាចបើកកិច្ចនីតិវិធីស៊ើបសួរណាមួយ ដោយឯកឯងបានឡើយបើពុំមានសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញាអាជ្ញា។ កាលណាចៅក្រមស៊ើបសួរបានទទួលពាក្យបណ្ដឹងឲ្យមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចៅក្រម ស៊ើបសួរត្រូវធ្វើតាមនីតិវិធីដូចមានកំណត់ក្នុងមាត្រា១៣៩(ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា)និងមាត្រា១៤០(ការបង់ប្រាក់តម្កល់ទុក)។ ការស៊ើបសួរត្រូវធ្វើឡើងចំពោះបទឧក្រិដ្ឋ តែបទមជ្ឈិមធ្វើក៏បានមិនធ្វើក៏បាន។ចៅក្រមស៊ើបសួរមិនអាចស៊ើបសួរលើអង្គហេតុនូវចំណុចណាដែលមិនបានបង្ហាញដោយព្រះរាជអាជ្ញានោះឡើយ[34]។

ប្រសិនបើមានលេចចេញអង្គហេតុថ្មីជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលស៊ើបសួរនោះចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនោះទៅ ព្រះរាជអាជ្ញាក្នុងករណីនេះព្រះរាជអាជ្ញាអាចប្ដឹងសុំឲ្យចៅក្រមស៊ើបសួរដើម្បីធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះតាម ការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។

ប៉ុន្តែចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងបន្ថែមទេប្រសិនបើអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូងមាត្រា១២៥។ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចដែនដីចំពោះគ្រប់បទបទល្មើសដែលបានប្រព្រឹត្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ចៅក្រមដែលមានសមត្ថកិច្ចគឺៈ[35]

-ចៅក្រមនាទីកន្លែងដែលបទល្មើសបានកើតឡើង

-ចៅក្រមនាលំនៅឋានពីសំណាក់របស់បុគ្គលសង្ស័យថាបានប្រព្រឹត្តបទល្មើស

-ចៅក្រមជាទីកន្លែងដែលចាប់ខ្លួនបុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស។ចៅក្រមស៊ើបសួរ មាន

[34] មាត្រា១៣៩ និងមាត្រា ១៤០នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[35] មាត្រា១២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សមត្ថកិច្ចគ្រប់បុគ្គលទាំងអស់លើកលែងតែជាសមត្ថកិច្ចរបស់តុលាការពិសេសនោះទេ។ នៅពេលជនជាប់ចោទ បានបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរសាលាដំបូងចៅក្រម ស៊ើបសួរត្រូវពិនិត្យអំពី

-អត្តសញ្ញាណនៃជនដែលបានបញ្ជូនមក

-ប្រាប់អំពីអង្គហេតុដែលបានធ្វើការចោទប្រកាន់

-ប្រាប់អំពីឈ្មោះបទល្មើសដែលបានចោទប្រកាន់

-មានសិទ្ធិឆ្លើយឬមិនឆ្លើយចំពោះការសួររបស់ចៅក្រមស៊ើបសួរនិងមានសិទ្ធិមានមេធាវី

ក្នុងករណីជនជាប់ចោទនៅក្រៅឃុំ បន្ទាប់ពីបង្ហាញខ្លួនលើកដំបូង ជននោះយល់ព្រមប្រកាសប្រាប់ទៅចៅក្រមស៊ើបសួរ អំពីអាសយដ្ឋានរបស់ខ្លួនឬនៅពេលដែលខ្លួនត្រូវបានផ្លាស់ប្តូរទីលំនៅ។ម្យ៉ាងទៀតគ្រប់ការឲ្យដំណឹងដែលបានធ្វើឡើងតាមរយៈអាសយដ្ឋានចុងក្រោយ ដែលប្រកាសឡើងដោយជនជាប់ចោទនោះត្រូវចាត់ទុកថាបានធ្វើឡើងដោយសាមីខ្លួនផ្ទាល់។

**១.ការស៊ើបសួរដាក់បន្ទុក**

យោងតាមសេចក្តីសន្និដ្ឋាន បញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញាដែលបានកំណត់អំពីអង្គហេតុនិងចំណុចដែលត្រូវឲ្យស៊ើបសួរហើយជាចំណុចនៃការស៊ើបសួរដាក់បន្ទុកពីព្រះរាជអាជ្ញានោះថា ពិតជាមានករណីដូចជាការចង្អុលបង្ហាញក្នុងដីកានេះដែរឬទេ។

**២.ការស៊ើបសួរដោះបន្ទុក**

ថ្វីដ្បិតតែចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរត្រឹមតែការចង្អុលបង្ហាញតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញាក៏ដោយ ក៏ចៅក្រមមានសេរីភាពក្នុងការស៊ើបសួរបានន័យថាចៅក្រមស៊ើបសួរធ្វើការងាររបស់ខ្លួនដោយស្វែងរកភស្តុតាងទាំងឡាយណាដែលជាមូលហេតុនៃភស្តុតាងដោះបន្ទុកផងដែរ។ ក្នុងអត្ថន័យនេះគឺដើម្បីការពារនូវសិទ្ធិជនជាប់ចោទនិងធានាផងដែរនូវភាពត្រឹមត្រូវនិងយុត្តិធម៌។ ចៅក្រមស៊ើបសួរដើរតួនាទីប្រៀបដូចជាអាជ្ញាកណ្តាលក្នុងការស្វែងរកការពិតនិងជាអ្នកបង្ហាញផងដែរអំពីភាពត្រឹមត្រូវរវាងបដិវិវាទនៃអយ្យការនិងជនជាប់ចោទដើម្បីដាក់ឲ្យចៅក្រមធ្វើការពិចារណាដោយយោងទៅតាមច្បាប់។

**៣.ការស៊ើបសួរជំនួស**

ទោះបីការស៊ើបសួរជាភារៈកិច្ចរបស់ចៅក្រមស៊ើបសួរក៏ពិតមែនតែបើយោងតាមមូលហេតុមួយចំនួនដែលបណ្តាលឲ្យចៅក្រម មិនអាចបំពេញភារៈកិច្ចនេះបានឬដោយមានភាពស្មុគស្មាញនៃបទល្មើសត្រូវស៊ើបសួរបន្ថែមទៀតខណៈពេលនោះ ចៅក្រមស៊ើបសួរអាចចេញដីកាចាត់ឲ្យស៊ើបសួរជំនួសបាន។[36]

យោងតាមរយៈដីកាមួយនេះចៅក្រមស៊ើបសួរអាចប្រគល់សិទ្ធិដល់ចៅក្រមនៃតុលាការរបស់

[36] ដកស្រង់ចេញពីសៀវភៅនីតិវិធីព្រហ្មទណ្ឌរបស់សាស្ត្រាចារ្យ ផៀង សំណាង

ខ្លួន ឬតុលាការ ឬនគរបាល ឬក៏អង្គការផ្សេងទៀតចាត់ឲ្យស៊ើបសួរជំនួសដើម្បីបំពេញ នាទីស៊ើបសួរជំនួសខ្លួនបាន។ដីកាប្រភេទនេះត្រូវបានបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវ និងចិរវេលាដែលត្រូវឲ្យស៊ើបសួរជំនួស។ដោយកិច្ចការនេះផងដែរត្រូវមានទំនាក់ទំនងផ្ទាល់ទៅនឹងបទល្មើសដែលបានចោទប្រកាន់។ដីកានេះមិនអាចមានលក្ខណៈទូទៅទេ នឹងតម្រូវឲ្យមានការណែនាំឲ្យបានច្បាស់លាស់មុននឹងអនុវត្ត។ម្យ៉ាងទៀតដីកានេះត្រូវមានកាលបរិច្ឆេទចុះហត្ថលេខាដោយចៅក្រមស៊ើបសួរប្រគល់សិទ្ធិនិងមានបោះត្រាផងដែរ។ គ្រប់ពេលណាក៏ដោយឲ្យតែចៅក្រមស៊ើបសួរយល់ឃើញថាជាការគួរនោះ គាត់មានអំណាចពេញលេញក្នុងការដកហូតដីកានេះបានគ្រប់ពេលវេលា។[37]

## កថាខណ្ឌទីពីរៈ វិធានការនិរន្តរាយ

នៅក្នុងវិធាននិរន្តរាយ គឺជាដំណាក់កាលមួយគឺជាការដកហូតសិទ្ធិសេរីភាពរបស់បុគ្គលណាម្នាក់ត្រូវបានអនុវត្តដោយអំណាចចាប់បង្ខំរបស់រដ្ឋគឺតាមរយៈស្ថាប័ននៃអំណាចតុលាការ។ ដ្បិតតែវិធានការមួយនេះបានរំលោភលើសិទ្ធិ និងសេរីភាពនៃជនជាប់ចោទក៏ពិតមែនតែក្នុងវត្ថុបំណងដើម្បីរក្សានូវតុល្យភាពនិងសណ្តាប់ធ្នាប់ក្នុងសង្គមក្នុងនោះសិទ្ធិសេរីភាពរបស់ជនជាប់ចោទក៏ត្រូវបានធានាតាមច្បាប់ផងដែរ។ ក្នុងការប្រើវិធានការមួយនេះចៅក្រមស៊ើបសួរមានសិទ្ធិអំណាច ក្នុងការចេញដីកាមួយចំនួនដូចមានចែងក្នុងបញ្ញត្តិជំពូកទី៣ គន្លីទី៤នៃក្រមនេះ។ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចូលខ្លួន នាំខ្លួន ចាប់ខ្លួន និងឃុំខ្លួន។

### ១.ដីកាបង្គាប់ឲ្យចូលខ្លួន

ដីកាបង្គាប់ឲ្យចូលខ្លួនគឺជាការបញ្ជាក់ទៅលើបុគ្គលណាម្នាក់ឬច្រើនឲ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ដីកាមួយនេះត្រូវចេញចំពោះជនត្រូវចោទឬទៅលើជន ណាមួយដែលមានតម្រុយអំពីពិរុទ្ធភាព។[38]ដីកាបង្គាប់ឲ្យចូលខ្លួនគឺត្រូវកំណត់នូវនិទ្ទេសដូចតទៅៈ

- អត្តសញ្ញាណនៃជនដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់និងអនុវត្តច្បាប់បង្ក្រាបអំពើល្មើស
- ថ្ងៃខែឆ្នាំនិងម៉ោង ពេលវេលាដែលត្រូវចូលខ្លួន
- ឈ្មោះនិងឋានៈនៃចៅក្រមដែលចេញដីកា។

ត្រូវចាត់ទុកថាជាដីកាដែលបានការនោះគឺត្រូវកំណត់កាលបរិច្ឆេទ ហត្ថលេខា ចៅក្រមស៊ើបសួរនិងបោះត្រាផង។មួយវិញទៀតដីកានេះត្រូវបានបញ្ជូនទៅដល់ជនពាក់ព័ន្ធដោយមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលា។ អ្នកដែលមានកម្មវត្ថុក្នុងដីកានេះត្រូវចុះហត្ថលេខាជាចំណាំថាពិតជា

[37] មាត្រា១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[38] មាត្រា១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

បានទទួលដីកានេះនូវដើមដីកា។

**២. ដីកាបង្គាប់ឲ្យនាំខ្លួន**

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួន។ដីកាបង្គាប់ឲ្យនាំខ្លួនគឺជាបញ្ជាដល់កងកម្លាំងសាធារណៈឲ្យចាប់និងនាំបុគ្គលណាម្នាក់ត្រូវចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវចេញទៅលើជនត្រូវចោទ ឬ បុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព[39]។ដែលដីកានេះត្រូវចុះនិទ្ទេសដូចខាងក្រោម៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- បទល្មើសដែលចោទប្រកាន់និងអត្ថបទច្បាប់ដែលកំណត់និងបង្ក្រាបបទល្មើសនេះ។
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា

ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវចុះកាលបរិច្ឆេទនិងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរនិងមានបោះត្រាផង។ បើពុំមានកំណត់ណាមួយដូចខាងលើទេត្រូវចាត់ទុកជាមោឃៈ។ ដីកានេះមានទិសដៅក្នុងការស្វែងរកជនដែលជាកម្មវត្ថុនៃដីកានេះ ដែលត្រូវអនុវត្តដោយមន្ត្រីនគរបាលយុត្តិធម៌ មិនត្រឹមតែប៉ុណ្ណោះដោយយោងតាមស្ថានភាពពិសេស ដីកានេះបានបង្គាប់ដល់នគរបាលនិងកងរាជអាវុធហត្ថផងដែរ។ ចំពោះការអនុវត្តដីកានេះ ក្នុងករណីនៃការចូលលំនៅឋានមានបញ្ញត្តិនៃការឆែកឆេរក៏ត្រូវយកមកអនុវត្តផងដែរ។ បុគ្គលដែលនឹងត្រូវបង្ហាញខ្លួនបន្ទាប់ពីការអនុវត្តដីកានេះរួចហើយ តែមិនអាចធ្វើការបង្ហាញខ្លួនបាននៅថ្ងៃនោះមុខចំពោះមុខចៅក្រមស៊ើបសួរ ឬអ្នកជំនួសដោយស្ថានភាពពិសេសណាមួយជននោះត្រូវបញ្ជូនខ្លួនទៅអង្គភាពនគរបាល ឬមណ្ឌលឃុំខ្លួនឬក៏ពន្ធនាគារដើម្បីធានាការបង្ហាញខ្លួន តែការបង្ហាញខ្លួនគឺនៅថ្ងៃបន្ទាប់បើពុំនោះទេជនដែលពាក់ព័ន្ធនឹងត្រូវដោះលែងឲ្យមានសេរីភាព។

គួរបញ្ជាក់ផងដែរថិរវេលានៃការឃុំខ្លួនជាបណ្តោះអាសន្នដោយផ្អែកតាមអានុភាពនៃដីកានេះ វាមិនមែនជាការឃុំខ្លួនបណ្តោះអាសន្នដែលត្រូវបានកំណត់ក្នុងជំពូកទី៤ ផ្នែក ទី៥(ការឃុំខ្លួនបណ្តោះអាសន្ន)ទេ តែបើមានការឃុំខ្លួនបណ្តោះអាសន្នត្រូវបានអនុវត្តដោយយោងតាមផ្នែកនេះ នោះថិរវេលាត្រូវរាប់បញ្ចូលក្នុងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន។

**៣.ដីកាបង្គាប់ឲ្យចាប់ខ្លួន**

ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន។ ដីកាបង្គាប់ឲ្យចាប់ខ្លួនគឺជាបញ្ជាដល់កម្លាំងសាធារណៈស្រាវជ្រាវនាំខ្លួនជននោះទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួននិងប្រាប់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួលនិងឃុំខ្លួនជននោះ[40]។ ដីកានេះត្រូវប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកអនុវត្ត។ទោះបីជាចៅក្រមស៊ើប

[39] មាត្រា១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[40] ដកស្រង់ចេញពីសៀវភៅនីតិវិធីព្រហ្មទណ្ឌរបស់សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិនិងលោកស្រី ចាំង ស៊ីណាត

សួរមានសិទ្ធិអំណាចក្នុងការចេញដីកាបង្គាប់ឲ្យចាប់ខ្លួនក៏ដោយ តែចាំបាច់ណាស់ចៅក្រមស៊ើបសួរត្រូវទៅសុំយោបល់ពីព្រះរាជអាជ្ញាមុននឹងចេញដីកានេះ[41]។ចៅក្រមស៊ើបសួរចេញដីកានេះបានលុះត្រាតែៈ

– ជាបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ

បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួនមិនដឹងថា ស្ថិតនៅទីកន្លែងណាឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ និទ្ទេសដែលត្រូវចុះនៃដីកាបង្គាប់ឲ្យចាប់ខ្លួនហើយដីកាបង្គាប់ឲ្យចាប់ខ្លួនគឺមាននិទ្ទេសដូចខាងក្រោមៈ

– អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ

– បទល្មើសដែលចោទប្រកាន់និងអត្ថបទច្បាប់បានកំណត់បង្ក្រាបបទល្មើសនេះ

– ឈ្មោះនិងឋានៈនៃចៅក្រមត្រូវចេញដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរនិងមានបោះត្រាផង។ ព្រះរាជអាជ្ញាជាអ្នកធានាដល់ការផ្សព្វផ្សាយដីកានេះដោយ ក្នុងករណីចាំបាច់ដីកាបង្គាប់ឲ្យចាប់ខ្លួនអាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ដោយប្រើវិធានការនានាដែលមានប្រសិទ្ធភាព។

### ៤. ដីកាបង្គាប់ឲ្យឃុំខ្លួន

ដីកាបង្គាប់ឲ្យឃុំខ្លួនក្រោយពីចៅក្រមស៊ើបសួរ បានចេញដីកាបង្គាប់ឲ្យចាប់ខ្លួនរួចហើយនោះកិច្ចបន្ទាប់របស់ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន។ដីកាបង្គាប់ឲ្យឃុំខ្លួនគឺជាបញ្ជាដល់ប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួនឲ្យទទួលនិងឃុំខ្លួនជនត្រូវចោទ[42]។ ចៅក្រមស៊ើបសួរអាចនឹងចេញដីកាបង្គាប់ឲ្យឃុំខ្លួនបានលុះត្រាតែជនជាប់ចោទ ជាកម្មវត្ថុនៃដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន។ ប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួនក្នុងការទទួលនិងឃុំខ្លួនជនបុគ្គល។ ដីកាបង្គាប់ឲ្យឃុំខ្លួនរហូតទាល់តែទទួលការឲ្យដំណឹងអំពីការដោះលែងឲ្យមានសេរីភាពវិញ មិនត្រឹមតែប៉ុណ្ណោះ ក្នុងពន្ធនាគារឬមណ្ឌលឃុំខ្លួន ត្រូវរក្សាទុកតាមដីកាបង្គាប់ឲ្យឃុំខ្លួនឬចេញដីកានេះដោយបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដែរ ម្យ៉ាងវិញទៀតដីកាបង្គាប់ឲ្យឃុំខ្លួនមានចុះនិទ្ទេស[43]៖

- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលចោទប្រកាន់និងអត្ថបទច្បាប់ដែលបានកំណត់និងបង្ក្រាបបទល្មើសនេះ។
- ឈ្មោះនិងឋានៈរបស់ចៅក្រមដែលចេញដីកាដីកាបង្គាប់ឲ្យឃុំខ្លួនត្រូវមានចុះកាលបរិច្ឆេទចុះហត្ថលេខាដោយចៅក្រមស៊ើបសួរនិងមានបោះត្រាផង។

[41] មាត្រា១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[42] ដកស្រង់ចេញពីសៀវភៅនីតិវិធីព្រហ្មទណ្ឌរបស់សាសាស្ត្រាចារ្យ ផៀង សំណាង

[43] មាត្រា២២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## ៥. ដីកាសម្រេចឲ្យជនជាប់ចោទស្ថិតក្រោមការពិនិត្យរបស់តុលាការ

ដីកាសម្រេចដាក់ជនត្រូវចោទស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នឬសម្រេចដោះលែងជនត្រូវចោទនៅក្រៅឃុំនោះ ភាគីអាចដាក់ជននោះឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយតម្រូវឲ្យជនត្រូវចេះគោរពនូវកាតព្វកិច្ចមួយឬច្រើនដែលមានចែងក្នុងមាត្រា២២៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បន្ទាប់ពីមានការត្រួតពិនិត្យតាមផ្លូវតុលាការដែលមានចែងក្នុង២២៣នៃក្រមនីតិវិធីព្រហ្មទណ្ឌមានចំនួន១២ចំណុចគឺ[44]៖

១.មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ

២.មិនត្រូវផ្លាស់ប្ដូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

៣.មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។

៤.មិនត្រូវបង្ហាញខ្លួន ទៅតាមការកំណត់នៅអង្គភាពនគរបាលឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៥.ត្រូវឆ្លើយតបទៅនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៦.ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជី គ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។

៧.មិនត្រូវបើកបររថយន្ត។

៨.មិនត្រូវទទួលឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

៩.ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានានិងចិរវេលាបង់ប្រាក់នេះក៏កំណត់ដោយចៅក្រមស៊ើបសួរ។

១០. មិនត្រូវកាន់កាប់អាវុធ។

១១.ត្រូវប្រគល់ខ្លួនឲ្យគេពិនិត្យព្យាបាលមានជាយថាហេតុ ដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលក្នុងមន្ទីរពេទ្យ។

១២. មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។

ក្នុងករណីនេះ ចៅក្រមស៊ើបសួរ ពុំអាចបង្គាប់ឲ្យជនត្រូវចោទគោរពនូវកាតព្វកិច្ចណាផ្សេងទៀតបានទេ។ ដោយឡែកចំពោះដីកាសម្រេចនេះ ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបន្តធ្វើចំពោះអនីតិជនអាយុក្រោម១៤ឆ្នាំបានឡើយ។ ព្រះរាជអាជ្ញាអាចប្ដឹងសុំឲ្យចៅក្រមស៊ើបសួរចេញដីកានេះបាននៅក្នុងករណីចៅក្រមស៊ើបសួរត្រូវចេញក្នុងរយៈពេល៥ថ្ងៃ។ចៅក្រមស៊ើបសួរចេញដីកាសម្រេចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬពីការសម្រេចបដិសេធការសុំឲ្យលោកដាក់ជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការប្រសិនបើចៅក្រមស៊ើបសួរពុំបានសម្រេចក្នុងរយៈ

[44] មាត្រា ២២៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ពេល៥ថ្ងៃនេះគឺព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរសម្រេចជំនួសបាន[45]។ការកែប្រែឬបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ ក្រៅពីចេញដីកាសម្រេចនេះរួចហើយគឺអត់មានការកែប្រែឬបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការដោយមានរបៀប៣យ៉ាងដូចតទៅ ៖

-តាមគំនិតផ្តួចផ្តើមរបស់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរអាចកែប្រែខ្លឹមសារនៃកាតព្វកិច្ចអាចលុបចោលឬបញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលាមិនតែប៉ុណ្ណោះ ចៅក្រមស៊ើបសួរក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ។ ក្នុងករណីនេះចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញានិងជនត្រូវចោទ [46]។

-ដើមបណ្តឹងអាចធ្វើពាក្យសុំកែប្រែឬលើកលែងពីតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ៥ថ្ងៃ ហើយប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងពេលនោះទេព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរឲ្យសម្រេចជំនួសចៅក្រមស៊ើបសួរបាន។ ចំពោះដីកាសម្រេចមិនព្រមធ្វើតាមពាក្យសុំរបស់គេទេនោះទេត្រូវតែមានសំអាងហេតុ។

បណ្តឹងសុំកែប្រែការត្រួតពិនិត្យ តាមផ្លូវតុលាការនោះជនត្រូវចោទឬមេធាវីការពារជនត្រូវចោទជនត្រូវចោទអាចធ្វើពាក្យសុំឲ្យលើកលែងឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។ចៅក្រមស៊ើបសួរបញ្ជូនពាក្យនេះភ្លាមទៅព្រះរាជអាជ្ញាដើម្បីសុំយោបល់និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បី ពិនិត្យ ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេលប្រាំថ្ងៃ គិតពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ប្រសិនបើចៅក្រមស៊ើបសួរពុំបានសម្រេចក្នុងពេលនេះ គឺជនត្រូវចោទអាចប្តឹងទៅសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរបាន ។ប្រសិនបើមានពាក្យសុំសាជាថ្មីមុនពេលដែលចៅក្រមស៊ើបសួរឬសភាស៊ើបសួរសម្រេចលើពាក្យសុំមុននោះរយៈពេលប្រាំថ្ងៃត្រូវចាប់ផ្តើមគិតពីពេលចេញដីកាសម្រេចលើពាក្យសុំពីមុន។ មួយវិញទៀតដីកាសម្រេចដែលមិនព្រមធ្វើតាមពាក្យសុំគឺត្រូវមានសំអាងហេតុ។

ក្នុងករណីនេះផងដែរ ចៅក្រមស៊ើបសួរចេញដីកាសម្រេចកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការឬដីកាសម្រេចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការឬដីកាសម្រេចមិនព្រមកែប្រែឬ បញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការមាត្រា២២៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ[47]។ប្រសិនបើ ត្រូវចោទដែលត្រូវបានដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះជនត្រូវចោទជាប់កាតព្វកិច្ចដោយចៅក្រមស៊ើបសួរ។ ហេតុនេះប្រសិនមានការគេចវេះពីកាតព្វកិច្ចដោយចេតនាអាចនឹងត្រូវដាក់ទណ្ឌកម្ម។ ក្នុងករណីនេះមាត្រា២៣០អនុញ្ញាតឲ្យចៅក្រមស៊ើបសួរឃុំ

[45] មាត្រា ២២៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[46] មាត្រា ២២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
[47] មាត្រា ២២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ខ្លួនជនត្រូវចោទ បើទោះបីជាគាត់ជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះបីជាជនត្រូវចោទជាប់ឃុំបណ្ដោះអាសន្នអស់រយៈពេលអតិបរមាដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះប៉ុន្មានក៏ដោយ។ប៉ុន្តែរយៈពេលឃុំខ្លួនបណ្ដោះអាសន្នក្នុងករណីនេះគឺ៤ខែយ៉ាងយូរសម្រាប់នីតិជន ២ខែយ៉ាងយូរសម្រាប់អនីតិជនដោយពុំចាំបាច់ មានការបែងចែកប្រភេទបទល្មើសចោទប្រកាន់ទេ។ ការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ ក្រមនីតិវិធីព្រហ្មទណ្ឌបានផ្ដល់សិទ្ធិឲ្យព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណីឬមេធាវីក្នុងការស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបាន។

## កថាខណ្ឌទី៣ ព្រំដែននៃការស៊ើបសួររបស់ចៅក្រមស៊ើបសួរ

### ១. តាមការស្នើរបស់ព្រះរាជអាជ្ញា

ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញាគ្រប់ពេលវេលានៃការស៊ើបសួរព្រះរាជអាជ្ញាស្នើសុំឲ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាម ដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាចៅក្រមរូបនេះត្រូវសម្រេចការបដិសេធក្នុងរយៈពេលដប់ប្រាំថ្ងៃ ។ការសម្រេចឲ្យគ្រូត្រូវាមានសំអាងហេតុក្នុងថេរវេលាយ៉ាងឆាប់បំផុត ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេលប្រាំថ្ងៃគឺយើងពិនិត្យដោយផ្ទាល់តាមពាក្យសុំទៅសភាស៊ើបសួរសម្រេចជំនួសចៅក្រមស៊ើបសួរបាន។ មាត្រា១៣២នៃក្រមនីតិវិធីព្រហ្មទណ្ឌ[48]។

### ២.តាមការស្នើរបស់ជនត្រូវចោទ ឬ មេធាវីការពារជនត្រូវចោទ

ការស្នើសុំឱ្យបំពេញកិច្ចឲ្យជនត្រូវចោទឬមេធាវីការពារជនត្រូវចោទ ស្របពេលនៃការស៊ើបសួរជនត្រូវចោទអាចស្នើសុំឲ្យចៅក្រមស៊ើបសួរធ្វើការសួរសំណួរខ្លួនឬ ដើមបណ្ដឹងរដ្ឋប្បវេណីឬសាក្សីសួរតបតគ្នាឬចុះទៅដល់ទីកន្លែងកើតហេតុពាក្យសុំនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរមានសំណាងប្រសិនបើ ស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំទៅចៅក្រមរូបនេះគឺជាការបដិសេធថារយៈពេលមួយថ្ងៃបន្ទាប់ ពីទទួលពាក្យសុំដីកានេះគ្រាន់តែមានសំអាងហេតុគឺជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញជនត្រូវចោទឬមេធាវីការពារក្ដីឲ្យជនត្រូវចោទប្រសិនបើចៅក្រមស៊ើប បានកំណត់ក្នុងរយៈពេលមួយឆ្នាំគឺជនសង្ស័យទាំងនោះផ្ទាល់តាមនោះគឺសុំឲ្យសភាស៊ើបសួរបានសម្រាប់ជំនួសចៅក្រមស៊ើបសួរ ដីជាគង់វ័យជ្រៃពីការស្នើសុំឱ្យបំពេញកិច្ចដល់ដើមបណ្ដឹងរដ្ឋប្បវេណីឬមេធាវីការពារដើមបណ្ដឹងរដ្ឋប្បវេណីនោះ គ្រប់ពេលនៃការសាកសួរដើមបណ្ដឹងរដ្ឋប្បវេណីសំបូរចៅក្រមស៊ើបសួរចម្លើយរបស់ខ្លួនគឺចម្លើយសាក្សីសួរចម្លើយជនត្រូវចោទសួរព័ត៌មាន មិនព្រមធ្វើតាមពាក្យសុំពេលនោះចៅក្រមរូបនេះត្រូវចេញដីកាបដិសេធក្នុងរយៈពេលមួយខែក្រោយពេលទទួលពាក្យសុំដីកានេះត្រូវមានសំអាងហេតុថាធ្វើជូនដំណឹងជាបន្ទាន់ លុះដល់ដើមបណ្ដឹងរដ្ឋប្បវេណីឬមេធាវីការពារក្ដីដើមបណ្ដឹងរដ្ឋប្បវេណីប្រសិនបើចៅក្រម

[48] មាត្រា ១៣២នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ស៊ើបសួរមិនបានសម្រេចក្នុងរយៈពេលមួយខែពីដើមបណ្ដឹងរដ្ឋប្បវេណី ដែលប្ដឹងដោយផ្ទាល់តាមរយៈពាក្យសម្ដី សភាស៊ើបសួរបានសម្រេចជំនួសចៅក្រមស៊ើបសួរមាត្រាមួយរយបួននៃក្រម នីតិវិធីព្រហ្មទណ្ឌ។

**៣.ការស្នើសុំដោយដើមបណ្ដឹងរដ្ឋប្បវេណី ឬ មេធាវីការពារដើមបណ្ដឹងរដ្ឋប្បវេណី**

នៅគ្រប់ពេលនៃការស៊ើបសួរ ដើមបណ្ដឹងរដ្ឋប្បវេណី ឬមេធាវីការពារការពារដើមបណ្ដឹងរដ្ឋប្បវេណីអាចសុំដល់ចៅករមស៊ើបសួរឲ្យស្ដាប់ចម្លើយរបស់ខ្លួន ស្ដាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទដោយសួរតទល់ ឬចុះទៅដល់ទីកន្លែងកើតហេតុ។ ពាក្យសុំនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេដ ក្នុងរយៈពេល១ខែក្រោយពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ដើមបណ្ដឹងរដ្ឋប្បវេណី ឬមេធាវីការពារក្ដីរបស់ដើបណ្ដឹងរដ្ឋប្បវេណី[49]។

ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេល១ខែទេ ដើមបណ្ដឹងរដ្ឋប្បវេណី អាចប្ដឹងផ្ទាល់តាមរយៈសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ តាមមាត្រា១៣៤។

## ផ្នែកទី២ ការបិទការស៊ើបសួរ និងដីកាដំណោះស្រាយ

### កថាខណ្ឌទី១ ការបិទការស៊ើបសួរ

ការបិទការស៊ើបសួរបញ្ចប់ការស៊ើបសួរគឺជាការបញ្ចប់បេសកកម្មរបស់ ចៅក្រមស៊ើបសួរដែលទទួលបន្ទុកធ្វើការសិក្សាតាមចោទថាទទួលបន្ទុកការសាកសួរនេះធ្វើឡើងតាម ដីកាដំណោះស្រាយ ដីកាដំណោះស្រាយនេះ ជាដីកាសម្រេចបញ្ជូនសំណុំរឿងទៅសៀមរាប ត្រូវជំនុំជម្រះ ឬជាដីកាលើកលែងការចោទប្រកាន់ដោយចេញជាលិខិតជូនព័ត៌មានឬជូនដំណឹង ទៅព្រះរាជអាជ្ញាជនត្រូវចោទ ដើមបណ្ដឹង និងមេធាវីដើម្បីត្រួតពិនិត្យនិងឆ្លើយតប [50]។ ការសន្និដ្ឋានមុនជូនរបស់ចៅក្រមស៊ើបសួរ ការសន្និដ្ឋានបញ្ជូន ឲ្យត្រួតពិនិត្យផ្ទាល់ មិនមែនជាដីកាដំណោះស្រាយទេ ចៅក្រមសួរចេញដីកាសន្និដ្ឋាននេះដើម្បីបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួននឹងត្រូវបញ្ជូនមកព្រះរាជអាជ្ញាតាមរយៈដីកាបញ្ជូនរឿងឲ្យពិនិត្យទាំងមូល ក្នុងករណីនេះ ព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋានស្ថាពរដើម្បីឆ្លើយតបទៅនឹងចៅក្រមស៊ើបសួរគឺ វិញ ដោយឡែកចំពោះការឆ្លើយតបរបស់ព្រះរាជអាជ្ញាអាចជាការយល់ព្រមឬមិនយល់ព្រមទៅលើដីកាដំណោះស្រាយពីការសម្រេចបញ្ជូនសំណុំរឿង ទៅជំនុំជម្រះឬដីកាលើកលែងការចោទប្រកាន់ឬ ព្រះរាជអាជ្ញាដើម្បីស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម ។ការសន្និដ្ឋានដោយព្រះរាជអាជ្ញា ក្រោយពីបានទទួលសំណុំរឿងពីចៅក្រមស៊ើបសួររួចហើយព្រះរាជអាជ្ញាត្រូវធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួនមួយជាលាយលក្ខណ៍អក្សរដែលទាញចេញពីការពិនិត្យសំណុំរឿងទាំងមូលក្នុងរយៈពេលពីរថ្ងៃ គិត

[49] មាត្រា១៣៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[50] ដកស្រង់ចេញពីសៀវភៅនីតិវិធីព្រហ្មទណ្ឌរបស់សាស្ត្រាចារ្យ ធៀង សំណាង

ចាប់ពីថ្ងៃទទួលបានសំណុំរឿងរួចត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរទាំងសេចក្តីសន្និដ្ឋានរបស់ខ្លួន សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាពុំមានកម្លាំងចាប់បង្ខំឲ្យចៅក្រមស៊ើបសួរយល់ស្របតាមនោះទេ តែប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា សំណុំរឿងមិនទាន់ចប់សព្វគ្រប់នោះព្រះរាជអាជ្ញានឹងបញ្ជូនសំណុំរឿងនេះទៅចៅក្រមស៊ើបសួរវិញដើម្បីស្នើសុំឲ្យបើកការស៊ើបសួរបន្ថែមតាមរយៈពេលខាងមុខ ស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញាហើយត្រូវគោរពតាមបញ្ញត្តិមាត្រា១៣២។ ម្យ៉ាងវិញទៀតក្នុងរយៈពេលប្រាំថ្ងៃ ដប់ប្រាំថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និងមួយខែក្នុងករណីជនត្រូវចោទនៅក្រៅឃុំ ភាពជាថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿងដីកាសន្និដ្ឋានស្ថាពរត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងមានសំអាងហេតុ នៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះ ព្រះរាជអាជ្ញាអាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះឬក៏លើកលែងចោទប្រកាន់។

**កថាខណ្ឌទី២ ដីកាដំណោះស្រាយ**

ចៅក្រមស៊ើបសួរ បិទការស៊ើបសួររបស់ខ្លួនដោយចេញដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬជាដីកាលើកលែងចោទប្រកាន់។

**១. ដីកាបញ្ជូនរឿងទៅជំនុំជម្រះ**

ដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរបិទការស៊ើបសួររបស់ខ្លួនឲ្យចេញដីកាដំណោះស្រាយដីកានេះអាចជាដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះឬដីកាលើកលែងចោទប្រកាន់ បួនជិតមួយ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះក្នុងករណីនេះចៅក្រមស៊ើបសួរបញ្ជូនជនត្រូវចោទទៅតុលាការដើម្បីជំនុំជម្រះពីបទឧក្រិដ្ឋឬបទមជ្ឈិមដោយចៅក្រមស៊ើបសួរ រៀបរាប់អំពីអំពើហិង្សាត្រូវចោទប្រកាន់លើឈ្មោះបទល្មើសតាមច្បាប់ អង្គការនេះក៏មានរូបភាពពីគ្រប់សមត្ថកិច្ចរបស់ចៅក្រមសាកសួរពីសំណុំរឿងបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការនិងបញ្ចប់ការឃុំខ្លួនបន្តសម្ងស្ស បណ្តោះអាសន្នផងដែរ ម្យ៉ាងវិញទៀត ចៅក្រមស៊ើបសួរថាយោងតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយនិងក្រោមលក្ខខណ្ឌមួយចំនួនដូចកំណត់ក្នុងមាត្រាពីររយប្រាំក្នុងករណីនេះចៅក្រមស៊ើបសួរការរក្សាទុកជនត្រូវចោទឲ្យនៅក្រោមវិធានការឃុំខ្លួន សុទ្ធរហូតដល់ពេលបង្ហាញខ្លួននៅចំពោះមុខ តុលាការ។[51]

**២.ដីកាលើកលែងចោទប្រកាន់**

ដីកាលើកលែងចោទប្រកាន់ ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់ឬមិនបញ្ជូនជននោះគេជម្លៀសសាលាជម្រះក្តីក្នុងករណីដែល អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋឬបទមជ្ឈិមឬបទរហូតជនប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់គ្មានភ័ស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទម្យ៉ាងវិញទៀតក្នុងករណីរលត់បណ្តឹងអាជ្ញាលើមូលហេតុមួយចំនួនពីរក្នុងកំណត់ក្នុងមាត្រាប្រាំបួន ប្រាំពីរ ក៏ជាមូលហេតុនៃការឆ្លងថ្មីក្នុងនោះមានការ

[51] មាត្រា២៤៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ចោទប្រកាន់ផងដែរ ចំពោះការលើកលែងចោទប្រកាន់ថាជាការលើកលែងទាំងស្រុងឬមួយផ្នែកគឺបានន័យថា ទាក់ទងអំពើត្រូវបានដាក់ឲ្យចៅក្រមស៊ើបសួរព័ត៌មាននោះស្វែងរកបុគ្គលឬដីមួយផ្នែកនៃអំពើរបស់ជននោះ។

បញ្ជាក់ដែរថានេះនឹងមានអនុភាពជាធរមាន នៅពេលផុតចិរវេលាប្តឹងឧទ្ធរណ៍របស់ប្រទេសទេ ព្រះរាជអាជ្ញា តើត្រូវប្តឹងទៅសភាស៊ើបសួរនេះសភាព្រហ្មទណ្ឌ មេសុនខតូចមែនតែព្រះរាជអាជ្ញាយល់ព្រមតាមដីកាលើកលែងចោទប្រកាន់នោះដែរ ។

# ជំពូកទី៣

# ដំណាក់កាលកាលជំនុំ

# ជម្រះក្តី

# ជំពូកទី៣ដំណាក់កាលកាលជំនុំជម្រះក្តី

## ផ្នែកទី១ ដំណាក់កាលសវនាការ

### ១. សមត្ថកិច្ចរបស់តុលាការ

នៅពេលសាវនាការសមាសភាពជំនុំជម្រះមានចៅក្រមម្នាក់ឬនាក់ដែលសម្រេចជាសមូហភាពតំណាងអយ្យការនិងក្រឡាបញ្ជីសវនាការមួយរូប។នៅក្នុងចំណោមបីរូបមាន ចៅក្រមមួយរូបជាប្រធាននៃក្រុមប្រឹក្សាជំនុំជម្រះ ចំណែកឯចៅក្រមពីររូបទៀតជាចៅក្រម ក្រុមប្រឹក្សា ។ម្យ៉ាងវិញទៀតមុខងារចៅក្រម និងមុខងារព្រះរាជអាជ្ញាមានវិសមតិភាពនឹងគ្នា យ៉ាងដាច់ខាត ។ ប្រសិនបើចៅក្រមណាម្នាក់ បានបំពេញមុខងារជាព្រះរាជអាជ្ញា ឬព្រះរាជអា ជ្ញារង ឬចៅក្រមស៊ើបសួរលើសំណុំរឿងណាមួយហើយ ចៅក្រមនេះពុំអាចចូលរយមក្នុងការជំនុំជម្រះបានទេ។ បើពុំដូច្នេះទេចៅក្រមត្រូវចាត់ទុកជាមោឃៈតាមមាត្រា២៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ [52]។ គួរបញ្ជាក់ផងដែរ

- ក្រឡាបញ្ជីនៃតុលាការមានភារកិច្ចដែលទទួលបន្ទុកពាក្យបណ្តឹងនៅក្នុងពេលសវនាការ ម្យ៉ាងវិញទៀតក្រឡាបញ្ជីអាបបទបញ្ជាផ្ទៃក្នុង និងធ្វើការកត់សម្គល់អង្គហេតុតាមចៅក្រមជំនុំជម្រះ ។
- តំណាងអយ្យការគឺចាំបាច់ណាស់ នៅក្នុងនីតិវិធីសវនាការ ព្រះរាជអាជ្ញាត្រូវតែមានវត្ត មានព្រមទាំងជាអ្នកតមណាងអោយសង្គមជាពិសេសនៅក្នុងរឿងក្តីព្រហ្មទណ្ឌដោយ តាំងនាមជាគូរក្តីជានិច្ច ។
- ជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទ ពុំអាចចូលមកបង្ហាញខ្លួននៅពេកសវនាការ

បានទេ នោះតុលាការពិនិត្យទៅមើលរឿងក្តី ហើយអាចជ្រើសរើសសម្រេចតាមវិធីបី យ៉ាងរួមមាន ៖

១.ប្រសិនបើមិនអាចចូលមកបង្ហាញខ្លួនបានទេដោយមូលហេតុស្ថានភាព សុខភាពឬស្ថានភាពធ្ងន់ធ្ងរដែលធ្វើអោយជនជាប់ចោទបង្ហាញខ្លួនចមពោះមុខ តុលាការបាន ប្រធានតុលាការអាចបង្គាប់អោយសួរជនជាប់ចោទ នៅទីកន្លែងដែល ជននោះនៅបាន ដោយកំណត់កាលបរិច្ឆេតនៃការសួរចម្លើយ។ ការសួរចម្លើយត្រូវធ្វើ ដោយប្រធានសវនាការ នៅចំពោះមុខព្រះរាជអាជ្ញា និងក្រឡាបញ្ជីនិងមេធាវីរបស់ជនជាប់ចោទ លើកលែងតែជនជាប់ចោទរូបនោះបានបោះបង់នៅមេធាវីរបស់ខ្លួន។ ចំពោះចម្លើយនោះត្រូវធ្វើកំណត់ហេតុ ។

២.ប្រសិនបើជនជាប់ចោទជាប់ចោទពីបទឧក្រិដ្ឋឬបទមជ្ឈឹមដែលនអាចចូល មកបង្ហាញខ្លួនបានទេ ត្រូវកំណត់កាលបរិច្ឆេទថ្មីនៃការបើកសវនាការ។ ដីការបង្គាប់ អោយនាំខ្លួនមានចុះនិទ្ទេសដុចតទៅៈអត្តសញ្ញាណរបស់ជនជាប់ចោទបទល្មើសដែលចោទប្រកាន់និងអត្ថបទច្បាប់ដែលកំណត់និងបង្ក្រាប់បទល្មើសនេះឈ្មោះឋានៈរបស់ចៅកក្រមដែលចេញដីការ។ដីការបង្គាប់អោយនាំខ្លួនត្រូវមានកាលចុះបរិច្ឆេទ និងចុះហត្ថ

[52] មាត្រា ២៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

លេខាដោយប្រធានសវនាការ និងមានបោះត្រាផង(មាត្រា៣១០នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។ តាមបទបញ្ញាតិ មាត្រា១៩២ ក៏យកមកអនុវត្តដូចគ្នាផងដែរ ។

៣.ដោយធ្វើការបន្តនីតិវិធីទៅមុខទៀតក្នុងករណីនេះតុលាការចេញសាលក្រមកំបាំងមុខ ឬ សាលក្រមចំពោះមុខចាត់ទុកថាចំពោះមុខ ។

**២. នីតិវិធីពេលសវនាការ**

២.១ សមាសភាពនាពេលសវនាការ

សមាសភាពសាលាដំបូងរួមមាន៖

a) ប្រធាន

b) អនុប្រធាន

c) ចៅក្រម

d) ក្រឡាបញ្ជី

e) មន្ត្រីរដ្ឋបាននិងមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀតដែលបម្រើការងារនៅ សាលាដំបូង[53] ។

២. ២ នីតិវិធិនិងដំណាក់កាលនៃការជំនុំជម្រះ

ក្នុងដំណាក់កាលនេះជាដំណាក់កាលដែលត្រូវសម្រេចអំពីការពិតណាមួយ ដែលត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់ដោយអនុភាពនៃការ ចាប់បង្ខំ គឺ សាលក្រម។ មុននឹងសម្រេចប់សវនាការក្រឡាបញ្ជីនៃសវនាការត្រូវប្រកាសអំពីរបេទបញ្ជា ផ្ទៃក្នុងនិងធ្វើសេចក្ដីថ្លែងអំពិសមាសភាពអ្នកដែលចុលរួម ទើបសម្រេចបើកសវនាការដោយចៅក្រម ។ តុលាការព្រហ្មទណ្ឌបើកសវនាការជំនុំជម្រះបានតែលើជនណាដែលបានបញ្ជូនមកក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ ។ ដោយនៅក្នុងដំណាក់កាលនេះស្ថិតនៅ ក្នុងដែនដីនៃសម្ថកិច្ចរបស់ចៅក្រមជមនុំជម្រះដែលយើងហៅបានថា ជាដំណាក់កាលជំនុំជម្រះចេញសាលក្រម ។ ក្នុងដំណាក់កាលនេះមានចៅក្រមថ្មីមួយទៀតដែលមិន ធ្លាប់ធ្វើការស៊ើបសួរឬចោទប្រកាន់ឡើយ។ រាល់ការជជែកដេញដោល ឬការតទល់គ្នា ការទាញហេតុផលរៀងៗខ្លួននឹងធ្វើឡើងនៅសវនាការ។ នៅក្នុងដមណាក់កាលនេះ លែងមានចេញដីការដូចនៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ឬដមនាក់កាលរបស់អយ្យការទៀតហើយ គឺមានតែសាលក្រមតែម្ដង ដែលមានអានុផាពនៃសាលក្រមនេះ អាចជាការផ្ដន្ទាទោសទៅលើជនជាប់ចោទ ឬរួចខ្លួនទៅលើការចោទប្រកាន់។

[53] ព្រះរាជក្រមលេខ នស/រកម/០៧០១/១០

២ ៣ ការកំណត់ពេលបើកសវនាការ

បន្ទាប់ពីតុលាការ បានទទួលសំណុំរឿង ដោយយោងតាមនីតិវិធីនៃការប្តឹងទៅ តុលាការ ប្រធានតុលាការត្រូវកំណត់កាលបរិច្ឆេទនៃសវនាករ ដោយបើកសវនាការដើម្បី កំណត់កាលបរិច្ឆេទនោះ។

ក្នុងករណីតុលាការបានទទួលបណ្តឹងដោយបញ្ជូនទៅជំនុំជម្រះក្តីផ្ទាល់ដោយដីការរបស់ចៅក្រមស៊ើបសួរ ឬ សាលដីការដោយសភាស៊ើបសួរ ប្រធាន តុលាការត្រូវថ្លឹងថ្លែងអំពីកាលបរិច្ឆេទនេះ ដូចមានចែងក្នុងមាត្រា៤៥៧ (រយៈដែលត្រូវគោរពរវាងដីការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់និងបង្គាប់អោយបង្ហាញខ្លួន) និងមាត្រា ៤៦៦ (រយៈពេលដែលត្រូវគោរពរវាងដីការកោះហៅ និងការបង្គាប់អោយបង្ហាញខ្លួន) ត្រូវ បានយកមកអនុវត្តដូចគ្នាផង ដែរ ។ ក្នុងករណីនេះជូនដំណឹងត្រូវជូនដំណឹងដល់ព្រះរាជ អាជ្ញាផងដែរ ។

២.៤ ការចូលរួមនីតិវិធីសវនាការ

នៅក្នុងសវនាការចាំបាច់ត្រូវមានអ្នកចូលរួម។ តើអ្នកណាខ្លះដែលត្រូវចូលរួមក្នុង នីតិវិធីនេះ?

1) ការចូលរួមរបស់ជនជាប់ចោទក្រោយពីទទួលបានដំណឹងអំពីកាលបរិច្ឆេទ អំពីការបង្ហាញខ្លួនជនជាប់ចោទត្រូវបង្ហាញនៅក្នុងសវនាការដោយផ្ទាល់[54]។ ជនជាប់ចោទត្រូវអមដោយមេធាវីដែលខ្លួនជ្រើសរើស ឬស្នើរអោយតុលាការចាត់តាំងមេធាវីជំនួស ឬមិនត្រូវការមេធាវី បើជននោះយល់ថាខ្លួនអាចមានការពារខ្លួនបាននៅចំពោះមុខតុលាការ។ តែការមិនមានមេធាវី មិនត្រូវបានអនុវត្តចំពោះបទឧក្រិដ្ឋ ឬជនជាប់ចោទជា អនីតិជន ។ ម្យ៉ាងវិញទៀត ការចូលខ្លួនរបស់ជនជាប់ចោទប្រព្រឹត្តទៅដោយ ឡែកពីគ្នាដូចក្នុងករណីបញ្ជូនទៅជំនុំជម្រះផ្ទាល់ជនជាប់ចោទចូលបង្ហាញខ្លួនដោយខ្លួនឯងនៅក្នុងសវនាការ(មាត្រា៣០២នៃនីតិវិធីព្រហ្មទណ្ឌ)។

2) ការចូលខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណីៈក្នុងសវនាការ ការតាំងខ្លួនជាដើម រដ្ឋប្បវេណីធ្វើតាមការប្រកាសប្តឹងសាមញ្ញនៅចំពោះក្រឡាបញ្ជី។ ការប្រ កាសនេះត្រូវចុះនីទ្ទេសក្នុងកំណត់ហេតុនៅសវនាការ។ ការតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីមិនអាចទទួលបានទេ ក្រោយពីសេចក្តីស្នើរសុំរបស់ព្រះ រាជអាជ្ញាត្រូវបានបញ្ចប់ (មាត្រា៣១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។នៅក្នុង ករណីនេះ បណ្តឹងរដ្ឋប្បវេណីក៏អាចជាមេធាវី សហព័ទ្ធ ឬញាតិលោហិតផ ងដែរ។ តែចំពោះអ្នកតំណាងមិនមែនជាមេធាវីត្រូវមានលិខិតជាលាយលក្ខ័ណ៍អក្សរ(មាត្រា ៣១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ )។

3) ការចូលខ្លួនរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចអមដោយមេធាវី។ អ្នកទទួលខុសត្រូវរដ្ឋប្ប វេណីអាចជាមេធាវី សហព័ទ្ធ ញាតិសាច់សាលោហិត (មាត្រា៣១៤នៃក្រមនីតិ

[54] មាត្រា៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

វិធីព្រហ្មទណ្ឌ)។

4) ការចូលខ្លួនរបស់សាក្សី មុននឹងឆ្លើយនឹងសំនួរសាក្សីនីមួយៗ ត្រូវផឹកទឹកសម្បថថា ខ្លួននិយាយតែការ ពិតស្របតាមសាសនា ឬជំនឿរបស់ខ្លួន(មាត្រា៣២៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ប្រធានតុលាការសួរសាក្សីនោះថាជា ញាតិលោហិតឬញាតិពន្ធរបស់ជនជាប់ ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចជាអ្នកស៊ីឈ្នួល បម្រើជននោះឬទេ ។

សាក្សីមានករណីកិច្ចផ្តល់នៅសាក្ខីកម្ម។ សាក្សីត្រូវតែចូលមកបង្ហាញខ្លួន នៅចំពោះមុខតុលាការតាមការកោះហៅរបស់តុលាការ តែបើរឹងទទឹងមិនព្រម ចូលមកនោះទេ វិធានការ នៃកម្លាំងសាធារណៈពីតុលាការត្រូវបានយកមក អនុវត្តដើម្បីធានាការបង្ហាញខ្លួនរបស់សាក្សី(មាត្រា៣១៥នៃនីតិវិធីព្រហ្មទណ្ឌ។

**៣. ការពិភាក្សាដេញដោល**

ក្រឡាបញ្ជីហៅឈ្មោះជនជាប់ចោទដើមបណ្តឹងរដ្ឋប្បវេណីអ្នកទទួលខុសត្រូវរដ្ឋប្ប វេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់អត្តសញ្ញាណ។ ប្រសិនដើមបើ ដើមបណ្តឹងរដ្ឋប្បវេណីអ្នកទទួលខុសត្រូវរដ្ឋប្បវេណីជាសហព័ទ្ធញាតិលោហិតក្រឡាបញ្ជីត្រូវផ្ទៀងផ្ទាត់សុពនភាពលិខិតអនុញ្ញាតិនៃការប្រគល់សិទ្ធ។ក្រឡាបញ្ជី សរសេរកំណត់ហេតុសវនាការដោយរៀបរាប់អំពីដំណើរប្រព្រឹត្តិទៅនៃសវនាការ និងសំណួរចម្លើយនៃការប្រព្រឹត្តិទៅនៃសវនាការ (មាត្រា៣៤១)។ មាត្រានេះត្រូវចុះហត្ថ លេខាដោយក្រឡាបញ្ជីនិងចុះទិដ្ឋាការក្រោយពីការផ្ទៀងផ្ទាត់ ដោយប្រធានសវនាការក្នុង រយៈក្រោយ១០ថ្ងៃប្រកាសសាលក្រម ។

- ភាគីនីមួយៗអង្គុយនៅតាមកន្លែងដែលទុកសម្រាប់អោយខ្លួននៅក្នុងសវនាការ។
- ប្រធានសវនាការប្រាប់ទៅជនជាប់ចោទអោយដឹងអំពើដែលគេចោទមកលើខ្លួន។
- ប្រធានសវនាការសួរចម្លើយជនជាប់ចោទ ទាំងដោះបន្ទុកនិងដាក់បន្ទុក។
- ព្រះរាជអាជ្ញា និងមេធាវី ព្រមទាំងភាគីអាចត្រូវបានអនុញ្ញាតអោយលើក សំណួរដល់ជនជាប់ចោទ ។
- ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនិងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។
- ព្រះរាជអាជ្ញា និងមេធាវី ព្រមទាំងភាគីអាចត្រូវបានអនុញ្ញាតអោយលើក សំនួរដល់ដលមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។ ក្រៅពីសំនួរព្រះរាជអាជ្ញា និងមេធាវីសំនួរផ្សេងទៀតត្រូវបានសួរដោយ ប្រធានសវនាការ ។
- តុលាការអាចស្តាប់ចម្លើយរបស់អ្នកប្តឹងបរិហារបានផងដែរ ដើម្បីយកព័ត៌ មាន (មាត្រា៣២៩នៃនីតិវិធីព្រហ្មទណ្ឌ)។

- ព្រះរាជអាជ្ញា និងមេធាវី ព្រមទាំងភាគីអាចត្រូវបានអនុញ្ញាតអោយលើក សំនួរដល់សាក្សី ។ ក្រៅពីសំនួរព្រះរាជអាជ្ញា និងមេធាវីសំនួរផ្សេងទៀត ត្រូវបានសួរដោយ ប្រធានសវនាការ ។ ភាគីអាចសុំអោយតុលាការស្តាប់ ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលដែលមានវត្តមានក្នុងសវនាការ ប៉ុន្តែមិន បានកោះហៅអោយបានត្រឹមត្រូវនោះទេហើយ ការស្តាប់ចម្លើយសាក្សីនេះ ត្រូវយល់ព្រមពីប្រធានសវនារទើបបាន [55]។ក្រឡាបញ្ជីស្រង់អត្តសញ្ញាណ និងអញ្ជើញសាក្សីនេះអោយថយទៅបន្ទប់រងចាំ។ ប្រសិនបើសាក្សីមិនអាច ចូលមកបង្ហាញខ្លួននៅមុខតុលាការតាមការកោះហៅនោះតុលាការអាចប្រើកម្លាំងសាធារណៈបង្ខំខ្លួនបាន ។ ប្រសិនបើជននោះ គ ថ្លង់ ក្រឡាបញ្ជីសរសេរសំនួរ រួចអោយជននោះសរសេរឆ្លើយសំនួរ ប្រសិនបើមិនអាច សរសេរឆ្លើយបាន ត្រូវរកអ្នកបកប្រែដោយអោយស្បថជាមុនសិនជួយដល់ តុលាការ បកប្រែចម្លើយដោយស្មោះត្រង់ (មាត្រា ៣៣១)។ ប្រសិនបើសាក្សី នោះមិនអាចនិយាយខ្មែរបានច្បាស់ល្អ ត្រូវរកអ្នកបកប្រែដោយត្រូវស្បថបកប្រែដោយភាពស្មោះត្រង់ ហើយអ្នកបកប្រែមិនអាចជា ព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវីឬសាក្សីក្នុងសវនាការបានទេ (មាត្រា៣៣០នៃនីតិវិធី ព្រហ្មទណ្ឌ)។
- ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចស្នើរសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនិងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការអោយឃើញការពិត។ សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនេះត្រូវចុះទិដ្ឋាការដោយប្រធានសវនាការ និងក្រឡាបញ្ជី ហើយភ្ជាប់ជាមួយសំណុំរឿង (មាត្រា៣៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ការដាក់សេចក្តីសន្និដ្ឋាននេះត្រូវធ្វើមុនពេលបិទ ការពិក្សាដេញដោល ។
- ប្រសិនបើការពិភាក្សាដេញដោលមិនបានបញ្ចប់ក្នុងសវនាការទេ តុលាការ អាចបន្តនៅសវនាការក្រោយតាមកាលបរិច្ឆេទដែលខ្លួនកំណត់[56] ។

**៤. ការប្រកាសសាលក្រម**

ការប្រកាសសាលក្រមត្រូវធ្វើឡើងនៅពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោល ឬនៅពេលសវការលើកក្រោយដែលកាលបរិច្ឆេទត្រូវកំណត់ដោយប្រធានសវនាការ ។ គ្រប់សាលក្រមត្រូវប្រកាសជាសាធារ

[55] មាត្រា៣២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[56] www.webside.drive.gogle.com

ណៈនៅពេលសវនាការ ដោយប្រធានសវនាការអានខ្លាំងៗ ផ្នែកនៃសេចក្តីសម្រេចរបស់សាលក្រម [57]។សាលក្រមដែលត្រូវប្រកាសអាចជា ៖

៤.១ សាលក្រមចាត់របៀប

តុលាការបង្គាប់ អោយប្រធានសវនាការ ចៅក្រមមួយរូបនៃក្រុមប្រឹក្សា ឬចៅក្រមដទៃទៀ តនៃតុលាការជាន់ដំបូងស៊ើបសួរបន្ថែម ប្រសិនបើយល់ឃើញថាការស្រាវជ្រាវជាថ្មីជាការចាំបាច់ ហើយចៅក្រមដែលទទួលបន្ទុកស៊ើបសួរបន្ថែមនេះអាចប្រើសិទ្ធិអំណាចដូចចៅក្រមស៊ើបសួរដែរ។

៤.២ សាលក្រមលើអង្គសេចក្តី

**ក. សាលក្រមចំពោះមុខ**

ប្រសិនបើជនជាប់ចោទចូលបង្ហាញខ្លួននៅពេលសវនាការ នោះសាលក្រមជាសាលក្រម ចំពោះមុខជនជាប់ចោទ [58]។ សាលក្រមចំពោះមុខជនជាប់ចោទមិនត្រូវអោយដំណឹងជននេះទេ។ សាលក្រមនេះនៅតែជាសាលក្រមចំពោះមុខដដែលបើទោះបីជនជាប់ចោទចេញពីបន្ទប់សវនាការក៏ដោយ(មាត្រា៣៦០)។ មួយវិញទៀតសាលក្រមនេះក៏ចាត់ទុកជាសាលក្រមចំពោះមុខដែរក្នុងករណីជនជាប់ចោទមានជំងឺធ្ងន់ធ្ងរហើយតុលាការបានធ្វើការសួរចម្លើយដល់កន្លែងដែល ជននោះស្នាក់នៅ។ សាលលក្រមចំពោះមុខអាចត្រូវប្តឹងឧទ្ធរណ៍បាន។

**ខ. សាលក្រមចំពោះដើមបណ្តឹងរដ្ឋប្បវេណី**

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីចូលបង្ហាញខ្លួននៅពេលសវនាការឬ មានអ្នកតំណាងដោយត្រឹមត្រូវនោះសាលក្រមត្រូវតែជាសាលក្រមចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីនេះ ។សាលក្រមចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីមនត្រូវជូនដំណឹងដល់សាមីខ្លួនទេ ។ ហើយសាលក្រមនេះអាចប្តឹងឧទ្ធរណ៍បាន។ ចំពោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណីក៏ដូចគ្នានឹងដើមបណ្តឹង រដ្ឋប្បវេណីផងដែរ ។

**គ. សាលក្រមកំបាំងមុខ**

ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយប្រសិនបើគ្មានភស្តុតាងបង្ហាញអោយឃើញថា សាមីខ្លួនដឹងពីដីការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងអំពីការ កោះហៅនោះទេ នោះសាលក្រមត្រូវប្រកាសកំបាំងមុចជនជាប់ចោទ ។ ក្នុងករណីដែលសាលក្រម ប្រកាសដោយពុំមានវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬអ្នក តំណាងដោយត្រឹមត្រូវសាលក្រមនេះអាចប្តឹងទាស់បាន (មាត្រា ៣៦៣ និងមាត្រា៣៦៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។

---

[57] មាត្រា៣៦៥នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[58] មាត្រា៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

## ផ្នែកទី២ បណ្តឹងទាស់

### ១. ទម្រង់នៃបណ្តឹងទាស់

ជាគោលការណ៍ គឺត្រូវធ្វើជាលាយលក្ខណ៍អក្សរ ៖

- នៅក្នុងការិយាល័យរបស់ក្រឡាបញ្ជីនៃតុលាការធ្វើការប្រកាសសាលក្រមនោះ ។
- នៅចំពោះមុខព្រះរាជអាជ្ញា ឬអង្គភាពនគរបាល ឬកងអាវុធហត្ថ ឬចំពោះមុខពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ។
- ករណីដែលពិរុទ្ធជនមានមេធាវីដើម្បីការពារខ្លួននោះ មេធាវីត្រូវតំណាងអោយពិរុទ្ធជន។ មេធាវីត្រូវមានលិខិតអនុញ្ញាតអោយធ្វើបណ្តឹងទាស់ កាលបើពិរុទ្ធជនជាអនីតិជនអាចត្រូវ តំណាងដោយឪពុកម្តាយ ឬអាណាព្យាបាលរបស់ខ្លួន ហើយអ្នកតំណាងដូចដែលបាន រៀបរាប់នេះមិនចាំបាច់ប្រគល់សិទ្ធិទេ ។ ប្រសិនបើទទួលបានពាក្យបណ្តឹងទាស់នេះព្រះរាជអាជ្ញា ឬអង្គភាពនគរបាល ឬកងរាជអា វុធហត្ថឬពន្ធធនាគារឬមណ្ឌលឃុំខ្លួននឹងបញ្ជូនបណ្តឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីតុលាការ ដែលបានធ្វើការប្រកាសសាលក្រមនោះ[59] ។

### ២. រយៈពេលនៃការប្តឹងទាស់

បណ្តឹងទាស់ត្រូវធ្វើក្នុងរយៈពេល១៥ថ្ងៃ កិតចាប់ផ្តើម ៖

- ពីថ្ងៃជូនដំណឹងពីសាលក្រមកំបាំងមុខកាលណាសាលក្រមត្រូវបានប្រគល់អោយពិរុទ្ធជន ដោយផ្ទាល់ដៃ ឬពីថ្ងៃដែលពិរុទ្ធជន បានដឹងយ៉ាងពិតប្រាកដអំពី សាលក្រមកាលណាសាលក្រមនេះមិន បានប្រគល់អោយដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេនោះ[60] ។

ដូច្នេះពិរុទ្ធជនដែលមិនសុខចិត្ត នឹងសាលក្រមកំបាំងមុខអាចប្តឹងទាស់បានរយៈ១៥ថ្ងៃ គិតចាប់ពីថ្ងៃដូចបានកំណត់ខាងលើនេះ។ ក្នុងករណីរយៈ១៥ថ្ងៃបានកន្លងផុតទៅពិរុទ្ធជន មិនបានប្តឹងទាស់នឹងសាលក្រមនេះទេ ពិរុទ្ធជននឹងត្រូវបាត់បង់សិទ្ធិនៅក្នុងការប្តឹងទាស់ នេះ តែពិរុទ្ធជននៅមានសិទ្ធិមួយទៀតគឺសិទ្ធិប្តឹងឧទ្ធរណ៍បាន ។

### ៣. អានុភាពនៃបណ្តឹងទាស់

៣. ១ បណ្តឹងទាស់ដោយពិរុទ្ធជន

បើបណ្តឹងទាស់ធ្វើប្រឆាំងសាលក្រមទាំងមូល សាលក្រមនេះត្រូវទុកជាអសាបង់។ ការ អនុវត្តសាលក្រមត្រូវព្យួរ មានន័យថាសាលក្រមកំបាំងមុខដែលចេញដោយគ្មានវត្តមានពិរុទ្ធជន នឹងត្រូវចាត់ទុកជាអសាបង់

[59] នីតិវិធីព្រហ្មទណ្ឌ សាស្ត្រាចារ្យអៀង សំណាង

[60] មាត្រា៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

នៅពេលដែលវាត្រូវបានពិរុទ្ធជនប្តឹងទាស់តាមរយៈដោយច្បាប់។ ហើយអានុភាពនៃកាប្តឹងទាស់នេះបានធ្វើអោយសាលក្រមត្រូវព្យួរ ។

តែទោះជាយ៉ាងនេះក៏ដោយ ដីកាបង្គាប់អោយចាប់ខ្លួននៅតែមានអានុភាពដដែល ទោះ សាលក្រមត្រូវបានព្យួរក៏ដោយដោយតុលាការនៅតែមានសមត្ថភាពដើម្បីសម្រេចពីការដោះលែងជនជាប់ចោទអោយមានសេរីភាពវិញ ។ ម្យ៉ាងទៀតកាលណាបណ្តឹងទាស់ធ្វើប្រឆាំង លើសេច ក្តីសម្រេចរដ្ឋប្បវេណី គឺមានន័យថាសេចក្តីសម្រេចផ្នែកនេះតែប៉ុណ្ណោះត្រូវទុកជាអាសាបង់ ដោយ ការសម្រេចលើផ្នែករដ្ឋប្បវេណីត្រូវទុកមួយរយៈសិនដោយរង់ចាំតុលាការសម្រេចលើបណ្តឹងទាស់នេះសិន ។

៣. ២ បណ្តឹងទាស់ដោយដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិប្តឹងទាស់ទៅនឹងសាលក្រមដែលសម្រេចកំបាំងមុខ ខ្លួន បានដែរ ។ បណ្តឹងទាស់នេះត្រូវកំណត់លើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីតែប៉ុណ្ណោះ ។

បណ្តឹងទាស់ត្រូវធ្វើរយៈ១៥ថ្ងៃ គិតចាប់ពី ៖

- ថ្ងៃអោយដំណឹងពីសាលក្រមកំបាំងមុខ កាលណាសាលក្រមប្រគល់អោយដើមបណ្តឹងរដ្ឋ ប្បវេណីដោយផ្ទាល់ដៃឬថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណី បានដឹងយ៉ាងពិតប្រាកដពីសាលក្រម បើសាលក្រមនេះ មិនបានប្រគល់អោយដល់ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ។ កាលបើដើមបណ្តឹង រដ្ឋប្បវេណីបានប្តឹងទាស់ទៅសាលក្រម ពាក្យបណ្តឹងនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយដាក់នៅក្នុងការិយាល័យរបស់ក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ក្នុងដំណាក់កាលនេះផងដែរ ដើមបណ្តឹងអាចត្រូវបានតំណាងដោយមេធាវី សហពន្ធ័ ឬ ញាតិលោហិតផ្ទាល់ ដោយអ្នកតំណាងទាំងនេះត្រូវមានលិខិតប្រគល់សិទ្ធិនៅក្នុងការប្តឹង ទាស់នេះ[61] ។

**៤. សាលក្រមសម្រេចលើបណ្តឹងទាស់**

សំណុំរឿង ត្រូវបានលើកយកជំនុំជម្រះនៅមុខតុលាការដដែល ។ មានន័យថានៅពេល ដែលតុលាការនឹងត្រូវលើកយកសំណុំរឿងនេះមកជំនុំជម្រះដោយភាគីពាក់ពន្ធ័ទៅនឹងរឿងក្តី នេះ នឹងត្រូវកោះហៅតាមរយៈគំនិតព្រះរាជអាជ្ញា។ ក្រោយពេលតុលាការពិនិត្យមើលពីភាព ដែលមិនអាចទទួលយកបាននៃបណ្តឹងទាស់នេះ តុលាការនឹងធ្វើការសម្រេចលើអង្គសេចក្តីជាថ្មី ម្តងទៀត ។

នៅក្នុងករណីដែលអ្នកប្តឹងទាស់ ដែលបានទទួលការកោះហៅដោយត្រឹមត្រូវតាមនីតិ វិធីហើយមិនអាចចូលបង្ហាញខ្លួន ពេលសវនាការទេ តុលាការនឹងប្រកាសថា បណ្តឹងទាស់នេះ ត្រូវទុកជាឯកសារឥតបានការ ។

---

[61] មាត្រា ៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

សាលក្រមដែលគេប្ដឹងទាស់នោះ ត្រូវរក្សាទុកដដែលមិនអាច មិនអាចកែប្រែបានទេ ដោយសាលក្រមនោះគឺមានអានុភាពចំពោះភាគីទាំងអស់ដែលពាក់ពន្ធ័ និងរឿងក្ដីនេះ [62]។

[62] មាត្រា ៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់បំផុត ក៏ដូចជាសរសេររៀបរ៉ាប់ ទាក់ទងទៅនឹងដំណាក់កាលសំខាន់ៗទាំងអស់នៅក្នុងសវនាការនៃរឿងក្តីព្រហ្មទណ្ឌនៅតុលា ការដំបូងរួចមក គឺពួកយើងអាចធ្វើសេចក្តីសន្និដ្ឋានបានថា នីតិវិធីនីមួយៗគឺមាភាពប្រទាក់ក្រ ឡានឹងគ្នា ចាប់តាំងពីនគរបាលយុត្តិធម៌រហូតដល់ដំណាក់កាលជំនុំជម្រះក្តីនិងការប្រ កាសសាលក្រម កាន់តែពិសេសគឺការអនុត្តដាក់ស្តែងនៅតុលាការដំបូងដែលមានទូទាំង ប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ។

នគរបាលយុត្តិធម៌ជាដំណាក់កាលដំបូងគេបង្អស់នៅក្នុងរឿងក្តីព្រហ្មទណ្ឌដោយហេតុ ថាដំណាក់កាលនេះសំខាន់ខ្លាំងណាស់ក្នុងការស្វែងរកបទល្មើសក៏ដូចជាអត្តសញ្ញាណរបស់ ជនល្មើស ព្រមទាំងធ្វើការឃាត់ខ្លួនបុគ្គលមួយចំនួននិងភស្តុតាងផងដែរ ក្នុងករណីដែលពួក គាត់យល់ឃើញថា បុគ្គលនោះបានចូលរួមប្រព្រឹត្តិបទល្មើស ។ ក្រោយពីការឃាត់ខ្លួនបុគ្គល ទាំងនោះរួចហើយនគរបាលយុត្តិធម៌ នាំខ្លួនជនល្មើសទៅអធិការដ្ឋាន បន្ទាប់មកធ្វើការស៊ើប សួរ ក្រោយសាកសួរក៏បង្គរសំណុំរឿងទៅអយ្យការដើម្បីចាត់ការតាមនីតិវិធី ។ តែទោះជាយ៉ា ងនេះក្តី ការអនុវត្តជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌ ពុំមានឧបករណ៍គ្រប់គ្រាន់សម្រាប់ធ្វើការ ចុះបង្ក្រាបបទល្មើសជាក់ស្តែង ។ ចំណែកឯស្ថាប័នអយ្យការ គឺជាដំណាក់កាលចោទប្រកាន់ ដែលរដ្ឋធម្មនុញ្ញបានធានាថាមានតែ អយ្យការទេជាបណ្តឹងនៃអាជ្ញា ។ មុននឹងធ្វើការចោទប្រ កាន់ត្រូវពិនិត្យមើលសំណុំរឿងដែលនគរបាលយុត្តិធម៌បញ្ជូនមក ហើយព្រះរាជអាជ្ញាត្រូវ ស្វែងរកភស្តុតាងដាក់បន្ទុក និងធាតុផ្សំបទល្មើស ។ កាលណាព្រះរាជអាជ្ញាយល់ឃើញថា មានបន្ទុកគ្រប់គ្រាន់ក្នុងការចោទប្រកាន់ គាត់អាចធ្វើតាមនីតិវិធីដូចជា ចេញដីការសន្និដ្ឋាន បញ្ជូនអោយស៊ើបសួរ ការបញ្ជូនរឿងអោយទៅជំនុំជម្រះផ្ទាល់ ឬនីតិវិធីបង្ហាញខ្លួនភ្លាម ។ មិនត្រឹមតែប៉ុណ្ណោះព្រះរាជអាជ្ញាក៏អាចតម្កល់រឿងទុកឥតចាត់ការបានផងដែរ ក្នុងករណីគ្មានបទល្មើសព្រហ្មទណ្ឌ ។ ព្រះរាជអាជ្ញាចោទប្រកាន់ និងធ្វើដីការសន្និដ្ឋានដោយស្នើរអោយចៅក្រម បើកការស៊ើបសួរ ។ ទោះជាយ៉ាងនេះក្តី យើងឃើញថា អង្គការអយ្យការគឺមានឋានានុក្រម មានន័យថា ព្រះរាជអាជ្ញាស្ថិតនៅក្រោមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងស្ថិតនៅក្រោម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ ក្នុងករណីដែលមានអធិបញ្ជាធ្វើការចោទប្រកាន់នោះព្រះរាជអាជ្ញា គឺត្រូវតែធ្វើតាមបញ្ជាថ្នាក់លើបានន័យថាទោះព្រះរាជអាជ្ញាមិនចង់ធ្វើការចោទប្រកាន់ក៏ដោយ បន្ទាប់ពីបញ្ជូនសំណុំរឿងដល់ចៅក្រមស៊ើបសួរហើយ ជាកិច្ចការបន្តរបស់ចៅក្រម។

ចៅក្រមស៊ើបសួរបើកការស៊ើបសួរតាមដីការសន្និដ្ឋានបញ្ជូនសំណុំរឿងរបស់ព្រះរាជអាជ្ញា។ ការស៊ើបសួររបស់ចៅក្រមមានទាំងការស៊ើបសួរដាក់បន្ទុកនិងដោះបន្ទុក។ ក្រោយ ពីការស៊ើបសួររួច ចៅក្រមស៊ើបសួរយល់ឃើញថា អង្គហេតុថ្មីនិងបទល្មើសថ្មី មិនមានក្នុង ដីការសន្និដ្ឋានរបស់ព្រះរាជអាជ្ញា នោះចៅក្រមស៊ើបសួរនឹងដាក់ស្នើរអោយព្រះរាជអាជ្ញាចេញដីការស៊ើបសួរបន្ថែម ។ ទោះការរៀបរាប់ខាងលើយ៉ាងនេះក្តីក៏ចៅក្រមស៊ើប

សួរមានការលំបាកដូចជាការប្តឹងនឹងសារលិខិតនីតិវិធីឬ ប្តឹងពីដីការសម្រេចរបស់ព្រះរាជអាជ្ញាជនត្រូវចោទដើម បណ្តឹងរដ្ឋប្បវេណីឬជនដែលពាក់ពន្ធ័សំណុំរឿងក្តីព្រហ្មទណ្ឌ មួយវិញទៀតនៅពេលដែលការតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណីចំពោះចៅក្រមស៊ើបសួរហើយចៅក្រមស៊ើបសួរ បានបញ្ជូនពាក្យបណ្តឹងនេះភ្លាមទៅព្រះរាជ អាជ្ញាដើម្បីពិនិត្យ និងធ្វើការចោទប្រកាន់តែករណីដែលព្រះរាជមិនចោទប្រកាន់តែចៅក្រមស៊ើបសួរនៅតែអាច បើកការស៊ើបសួរបាន។ក្រោយពីចៅក្រមស៊ើបសួរបានបញ្ចប់នៃកិច្ចនីតិវិធីស៊ើបសួរ ចៅក្រមស៊ើបសួរក៏ត្រូវបញ្ជូន ព័ត៌មានឬដំណឹងទៅព្រះរាជអាជ្ញា ឬគ្រប់ភាគីនៅក្នុងសំណុំរឿង បើព្រះរាជអាជ្ញាយល់ឃើញថាការស៊ើបសួរនោះ គ្រប់ជ្រុងជ្រោយរួចរាល់ហើយព្រះរាជអាជ្ញានឹងធ្វើដីការសន្និដ្ឋានជាស្ថាពរ ១៥ថ្ងៃ ក្នុងករណីជនត្រូវចោទ នៅក្នុង ឃុំ១ខែ និងជនត្រូវចោទនៅក្រៅឃុំ ។ បន្ទាប់ពីចៅក្រម ស៊ើបសួរបានទទួលសំណុំពីព្រះរាជអាជ្ញា និងភ្ជាប់ ជាមួយដីកាសន្និដ្ឋានជាស្ថាពរ កិច្ចបន្ទាប់ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទាំងមូលទៅចៅក្រមជំនុំជម្រះ ។ ក្រោយពីទទួលបាន សំណុំរឿងហើយចៅក្រមជំនុំជម្រះ បើកសវនាការជំនុំជម្រះក្តីតែម្តង ។ សេចក្តីសម្រេចរបស់ ចៅក្រមជំនុំជម្រះអាចជាការផ្តន្ទាទោសលើជនត្រូវចោទ ឬត្រូវរួចផុតពីការចោទប្រកាន់។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើសេចក្តីសន្និដ្ឋានរួចមកយើងឃើញថា ការអនុវត្តច្បាប់ក៏ដូចជាកិច្ចអនុវត្តនីតិវិធីក្នុងដំណើររឿងក្តីព្រហ្មទណ្ឌ គឺប្រព្រឹត្តទៅដោយរលូន និងប្រទាក់ក្រឡាគ្នារហូតដល់ចប់នីតិវិធី។ ក៏ប៉ុន្តែក្នុងនោះផងដែរក៏មានបញ្ហាក្នុងកិច្ចនៃនីតិវិធីមួយចំនួននូវមានចំណុចអសកម្មពាក់ព័ន្ធនឹងបច្ចេកទេស ស្ថាប័ន និងការរួមសហការ ដែលជាហេតុធ្វើឲ្យមានចន្លោះប្រហោងនិងយឺតយ៉ាវក្នុងការបំពេញការងារ។ ដើម្បីជាការរួមចំណែកធ្វើឲ្យកាន់តែប្រសើរឡើង ក្នុងវិស័យយុត្តិធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា យើងខ្ញុំដែលជានិស្សិតច្បាប់សូមចូលរួមចំណែកផ្តល់នូវអនុសាសន៍ដូចជា ត្រូវបំពេញនូវកង្វះខាត ឧបករណ៍បច្ចេកទេស និងមធ្យោបាយប្រើប្រាស់ដែលយើងឃើញថាការងារមួយចំនួន មានភាពចន្លោះប្រហោងនៅពេលចូលអន្តរាគមន៍ ការងារស៊ើបអង្កេត និងការបង្ក្រាបមិនទាន់បានឆ្លើយតបទៅតាមសំណូមពរនៅឡើយ។ ជាពិសេសគឺគ្រប់គ្រងមូលដ្ឋានដូចជា ក្មេងទំនើង ការប្រើប្រាស់គ្រឿងញៀន មុខសញ្ញាមានដីកាចាប់ខ្លួន មុខសញ្ញាសេសសល់ និងមុខសញ្ញាដោះលែងចេញពីពន្ធនាគារ។ មួយទៀតគឺពាក់ព័ន្ធនឹងការខ្វះ មធ្យោបាយ សម្ភារៈ និងថវិកា ដើម្បីបម្រើឲ្យកិច្ចសហប្រតិបត្តិការស្រាវជ្រាវ ធ្វើឲ្យការងារបង្ក្រាបបទល្មើសមិនទាន់ពេលវេលាជាដើម។ មួយទៀតអាចមានការពាក់ព័ន្ធនឹងអំពើពុករលួយដែលបណ្តាលឲ្យមានការចាប់ខ្លួនជនល្មើសបានហើយ តែមានការដោះលែងវិញដោយសារការស៊ីសំណូកសូកប៉ាន់ពីសំណាក់អ្នកអនុវត្តច្បាប់មួយចំនួន។

ដូចនេះដើម្បីឲ្យការបង្ក្រាបបទល្មើសមានភាពល្អប្រសើរនិងដំណើការដោះស្រាយរឿងក្តីព្រហ្មទណ្ឌមានភាពល្អប្រសើរយើងត្រូវមានឧបករណ៍បច្ចេកទេសគ្រប់គ្រាន់ បំបាត់ចោលនូវរាល់អំពើពុករលួយ លុបបំបាត់វប្បធម៌និទណ្ឌភាព បើមាននិទណ្ឌភាព គឺគ្មានទេភាពស្មើគ្នាចំពោះមុខច្បាប់។ ចំពោះការប្រលងជ្រើសរើសមន្ត្រីគឺដោយសមត្ថភាព និងមានចំណេះដឹងព្រមទាំងសីលធម៌ល្អ ជាពិសេសគឺកាបង្កើតតុលាការតាមមុខជំនាញដើម្បីឲ្យការដោះកាន់តែមានភាពល្អប្រសើរថែមទៀត។ហើយនិងការផ្សព្វផ្សាយច្បាប់ដល់ប្រជាជនឲ្យកាន់ទូលាយ។

# ឯកសារយោង

# ឯកសារយោង

-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

-ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

-សៀវភៅ នគរបាលយុត្តិធម៌របស់លោកគ្រូ កៅ សីហា

-សៀវភៅ នីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល អំណោយរបស់ស្ថានទូតបារាំង

-ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

-សៀវភៅ នីតិវិធីព្រហ្មទណ្ឌរបស់សាស្ត្រាចារ្យ អៀង សំណាង

-សៀវភៅ នីតិវិធីព្រហ្មទណ្ឌរបស់ សាស្ត្រាចារ្យ រុនពណ្ណារិទ្ធិ និងសាស្ត្រាចារ្យ ចាំង ស៊ីណាត

-ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា

https://m.facebook.com>permalink
http://www.isc.gov.kh

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៛

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

*លេខ៖*

# ដីកាបង្គាប់ឲ្យស៊ើបអង្កេតបឋម

+++++

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញរបាយការណ៍លេខ: .../១១ តពទ.បជ ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ របស់សាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ ។

-បានឃើញសុំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ ។

-បានឃើញមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាលឱ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧។

**សម្រេច**

**១**-បង្គាប់ឱ្យសាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ បើកការស៊ើបអង្កេតបឋម លើករណីឈ្មោះ ... ហើយឱ្យឈ្មោះ ... បង់ប្រាក់ពិន័យអន្តរកាលទៅតាមនីតិវិធី។

**២**-ពេលស៊ើបអង្កេតចប់បញ្ជូនសំណុំរឿងមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យវិញ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ ... ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តពោធិ៍សាត់

*សំណុំរឿងព្រហ្មទណ្ឌ*

*លេខ............*

*ចុះថ្ងៃទី ... ខែ... ឆ្នាំ២០១៦*

# កំណត់ហេតុស្តាប់ចម្លើយ

ឆ្នាំ ពីរពាន់ដប់ប្រាំមួយ ខែធ្នូ ថ្ងៃទីពីរ វេលាម៉ោង ដប់ និងសូន្យ នាទី។
យើង ...ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់ អមដោយលោកជាក្រឡាបញ្ជី ។
យើងបានស្តាប់ចម្លើយឈ្មោះ...ជាជនសង្ស័យដោយមានលោក...ជាមេធាវីការពារ។
បានមកបង្ហាញខ្លួន នៅចំពោះមុខយើង ដែលមានអត្តសញ្ញាដូចខាងក្រោម:

នាមត្រកូល ៖ ... នាមខ្លួន ៖ ...

ភេទ: ប្រុស

កើតថ្ងៃទី ៖ អាយុ ... ឆ្នាំ

ទីកន្លែងកំណើត ៖ភូមិ...ខេត្តពោធិ៍សាត់

អាសយដ្ឋាន ៖ភូមិ...ខេត្តពោធិ៍សាត់

មុខរបរ ៖ ...

សាសនា: ព្រះពុទ្ធ

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ... "រ" ម្តាយឈ្មោះ ៖ ... "រ"

អនីតិជន ☐ ឬ នីតិជន ☐

ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន

ជននេះ ៖ ☐ ចេះនិយាយ ☐ ចេះអាន ☐ ចេះសរសេរអក្សរខ្មែរ

ជននេះ ៖ ☐ មិនចេះនិយាយ ☐ មិនចេះអាន ☐ មិនចេះសរសេរអក្សរខ្មែរ

**សួរ-ឆ្លើយ៖** នៅថ្ងៃទី... ខែ... ឆ្នាំ២០១៦ វេលាម៉ោងប្រហែលជា២១ជាង មិត្តភក្តិរបស់ខ្ញុំមានគ្នាបីនាក់ ១.ឈ្មោះ ...២.... ៣.ឈ្មោះ ... ជិះម៉ូតូ០២គ្រឿងមកបបួលខ្ញុំនៅផ្ទះ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្ត
*បន្ទាយមានជ័យ*

កំណត់ហេតុស្រុះស្រួល

ឆ្នាំពីរពាន់ដប់ពីរ ខែ មេសា ថ្ងៃទី ពីរ វេលាម៉ោង ពីរ និង ដប់ នាទី នៅអយ្យការអម សាលាដំបូងខេត្តបន្ទាយមានជ័យ។

បានធ្វើការស្រុះស្រួលរវាងដើមចោទ និងជនជាប់សង្ស័យ ដូចតទៅ:

-ភាគីដើមចោទឈ្មោះ ... ភេទ ប្រុស អាយុ ... នៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ បានប្តឹងឈ្មោះ ... ភេទ ... ឲ្យប្រគល់ដី ស្រែចំនួន កន្លះហិចតា ឲ្យមកខ្លួនវិញ។

-ជនជាប់សង្ស័យឈ្មោះ ... ភេទ ... អាយុ ... ឆ្នាំ រស់នៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ បានស្រុះស្រួលជាមួយដើមបណ្តឹងដោយយល់ព្រមប្រគល់ដីស្រែចំនួន កន្លះ ហិចតា នេះស្ថិតនៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ ឲ្យដើមបណ្តឹងឈ្មោះ ... ដើម្បីគ្រប់គ្រង និងបានយល់ព្រមសងស្រូវទៅដើមបណ្តឹងវិញចំនួន ០៦ បាវ។

ការស្រុះស្រួលគ្នានេះ ដើមបណ្តឹងឈ្មោះ ... សុខចិត្តដកពាក្យបណ្តឹងឈប់ប្តឹងពីជនជាប់សង្ស័យឈ្មោះ ... វិញហើយ។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោង ពីរ និងហាសិប នាទី នាថ្ងៃ ខែ ឆ្នាំដដែល រួច បានអានឲ្យស្តាប់ ឆ្លើយថាត្រឹមត្រូវ និងយល់ព្រមផ្តិតមេដៃ និងចុះហត្ថលេខាទុកចំណាំ។

ដើមបណ្តឹង ជនជាប់សង្ស័យ

បានឃើញ
ថ្ងៃទី ខែ ... ឆ្នាំ ២០១២
ព្រះរាជអាជ្ញា

នៅភូមិ...ខេត្តពោធិ៍សាត់ ថាទៅដុតត្រីហុប ពេលនោះខ្ញុំនិងមិត្តភក្តិរៀបចេញដំណើរ ស្រាប់តែសមត្ថកិច្ចមកដល់ ហើយបានហៅពួកខ្ញុំទាំងបួននាក់ មកអធិការដ្ឋាននគរបាលក្រុងពោធិ៍សាត់ សមត្ថកិច្ចបានឆែកឆេរក្នុងម៉ូតូ របស់ខ្ញុំ ឃើញមានក្រដាសអាលុយមីញ៉ូម ហើយទុយយូមួយដើម និងពិនិត្យទឹកនោមខ្ញុំ ឃើញមានសារធាតុញៀន ។

**សួរ ឆ្លើយ៖** ខ្ញុំធ្លាប់ប្រើប្រាស់ថ្នាំញៀន ហើយប្រើប្រាស់លើកចុងក្រោយមុនថ្ងៃចាប់ខ្លួនពីរឬបីថ្ងៃ ប្រើម្នាក់ឯងក្នុងផ្ទះរបស់ខ្ញុំ។ថ្នាំញៀនដែលខ្ញុំប្រើប្រាស់នេះ ទិញពីឈ្មោះ ...ណាត់យកមកឲ្យនៅផ្លូវ...ខេត្តពោធិ៍សាត់ ទិញតំលៃ៣ម៉ឺនរៀល។

**សួរ ឆ្លើយ៖** ពួកម៉ាកបីនាក់ទៀត សមត្ថកិច្ចបានឆែកឆេរអត់ឃើញមានអីពាក់ ពន្ធ័បានឲ្យទៅផ្ទះវិញ ។

**សួរ ឆ្លើយ៖** ខ្ញុំមិនដែលរកស៊ីជួញដូរ និងចែកចាយថ្នាំញៀនទេ។

**សួរ ឆ្លើយ៖** នៅក្នុងថ្ងៃខែមិនចាំ ក្នុងឆ្នាំ... ពេលយប់មិនចាំម៉ោង ខ្ញុំបានជិះម៉ូតូម៉ាកស៊ីរុស អត់មានផ្លាកលេខ ចេញពីផ្ទះដើម្បីទៅទិញមីនិងបារីជក់ ពេលជិះមកដល់ស្ពានដែក (ផ្លូវរថភ្លើង) តាមផ្លូវមោត់ស្ទឹង ស្រាប់តែមានរថយន្តតូចមួយគ្រឿង បានជិះមកតៀរម៉ូតូរបស់ខ្ញុំបណ្តាលឲ្យដួល ហើយឃើញគេចុះពីលើឡានរួចស្រែកឲ្យខ្ញុំឈប់ ឃើញដូច្នេះខ្ញុំក៏រត់ចោលម៉ូតូ មកដេកផ្ទះ ។

**សួរ ឆ្លើយ៖** ពេលបាត់ម៉ូតូខ្ញុំមិនបានប្តឹងសមត្ថកិច្ចទេ ក្រោយមកលឺដំណឹងថាម៉ូតូរបស់ខ្ញុំ នៅប៉េអឹមហើយពាក់ពន្ធ័និងថ្នាំញៀន លឺដូចន្នេះខ្ញុំមិនហ៊ានទៅសុំម៉ូតូវិញទេ ព្រោះខ្លាចគេចោទ ថាជួញដូរថ្នាំញៀន ។

**សួរ ឆ្លើយ៖** ពេលខ្ញុំរត់ចោលម៉ូតូ ខ្ញុំមិនមានថ្នាំញៀនទេហើយថ្នាំញៀនដែលសមត្ថកិច្ចដកហូតបាន ខ្ញុំមិនដឹងថាជារបស់អ្នកណាឡើយ ។

*បញ្ចប់កំណត់ហេតុវេលាម៉ោង ដប់ និង សែសិបប្រាំនាទី នាថ្ងៃ ខែ ឆ្នាំ ដដែល។*

យើងបានប្រាប់ជននេះឱ្យអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុង កំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ផ្តិតស្រាមដៃលើកំណត់ហេតុនេះ ។

បានអានចប់សព្វគ្រប់ ហើយជននេះមិនមានបដិសេធចំណុចណាទេ និង ចុះហត្ថលេខា ឬ ផ្តិតស្រាម ដៃជាមួយយើង ។

| | | |
|---|---|---|
| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូង ខេត្តពោធិ៍សាត់**

*សំណុំរឿងព្រហ្មទណ្ឌលេខ ...*

*ចុះថ្ងៃទី ... ខែ ... ឆ្នាំ...*

**ដីកាកោះ**

*យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់*

*បង្គាប់មកឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំ ជាសាក្សី ។*

*ទីលំនៅបច្ចុប្បន្ននៅភូមិ...ខេត្តពោធិ៍សាត់ ។*

*ឱ្យចូលទៅកាន់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់*

*នៅវេលាម៉ោង២០០ រសៀល ថ្ងៃទី ... ខែ... ឆ្នាំ... ។*

*ដើម្បី* ***សួរយកចម្លើយ***

*ពីដំណើររឿង* ***បង្ក្រាបបទល្មើសព្រៃឈើ កាលពីថ្ងៃទី ... ខែ... ឆ្នាំ ... នៅ ចំណុច...ភូមិ...ខេត្តពោធិ៍សាត់។***

*សាមី*

*ខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងរឿង ខាងលើ មកជាមួយផងប្រសិនបើមាន។*

*ធ្វើនៅពោធិ៍សាត់, ថ្ងៃទី ... ខែ ... ឆ្នាំ ...*

**ព្រះរាជអាជ្ញារង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការ អម

សាលាដំបូងខេត្ត ពោធិ៍សាត់

លេខ..................

# លិខិតជូនដំណឹង

យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

សូមជូនដំណឹងលោក ... អាយុ ... ឆ្នាំ មានទីលំនៅ ភូមិ.... ឃុំ... ស្រុក... ខេត្តបាត់ដំបង អោយបានជ្រាបថា:

ពាក្យបណ្តឹងរបស់លោក ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៣ ដែលបាន ប្តឹងលោក ... អាយុ...ឆ្នាំមានទីលំនៅភូមិ... ឃុំ... ស្រុក... ខេត្តកំពង់ឆ្នាំង ថា: **បានបង្កគ្រោះថ្នាក់ចរាចរណ៍** ប្រព្រឹត្តនៅភូមិ... ឃុំ... ស្រុក... ខេត្តពោធិ៍សាត់ ដែលមានសំណុំរឿងព្រហ្មទណ្ឌ លេខ:... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៣ នោះត្រូវបានតំណាងអយ្យការតម្កល់រឿងទុកឥតចាត់ការ តាមដីការតម្កល់រឿងទុកឥតចាត់ការ លេខ:... អយ/១៦ ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ ហើយ សូមលោកជ្រាប។

លោកមានសិទ្ធិប្តឹងតវ៉ារយៈពេលពីរខែគិតចាប់ពីថ្ងៃលោកបានទទួលដំណឹងនេះ។

ពោធិ៍សាត់, ថ្ងៃទី... ខែ... ឆ្នាំ ២០១៦

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ.........................

# ដីកាតម្កល់រឿងទុកឥតចាត់ការ

យើង ............តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ...................ចុះថ្ងៃទី........ខែ.........ឆ្នាំ២០១.....
.របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា។

**១- អវត្តមានបទល្មើស**

☐ ១.១. អវត្តមានបទល្មើស

**២- ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់**

☐ ២.១. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

**៣- មូលហេតុគតិយុត្ត**

☐ ៣.១. ការដកពាក្យបណ្តឹង

☐ ៣.២. ការលើកលែងទោសជាទូទៅ

☐ ៣.៣. មរណភាពជនល្មើស

☐ ៣.៤. ផុតអាជ្ញាយុកាល

☐ ៣.៥. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

☐ ៣.៦. អាជ្ញាអស់ជំនុំ

☐ ៣.៧. ការសម្របសម្រួលជាមួយរដ្ឋ

☐ ៣.៨. ការបង់ប្រាក់ពិន័យសរុប ឬពិន័យសម្របសម្រួល

☐ ៣.៩. អភ័យឯកសិទ្ធ

☐ ៣.១០. អនិយ័តភាពនៃនីតិវិធី

☐ ៣.១១. ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

**៤- ការចោទប្រកាន់មិនផ្តល់ប្រយោជន៍**

☐ ៤.១. ការស្វែងរកមិនបានផល

☐ ៤.២. ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[2]

☐ ៤.៣ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

☐ ៤-៤ ការខកខានរបស់ដើមបណ្តឹង

☐ ៤.៥. អាកប្បកិរិយារបស់ជនរងគ្រោះ

☐ ៤.៦. ជនរងគ្រោះមិនចាប់អារម្មណ៍ នឹងបទល្មើស

☐ ៤.៧. និយ័តកម្មដោយឯកឯង[3]

☐ ៤.៨. ព្យសនកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើស

**៥- នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា**

☐ ៥.១. ការជួសជុលការខូចខាតដោយ/ដល់អនីតិជន

☐ ៥.២. សន្ធានកម្ម[4]

☐ ៥.៣. អចិបញ្ញាផ្តល់ការព្យាបាល

☐ ៥.៤. ជនរងគ្រោះ/ដើមបណ្តឹងបោះបង់បណ្តឹង
តាមការស្នើសុំរបស់ព្រះរាជអាជ្ញា

☐ ៥.៥. និយ័តកម្មតាមសំណើររបស់ព្រះរាជអាជ្ញា

☐ ៥.៦. ការរំលឹកពីអត្ថបទច្បាប់/ការព្រមាន[5]

☐ ៥.៧. ការកំណត់ទិសដៅចំពោះរចនាសម្ព័ននៃសុខភាព នៃសង្គម ឬវិជ្ជាជីវៈ

☐ ៥.៨. ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

**៦- នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗ**

---

[1] ) ដូចជាមូលហេតុ វិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

[2] ) ដើមបណ្តឹងឈប់ប្តឹង

[3] ) សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និង ស្តារស្ថានភាពឡើងវិញ

[4] ) ករណីចែងដោយច្បាប់

[5] ) ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើស តាមកំណត់ច្បាប់ និងធ្វើការព្រមានឲ្យឈប់ប្រព្រឹត្ត

[6] ) ករណីចែងដោយច្បាប់

☐ ៦.១. ការចោទប្រកាន់ ឬទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

**៧-ជនល្មើសមិនត្រូវបានស្គាល់**

☐ ៧.១. ជនល្មើសមិនត្រូវបានស្គាល់

**៨-ជំនួយការអប់រំ**

☐ ៨.១. ការផ្តល់ជំនួយការអប់រំជំនួសការចោទប្រកាន់

**ការអង្កេតផ្សេងៗ ៖**កាលពីថ្ងៃទី.........................................................................................

...................................................................................................................................................

...........................................................................................................................................

**បានឃើញ:**

-កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងឈ្មោះ

-កំណត់ហេតុស្តាប់ចម្លើយជនសង្ស័យឈ្មោះ ។

-ពាក្យស្នើសុំដកបណ្តឹងរបស់ឈ្មោះ ចុះថ្ងៃទី ............ខែ ............ ឆ្នាំ ............។

**យល់ឃើញថា:**

-តាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ

**ហេតុដូច្នេះ សម្រេច**

-តម្កល់រឿងព្រហ្មទណ្ឌលេខ ............ ថ្ងៃទី ..... ខែ ............ ឆ្នាំ ............ ទុកឥតចាត់ការតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី... ខែ....... ឆ្នាំ........

**ព្រះរាជអាជ្ញារង**

អយ្យការអម
សាលាដំបូងខេត្ត
ពោធិ៍សាត់
លេខ៖

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

យើង ............ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០ ។

បានឃើញមាត្រា ៤៣ និង ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជ ក្រមលេខៈ នស/រ កម ០៨ ០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

ក្រោយពីបានពិនិត្យឯកសារខាងលើ

**ឃើញថា ៖**

១-នាមត្រកូលនាមខ្លួន ៖ ភេទ សញ្ជាតិ ៖ ខ្មែរ
កើតថ្ងៃទីខែឆ្នាំ ៖
ទីកន្លែងកំណើត ៖ភូមិ ឃុំ ស្រុក ខេត្ត
អាស័យដ្ឋានសព្វថ្ងៃៈភូមិ ឃុំ ស្រុក ខេត្ត
មុខរបរ ៖ ប្តីឬប្រពន្ធឈ្មោះ ៖ កសិករ
ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖ "រ"
អនីតិជន☐ ឬ ☐ នីតិជន

**ឃើញថាៈ**

កាលពីថ្ងៃទី ខែ ឆ្នាំ ២០១៨

ពីបទៈ ដែលល្មើសមាត្រា នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

-ឯកសារនានាទាក់ទងសំណុំរឿង លេខៈ ចុះថ្ងៃទី ខែ ឆ្នាំ ២០១៨ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ

-តាមរបាយការណ៍លេខៈ

**យល់ឃើញថាៈ**

-

-អង្គហេតុខាងលើ មានលក្ខណៈមូលសព្វគ្រប់ និងភស្តុតាងដែលប្រមូលបានអាចកំណត់អំពីធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ហេតុ ដូច្នេះគប្បីសម្រេចបញ្ជូនសំណុំរឿងនេះដោយផ្ទាល់ទៅសាលាដំបូង ខេត្ត បន្ទាយមានជ័យ ដើម្បីជំនុំជម្រះតាមច្បាប់ជាធរមាន។

**ហេតុដូច្នេះសម្រេច ៖**

**បញ្ជូនជនជាប់ចោទ** ឈ្មោះ ភេទ អាយុ ឆ្នាំ ពីបទៈ ដែលល្មើសមាត្រា ប្រព្រឹត្តនៅភូមិឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ខែ ឆ្នាំ ២០១៨។**ទៅសាលាដំបូងខេត្ត បន្ទាយមានជ័យ ដើម្បីជំនុំជម្រះ តាមនីតិវិធីកោះហៅបញ្ជូនទៅជំនុំជំម្រះផ្ទាល់ ចំពោះអង្គហេតុខាងលើ ។**

បន្ទាយមានជ័យ ថ្ងៃទី ខែ ឆ្នាំ ២០១

**ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្ត
*ពោធិ៍សាត់*
*លេខ៖..........*

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង ........... តំណាងអយ្យការអម សាលាដំបូងខេត្ត ពោធិ៍សាត់
បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ .... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១...
បានឃើញរបាយការណ៍របស់អធិការដ្ឋាននគរបាលស្រុកក្រគរ លេខ: ...
ចុះថ្ងៃទី... ខែ... ឆ្នាំ២០១... ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា មាននតម្រុយសន្មតបានថា:**

១-នាមត្រកូល ៖ ... នាមខ្លួន ...........ហៅតា ភេទ...
អាយុ ៖ ....ឆ្នាំ
ទីកន្លែងកំណើត៖ ..........................................................................
អាសយដ្ឋាន ៖ ..........................................................................
មុខរបរ ៖ ...
☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ..............
សញ្ជាតិ ៖ ខ្មែរ
ឪពុកឈ្មោះ ៖........... "ស" ម្ដាយឈ្មោះ ៖ ........... "ស"
អនីតិជន ☐ ឬ នីតិជន ☐

២-នាមត្រកូល ៖........... នាមខ្លួន ........... ភេទ...........
អាយុ ៖ ............ឆ្នាំ
ទីកន្លែងកំណើត៖ ..........................................................................
អាសយដ្ឋាន៖ ......................................................................
មុខរបរ ៖ ............
☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ...........

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ........... "ស" ម្តាយឈ្មោះ ៖ ........... "ស"

អនីតិជន ☐ ឬ នីតិជន ☐

៣-នាមត្រកូល ៖ ........... នាមខ្លួន ........... ភេទ...........

អាយុ ៖ ...........ឆ្នាំ

ទីកន្លែងកំណើត៖ ...........................................................................

អាសយដ្ឋាន ៖ ...........................................................................

មុខរបរ ៖ ...........

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ...........

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ........... "ស" ម្តាយឈ្មោះ ៖ ........... "ស"

អនីតិជន ☐ ឬ នីតិជន ☐

## បានប្រព្រឹត្តអំពើដូចតទៅ ៖

កាលពីថ្ងៃទី........... ខែ...........ឆ្នាំ........... វេលាម៉ោង...........និង...........នាទី មានបទល្មើស........... ........... ...........នៅតំបន់........... ........... ស្ថិតនៅភូមិ...........ឃុំ...........ស្រុក........... ខេត្តពោធិ៍សាត់ បង្កឡើងដោយជនសង្ស័យចំនួន០៧នាក់ ១.ឈ្មោះ...........ភេទ........... អាយុ ...........ឆ្នាំ ជា...........២.ឈ្មោះ ........... ភេទ........... ហៅ........... ភេទ........... អាយុ ...........ឆ្នាំ ៣.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ ៤.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ ៥.ឈ្មោះ ........... ភេទ........... អាយុ...........ឆ្នាំ ៦.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ ៧.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ។ ពេលទទួលបានបណ្តឹងពីប្រជាពលរដ្ឋ លោកអធិការបានបញ្ជាឲ្យលោកអធិការរងទទួលផែនការយុត្តិធម៌ ដឹកនាំផ្នែកជំនាញ ដោយសហការជាមួយប៉ុស្តិ៍........... ចុះទៅកន្លែងកើតហេតុដើម្បីធ្វើការស្រាវជ្រាវ បន្ទាប់ពីទៅដល់កន្លែងកើតហេតុលោកអធិការរងទទួលផែនការយុត្តិធម៌ ដឹកនាំផ្នែកជំនាញ និងប៉ុស្តិ៍........... ធ្វើការស្រាវជ្រាវកំណត់មុខសញ្ញា ។លុះដល់ថ្ងៃទី........... ខែ........... ឆ្នាំ........... កំលាំងអធិការដ្ឋាននគរបាលស្រុក........... ធ្វើការឃាត់ខ្លួន ១.ឈ្មោះ........... ភេទ........... អាយុ ...........

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងខេត្ត
*ពោធិ៍សាត់*
*លេខ៖*

## ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបទល្មើសថ្មីបន្ថែម

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ ។

-បានឃើញនីតិវិធីស៊ើបសួរលើឈ្មោះ ... ឈ្មោះ... និង ឈ្មោះ...ជាជនត្រូវចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៥០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិ... ខេត្តពោធិ៍សាត់ និង នៅខណ្ឌ... ក្រុង ... កាលពីថ្ងៃទី... ខែ ... ឆ្នាំ ២០១៦។

**ឃើញថាអង្គហេតុ:** តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ... បានឆ្លើយសារភាពថា ៖ កាលពីអំឡុង ខែ... ឆ្នាំ២០១៥ខ្លួនធ្លាប់បានទៅទិញថ្នាំញៀនពីឈ្មោះ ... ហៅ ... ចំនួនពាក់កណ្តាលកន្លះជ្រុង តម្លៃ១២០០០០០រៀល(មួយលានពីរសែនរៀល) ហើយឈ្មោះ...យកថ្នាំមកធនៅភូមិរលោប សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។ នៅអំឡុង ខែ... ឆ្នាំ២០១៥ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ... ចំនួនកន្លះហ៊ុន នៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។ នៅអំឡុងខែ... ឆ្នាំ២០១៥ខ្លួនបានទៅទិញថ្នាំញៀនពីឈ្មោះ... ចំនួនមួយហ៊ុន ហើយឈ្មោះ...យកថ្នាំមកធនៅភូមិ ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់។ នៅចុងខែ... ឆ្នាំ២០១៥ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ... ចំនួនមួយជ្រុង តម្លៃ៧០០ដុល្លា (ប្រាំពីររយ) ទិញនៅភូមិ... សង្កាត់.... ក្រុង... ខេត្តពោធិ៍សាត់។

☐ ដែលត្រូវបានចៅក្រមស៊ើបសួររកឃើញ ហើយបានជូនដំណឹងតាមលិខិតលេខ... ចុះថ្ងៃទី ... ខែ... ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរ និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ ។

-បានឃើញលិខិតជូនដំណឹងលេខ... ចុះថ្ងៃទី ...ខែ... ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរ ស្តីពីលេចចេញនូវអង្គហេតុថ្មី។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា មានតម្រុយសន្មតបានថា:**

១-នាមត្រកូល ៖... នាមខ្លួន ៖ ហៅ ... ភេទ ប្រុស

កើតថ្ងៃទី ៖

ទីកន្លែងកំណើត ៖

អាសយដ្ឋាន ៖ ភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់

មុខរបរ ៖

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖

សញ្ជាតិ ៖ ខ

ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖

អនីតិជន☐ ឬ នីតិជន ☐

២-នាមត្រកូល ៖ ... នាមខ្លួន ៖ ភេទ ប្រុស

កើតថ្ងៃទី ៖

ទីកន្លែងកំណើត ៖

អាសយដ្ឋាន ៖ ភូមិ

មុខរបរ ៖

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖

អនីតិជន☐ ឬ នីតិជន ☐

៣-នាមត្រកូល ៖ ... នាមខ្លួន ៖ ភេទ ប្រុស

កើតថ្ងៃទី ៖

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តពោធិ៍សាត់

*លេខ៖*

## ដីកាស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម

យើង ... តំណាងអយ្យការអមសាលាដំបូងខេត្ត ពោធិ៍សាត់។

-បានឃើញមាត្រា ២៤៦ និង ១៣២នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសអោយប្រើ

-តាមព្រះរាជក្រមលេខ នស. រកម . ០៨០៧.០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី... ខែ ... ឆ្នាំ ២០១៥។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ ២០១៥។

**ដែលបានបើកការស៊ើបសួរលើ:**

១-ឈ្មោះ ... ភេទ ប្រុស អាយុ...ឆ្នាំ

២-អញ្ញាតជន

ពីបទ៖ អំពើលួច ,ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៣៥៣ ,៣៥៦នៃក្រមព្រហ្មទណ្ឌ និងតាមមាត្រា៨៥ ,៨០នៃច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន ។

ប្រព្រឹត្តិនៅសង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី... ,ទី...ខែ.... ឆ្នាំ២០១៥។

**បានឃើញ** ៖ដីកាបញ្ជូនអោយឆ្លើយដើម្បីបិទបញ្ចប់ការស៊ើបសួរលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ។

## យល់ឃើញថា:

-ដីកាសន្និដ្ឋានបញ្ជូនរឿងទសើុបសួរលេខ ... ចុះថ្ងៃទី...ខែ..។ ឆ្នាំ២០១៥ បានបើក ការស៊ើបសួរលើ អញ្ញាតជន ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិ... សង្កាត់...ក្រុង... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី... ខែ... ឆ្នាំ០១៥។

- ចៅក្រមស៊ើបសួរពុំទាន់បានបំពេញកិច្ចស៊ើបសួរ រកសាវតាជាតិរបស់អញ្ញាតជន នៅឡើយ

## ហេតុដូច្នេះសម្រេច

១-ស្នើសុំឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរបន្ថែម ៖

-បំពេញកិច្ចស៊ើបសួររកសាវតាជាតិរបស់ជនត្រូវចោទ (អញ្ញាតជន) ទៅតាមនីតិវិធ

២-បញ្ជូនសំណុំរឿងលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ ២០១៥ ទៅចៅក្រមស៊ើបសួរដើម្បី បំពេញកិច្ចស៊ើបសួរបន្ថែម។

ធ្វើនៅពោធិ៍សាត់ ថ្ងៃទី ខែ ... ឆ្នាំ ២០១៦

**តំណាងអយ្យការ**

អយ្យការ អម

សាលាដំបូងខេត្តបន្ទាយមានជ័យ

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ដីកាសន្និដ្ឋានសុំជល់ចៅក្រមស៊ើបសួរកុំឲ្យស៊ើបសួរ

យើង ...តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ:...ចុះថ្ងៃទី...ខែ ...ឆ្នាំ ២០១២របស់ អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ មាត្រា១៣៧ មាត្រា១៣៨ និង មាត្រា ១៣៩នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណា ចក្រកម្ពុជា។

-បានឃើញ ដីកាសម្រេចលេខៈ...ព.ស/ព្រ.ទ ចុះថ្ងៃទី... ខែ... ឆ្នាំ២០១២របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ លើពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។

## ក្រោយពីបានពិនិត្យឯកសារខាងលើ:

០១-នាមត្រកូល និងនាមខ្លួន: ...
ភេទប្រុស អាយុ ...ឆ្នាំ សញ្ជាតិ...
ទីកន្លែងកំណើត: ខេត្ត...
ទីលំនៅបច្ចុប្បន្ន: ភូមិ...ខេត្តបន្ទាយមានជ័យ
មុខរបរ: នៅផ្ទះ (ចាស់ជរា) សាសនា ព្រះពុទ្ធ
ប្រពន្ធឈ្មោះ ... (ស្លាប់)
ឪពុកឈ្មោះ ... (ស) ម្ដាយឈ្មោះ ... (ស)
នីតិជន ☑ ឬអនីតិជន ☐

០២-នាមត្រកូល និងនាមខ្លួន: ...
ភេទប្រុស កើតថ្ងៃទី ... ខែ... ឆ្នាំ ... សញ្ជាតិខ្មែរ
ទីកន្លែងកំណើត: ភូមិ...ខេត្តស្វាយរៀង
ទីលំនៅបច្ចុប្បន្ន: ភូមិ... ខេត្តបន្ទាយមានជ័យ
មុខរបរ: ...សាសនា ព្រះពុទ្ធ
ប្រពន្ធឈ្មោះ ...

ឪពុកឈ្មោះ ... (ស) ម្តាយឈ្មោះ ... (រ)
និតិជន ☑ ឬអនីតិជន □

**ការសង្កេតផ្សេងៗ៖**

កាលពីថ្ងៃទី ...ឈ្មោះ ...ហៅ ...ភេទប្រុស បានមកដាក់ពាក្យប្តឹងនៅ អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ដោយប្តឹងឈ្មោះ ...ថា៖ បានធ្វើ និង ប្រើប្រាស់នូវឯកសារក្លែងក្លាយលើពាក្យស្នើ សុំដីស្រែ ចុះថ្ងៃទី...ខែ... ឆ្នាំ១...ដើម្បីយកមកធ្វើជាឯកសារយោងសំរាប់ចេញប័ណ្ណសំគាល់សិទ្ធកាន់កាប់ អចលនវត្ថុហើយ នៅក្នុងនោះមានឈ្មោះ ...ជាមេឃុំ... បានចូលរួមបញ្ជាក់ និងប្រព្រឹត្តអំពើក្លែងឯកសារនេះ ផងដែរ។ លុះថ្ងៃទី... ខែ... ឆ្នាំ... ឈ្មោះ ...ហៅ ...បានមកដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹង
រដ្ឋប្បវេណីតាមផ្លូវអន្តរាគន៍ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៖... ចុះថ្ងៃទី... ខែ ... ឆ្នាំ... មក ចៅក្រមស៊ើបសួរ ។

**យល់ឃើញថា:**

-ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី
តាមផ្លូវអន្តរាគមន៍ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ៖
... ចុះថ្ងៃទី...ខែ...ឆ្នាំ២... របស់ឈ្មោះ ...ហៅ
...បានប្តឹងមកចៅក្រមស៊ើបសួរហើយតាមរយៈដីកាសម្រេចលើ
ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលេខ៖... ចុះថ្ងៃទី... ខែ...ឆ្នាំ...
របស់ចៅក្រមស៊ើបសួរបានបញ្ជូនមក
អយ្យការដើម្បីអោយតំណាងអយ្យការធ្វើការពិនិត្យនិងសម្រេច។
បន្ទាប់ពីតំណាងអយ្យការទទួលបានពាក្យ បណ្តឹងសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ ...ហៅ......តាមដីកាបញ្ជូនលេខ៖ ...រប/សលជ.បជ ចុះថ្ងៃទី ... ខែ... ឆ្នាំ ... របស់សាលាដំបូងខេត្តបន្ទាយមានជ័យ និងក្រោយពីបានអង្កេតបឋមរួចរាល់តំណាងអយ្យការបានសម្រេចតម្កល់រឿងទុកឥតចាត់ការលើសំណុំរឿងព្រហ្មទណ្ឌ លេខ ៖ ... ចុះថ្ងៃទី ... ខែ ...ឆ្នាំ ... របស់ អយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យ ដោយមូលហេតុផុតអាជ្ញាយុកាលនៃបទល្មើសតាមដីកា លេខ៖... ចុះថ្ងៃទី... ខែ ...ឆ្នាំ...របស់អយ្យការអមសាលាដំបូងខេត្ត បន្ទាយមានជ័យ។

-តាមមាត្រា ១៣៩ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា) វាក្យខ័ណ្ឌ៣ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជ អាជ្ញា អាចសុំ ដល់ ចៅក្រមស៊ើបសួរ កុំអោយស៊ើបសួរ លើពាក្យបណ្តឹងសុំតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី របស់ឈ្មោះ...ហៅ ...ដោយហេតុថា៖ នៅក្នុងពាក្យបណ្តឹងរបស់ឈ្មោះ...បានប្តឹង ពីឈ្មោះ...និង ឈ្មោះ.. ថាបានក្លែងដោយសិកសៀតអក្សរលើពាក្យ ស្នើ សុំ ដីស្រែ របស់ ឈ្មោះ...ចុះថ្ងៃ ទី... ខែ ... ឆ្នាំ ...

ដែលពាក្យស្នើសុំនេះកើតមានឡើងតាំងពី ឆ្នាំ..... មកម្ល៉េះ ដោយយោងតាមមាត្រា ៦១០ នៃក្រមនីតិវិធី ព្រហ្មទណ្ឌបានចែងថា៖ "អាជ្ញាយុកាលនៃ បណ្ដឹង អាជ្ញា និង អាជ្ញាយុកាលនៃទោស ចំពោះបទល្មើស ដែលត្រូវបានប្រព្រឹត្ត នៅមុនក្រម នេះចូលជា ធរមាន ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃច្បាប់ចាស់" ហេតុនេះ អាជ្ញាយុកាលនៃបទល្មើសត្រូវអនុវត្តតាមច្បាប់ព្រហ្មទណ្ឌអន្តរកាល។ តាមមាត្រា៣០នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាលបានចែងថា" អាជ្ញាយុកាលសំរាប់បទមជ្ឈឹមមានរយះពេល០៣ឆ្នាំ រីឯអាជ្ញាយុកាលសំរាប់បទ ឧក្រិដ្ឋមានរយះពេល១០ឆ្នាំ" ដូចនេះនាំអោយផុតអាជ្ញាយុកាលនៃបទល្មើស ព្រោះថា បើគិតរយះពេល ពីឆ្នាំ១៩៩៥មកដល់ថ្ងៃដែល ឈ្មោះ ...ហៅ ... បានដាក់ពាក្យប្តឹងគឺមានរយះពេល១៦ឆ្នាំហើយ (ប្រសិនបើមើលទៅមាត្រា ១០ នៃក្រមនីតិវិធី ព្រហ្មទណ្ឌវិញ ចិរវេលានៃអាជ្ញាយុកាលនៃបណ្ដឹងអាជ្ញា១៥ ឆ្នាំចំពោះបទឧក្រិដ្ឋ ចំណែកឯ បទមជ្ឈិម រយះ ពេល ៥ឆ្នាំ ដូចនេះបើតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ អាជ្ញាយុកាលនៃបទល្មើសក៏បានផុតហើយដែរ)កន្លងមក ឈ្មោះ ... ហៅ ... ពុំបានប្តឹងតវ៉ាអំពីការក្លែងលិខិតនេះដែរ ហេតុនេះ ចេរវេលា នៃ អាជ្ញាយុកាល នៃបណ្ដឹងអាជ្ញាបានផុតហើយ គប្បីរំលត់បណ្ដឹងអាជ្ញា (តាមមាត្រា ៧នៃ ក្រ.ន.ព្រ)។

## ហេតុដូច្នេះសម្រេច

-ស្នើសុំដល់ចៅក្រមស៊ើបសួរ

កុំអោយស៊ើបសួរលើពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី តាមផ្លូវអន្តរាគមន៍ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១២ របស់ឈ្មោះ...ហៅ...ដែលបាន ចុះនៅក្នុង សំណុំរឿងព្រហ្មទណ្ឌ លេខ ៖ ...ចុះថ្ងៃទី ... ខែ ...ឆ្នាំ ២... របស់អយ្យការអមសាលាដំបូងខេត្ត - បន្ទាយមាន ជ័យ ដោយ មូលហេតុនៃការផុតរំលត់អាជ្ញាយុកាលនៃបទល្មើស។

ធ្វើនៅ បន្ទាយមានជ័យ, ថ្ងៃទី ខែ ...ឆ្នាំ ...

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្ត បន្ទាយមានជ័យ**

**លេខ:**

## តំណាងអយ្យការអមសាលាដំបូងខេត្ត បន្ទាយមានជ័យ

**<u>សូមគោរពជូន</u>**

## ឯកឧត្តមអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍

**<u>កម្មវត្ថុ:</u>** របាយការណ៍បណ្ដឹង ឧទ្ធរណ៍ នឹងដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នលេខ: ... ចុះថ្ងៃទី ...

ខែ ... ឆ្នាំ ២០១៤។

**<u>យោង:</u>** -សំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី... ខែ ... ឆ្នាំ ២០១៤ ។

-ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤ ។

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំសូមជំរាបជូន ឯកឧត្តម មេត្តាជ្រាបថា: លោកចៅក្រម ស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចមិនឃុំខ្លួនជនត្រូចចោទឈ្មោះ ... ដែលដាក់ ឲ្យស្ថិតនៅក្រោមការពិនិត្យ ពីបទ:អំពើហិង្សាដោយចេតនា(ស្ថានទម្ងន់ទោស) តាមដីកាសំរេចលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤ តំណាងអយ្យការមិនយល់ស្របដោយសំអាងថា:

-តាមចម្លើយរបស់ដើមបណ្ដឹងឈ្មោះ ... និងចម្លើយសាក្សីឈ្មោះ ... .ឈ្មោះ... ឈ្មោះ ... .ឈ្មោះ ... .ឈ្មោះ ... មានភាពស៊ីសង្វាក់គ្នាបញ្ជាក់ថា:កាលពីថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤ នៅចំណុចភូមិ... សង្កាត់... ក្រុង... ខេត្តបន្ទាយមានជ័យ មានការទាស់គ្នា រវាងក្រុមជនរងគ្រោះ និងក្រុមជនត្រូវចោទ ឈ្មោះ ... មានការវាយ និងកាប់ចាក់គ្នា ដោយពេលទាស់គ្នានោះជនត្រូវចោទឈ្មោះ ... បានយកកាំបិត ចាក់ទៅលើជនរងគ្រោះឈ្មោះ ... ហើយជនរងគ្រោះឈ្មោះ ... បានយកដៃរងបណ្ដាលឲ្យមុតដៃតែម្ដង មិនមែនជនរងគ្រោះដួលទៅប៉ះ កាំបិទដែលជនត្រូវចោទកាន់ បណ្ដាលឲ្យរបួស ដូចចម្លើយរបស់ជនត្រូវ ចោទឆ្លើយដោះសារនោះទេ ។

-ការប្រព្រឹត្តរបស់ជនត្រូវចោទមានបក្សពួកជាក្រុម និងមានអាវុធ បណ្តាលឲ្យប៉ះពាល់ដល់ សន្តិសុខសណ្តាប់ធ្នាប់សង្គម និងព្យសនៈកម្មធ្ងន់ធ្ងរ។

-ជនត្រូវចោទជាកម្មករ មានទីលំនៅមិនច្បាស់លាស់ ការសម្រេចមិនឃុំខ្លួន ជនត្រូវចោទនិង មិនចូលមកបង្ហាញខ្លួនទៅតាមនីតិវិធីឡើយ ។

-ជនត្រូវចោទជាកម្មករ មានបក្សពួកច្រើន ជាក្រុមទំនើងការមិនឃុំខ្លួន ជនត្រូវចោទអាចនិងទៅបង្កបទល្មើសជាថ្មីទៀត។

-ជនត្រូវចោទប្រព្រឹត្តបទល្មើសមានគ្នាច្រើន ការអោយជនត្រូវចោទនៅក្រៅឃុំអាចត្រូវវត្ថារវាងជនត្រូវចោទ និងជនត្រូវចោទ ធ្វើឲ្យបាត់ភស្តុតាង និងអាចជនត្រូវចោទទៅគាបសង្កត់លើសាក្សី ឬជនរងគ្រោះធ្វើឲ្យមានការលំបាកដល់ការស៊ើប អង្កេតប្រមូលភស្តុតាង។

-ដោយផ្អែកលើមូលហេតុទាំងអស់នេះ ទើបតំណាងអយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យ ប្តឹងឧទ្ធរណ៍និងដីកាសម្រេចមិនឃុំខ្លួនលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១៨។

សេចក្តីដូចបានជំរាបជូនខាងលើសូមឯកឧត្តម **អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍** មេត្តាជ្រាបជារបាយការណ៍ ។

សូម ឯកឧត្តម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅ បន្ទាយមានជ័យ , ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៨

**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តបន្ទាយមានជ័យ**

លេខ:............................................

## ដីកាកោះឱ្យចូលរួមសវនាការ

**********

យេង ...ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ដែលមានជនជាប់ចោទ:

១-ឈ្មោះ ...ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

២-ឈ្មោះ ...ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

ជាប់ចោទពីបទ **បើកបរបង្កឲ្យគ្រោះថ្នាក់ស្លាប់ដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិ... ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី...ខែ... ឆ្នាំ... បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៨១.៨២** នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

**ហេតុដូច្នេះសម្រេច**

បង្គាប់ឱ្យឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំជាតិខ្មែរ ទីលំនៅបច្ចុប្បន្នរស់នៅភូមិ...ខេត្តបន្ទាយមានជ័យ ឱ្យចូលទៅកាន់សាលាដំបូងខេត្តបន្ទាយមានជ័យ **នៅថ្ងៃទី... ខែ... ឆ្នាំ...វេលាម៉ោង ២:០០** រសៀល ជាកំហិត ដើម្បីឆ្លើយដោះសាពីការចោទប្រកាន់មកលើខ្លួនដូចខាងលើ ។

**ចៅក្រមជំនុំជម្រះ**

- លោក ...ចៅក្រមសាលាដំបូងខេត្ត

**តំណាងអយ្យការ**

- លោក ... ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

- លោក ...ក្រឡាបញ្ជី

**សិទ្ធិរបស់ជនជាប់ចោទមានដូចតទៅ:**

- សិទ្ធិពីការដឹងឮពីលិខិតចោទប្រកាន់ទោស និងដីកាកោះឱ្យចូលរួមសវនាការ
- សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី ឬសំណូមពរផ្សេងៗ

- សិទ្ធិប្ដឹងជិតចិត្តទៅក្រមជំនុំជម្រះ
- សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងពាក់មេធាវីជួយការពារ

បន្ទាយមានជ័យ, ថ្ងៃទី ... ខែ ... ឆ្នាំ ...

**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តបន្ទាយមានជ័យ**

លេខ:...........................................

**********

## ដីកាកោះឱ្យចូលរួមសវនាការ

យើង ...ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ដែលមានជនជាប់ចោទ:

១-ឈ្មោះ ...ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

២-ឈ្មោះ ...ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

ជាប់ចោទពីបទ **បើកបរបង្កឱ្យគ្រោះថ្នាក់ស្លាប់ដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិ... ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី...ខែ... ឆ្នាំ... បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៨១.៨២** នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

**ហេតុដូច្នេះសម្រេច**

បង្គាប់ឱ្យឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំជាតិខ្មែរ ទីលំនៅបច្ចុប្បន្នរស់នៅភូមិ...ខេត្តបន្ទាយមានជ័យ ឱ្យចូលទៅកាន់សាលាដំបូងខេត្តបន្ទាយមានជ័យ **នៅថ្ងៃទី... ខែ... ឆ្នាំ...វេលាម៉ោង** ២ⁿ០០ រសៀល ជាកំហិត ដើម្បីឆ្លើយដោះសាពីការចោទប្រកាន់មកលើខ្លួនដូចខាងលើ ។

**ចៅក្រមជំនុំជម្រះ**

- លោក ...ចៅក្រមសាលាដំបូងខេត្ត

**តំណាងអយ្យការ**

- លោក ... ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

- លោក ...ក្រឡាបញ្ជី

**សិទ្ធិរបស់ជនជាប់ចោទមានដូចតទៅ:**

- សិទ្ធិពីការដឹងឮពីលិខិតចោទប្រកាន់ទោស និងដីកាកោះឱ្យចូលរួមសវនាការ

- សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី ឬសំណូមពរផ្សេងៗ
- សិទ្ធិប្តឹងជិតចិត្តទៅក្រមជំនុំជម្រះ
- សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងពាក់មេធាវីជួយការពារ

បន្ទាយមានជ័យ, ថ្ងៃទី ... ខែ ... ឆ្នាំ ...

**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការ**
អមសាលាដំបូង
ខេត្តបន្ទាយមានជ័យ
លេខ: ____________ អក

## ដីកាឲ្យដំណឹងពីសេចក្តីសម្រេចរបស់តុលាការ

យើង ... ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី... ខែ ... ឆ្នាំ ២០១០ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៖ ... (ត) ចុះថ្ងៃទី... ខែ... ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ។

បានឃើញមាត្រា ៤៨២ និងមាត្រា ៤៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**<u>ជូនដំណឹងមក</u>**

ឈ្មោះ ... ភេទប្រុស ឆ្នាំកំណើត ... (អាយុ ... ឆ្នាំ) សញ្ជាតិ ខ្មែរ មានទីលំនៅ ភូមិ... សង្កាត់... ក្រុង... ខេត្តបន្ទាយមានជ័យ ជាជនជាប់ចោទឲ្យបានជ្រាប ថា៖ រឿងក្តីរបស់លោក ត្រូវបានសាលាដំបូងខេត្តបន្ទាយមានជ័យធ្វើការជំនុំជម្រះ និងសម្រេចសេចក្តីរួចហើយ តាមរយៈសាលក្រម ដូចបានយោងខាងលើ និងភ្ជាប់ជាមួយស្រាប់ ។

អាស្រ័យហេតុនេះសូមលោកជ្រាបបើលោកមិនសុខចិត្តនឹងការសម្រេចសេចក្តីតាមសាលក្រមខាងលើនេះទេលោកមានសិទ្ធិប្តឹងទាស់និង សាលក្រមខាងលើនេះបានក្នុងរយៈពេល **១៥ថ្ងៃ** ដោយគិតចាប់ពីថ្ងៃ បានទទួលដីកាឲ្យដំណឹង នេះតទៅនិងមានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល **០១ខែ** គិតចាប់ពីថ្ងៃផុតកំណត់ នៃការប្តឹងទាស់។

ផ្ញើនភ្ជាប់មកជាមួយនូវសាលក្រមព្រហ្មទណ្ឌលេខ៖ ... (ត) ចុះថ្ងៃទី... ខែ... ឆ្នាំ២០១១ របស់ សាលាដំបូងខេត្តបន្ទាយមានជ័យ ។

បន្ទាយមានជ័យ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤

**ព្រះរាជអាជ្ញារង**

យើង..................................................ជា..................................................................

បានប្រគល់ដីកាឲ្យដំណឹងនេះដល់ឈ្មោះ..........................ទីលំនៅសព្វថ្ងៃភូមិ...............................

ឃុំ/សង្កាត់...............................ស្រុក/ខណ្ឌ.............................ខេត្ត/ក្រុង.............................

នៅថ្ងៃទី..............ខែ....................ឆ្នាំ២០........... រួចហើយ ។

| | |
|---|---|
| **អ្នកទទួល** | **អ្នកប្រគល់** |
| **ហត្ថលេខា ឬ ផ្តិតមេដៃ** | **ហត្ថលេខា** |

**មាត្រា ៣៨២ថ្មី.- រយៈពេលប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

ការប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវតែធ្វើក្នុងរយៈពេល១ (មួយ) ខែ ។

កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលប្រកាសសាលក្រម ។

កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកថាចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឲ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ ។

កាលណាសាលក្រមនោះជាសាលក្រមកំបាំងមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលផុតកំណត់ប្ដឹងទាស់ ។

**មាត្រាពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣

នស/រកម/០៦១៣/០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្ដីគោរពជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ

ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

អង្គ វង្ស វឌ្ឍានា

លេខ: ៥៩៣ស.ណ

សំណៅចម្លងត្រឹមត្រូវតាមច្បាប់ដើម ជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០១៣

អគ្គ[illegible]រាជរដ្ឋាភិបាល

សយ សុខា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការក្រសួងយុត្តិធម៌**

លេខៈ ៣៤ យ.ក.ប្រក/០៧

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៧

# ប្រកាស

## ស្តីពី

## បែបបទ និងទម្រង់ការ នៃការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមការចាំបាច់

## ស ម្រេ ច

**ប្រការ ១ :**

ត្រូវបានទទួលនូវគុណសម្បត្តិ ជាភ្នាក់ងារនគរបាលយុត្តិធម៌ ចំពោះមន្ត្រីនគរបាល កងរាជអាវុធហត្ថ យោធិនដែលចាំបាច់ក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសព្រហ្មទណ្ឌ :

១- នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។

២- ភ្នាក់ងារនគរបាលជាតិផ្សេងទៀត ។

៣- នាយទាហាននៃកងរាជអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ។

៤- យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថ ។

**ប្រការ ២ :**

មុននឹងបំពេញមុខងារ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូង ទៅតាមបែបបទ និងរូបមន្ត ដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ៣ :**

ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

**ប្រការ ៤ :**

ប្រធានសាលាដំបូង និងព្រះរាជអាជ្ញាអមសាលាដំបូងគ្រប់ខេត្ត-ក្រុង និងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៕

អង្គ វង្សវឌ្ឍានៈ

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- តុលាការកំពូល
- មហាអយ្យការអមតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍
- តុលាការ និងអយ្យការសាលាដំបូងខេត្ត-ក្រុង
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

*ឧបសម្ព័ន្ធនៃប្រកាសលេខ ៣៥ កយ.ប្រក / ០៧ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៧*

# នីតិវិធី

## នៃការធ្វើសម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌

១- ក្រឡាបញ្ជី ជាអ្នកចាត់ចែងកម្មវិធី :

- ហៅឈ្មោះអ្នកដែលចូលធ្វើសម្បថម្នាក់ម្តងៗ ចូលក្នុងសាលពិធី
- ប្រកាសបើកពិធីធ្វើសម្បថ ភ្នាក់ងារនគរបាលយុត្តិធម៌
- ប្រកាសសមាសភាព ក្រុមប្រឹក្សា តំណាងអយ្យការ និងក្រឡាបញ្ជី :

☞ តំណាងតុលាការ

- លោក.......................... ប្រធានសាលាដំបូង

☞ តំណាងអយ្យការ

- លោក.......................... ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង

☞ ក្រឡាបញ្ជី

- លោក.......................... ក្រឡាបញ្ជីនៃពិធី

២- ក្រឡាបញ្ជីអានបញ្ជីឈ្មោះអ្នកដែលត្រូវស្បថ

៣- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

៤- តំណាងភ្នាក់ងារនគរបាលយុត្តិធម៌ម្នាក់ អាន **ធម្មានុស្សាន** ( ឱ្យអ្នកស្បថថាតាមខ្លាំងៗ )

៥- ប្រធានក្រុមប្រឹក្សា អាន **សច្ចាប្រណិធាន** ( ឱ្យអ្នកស្បថលើកដៃស្តាំដាក់ត្រឹមត្រចៀក និងថាតាមខ្លាំងៗ )

៦- មតិផ្តាំផ្ញើ របស់តំណាងអយ្យការ

៧- មតិផ្តាំផ្ញើ របស់ប្រធានក្រុមប្រឹក្សា

៨- ចប់កម្មវិធី

*__សំគាល់:__ អ្នកស្បថទាំងអស់ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ និងផ្តិតចំលងកំណត់ហេតុជូនសាមីខ្លួនម្នាក់ៗ*

# ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមសច្ចាប្រណិធានថា នឹងអនុវត្តវិជ្ជាជីវៈ ជាភ្នាក់ងារនគរបាលយុត្តិធម៌របស់ខ្ញុំ ដោយសេចក្តីថ្លៃថ្នូរ ដោយសតិសម្បជញ្ញៈ ដោយសេចក្តីទៀងត្រង់ ដោយមនុស្សធម៌ ដោយស្មារតីឯករាជ្យ និងដោយគោរពរដ្ឋធម្មនុញ្ញ និងច្បាប់ទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ជាដរាបតរៀងទៅ ។

## ប្រារព្ធខាន (សេចក្តីអំពាវនាវ)

បពិត្រអស់ទេពារ័ក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏សក្តិសិទ្ធិ មាន : ព្រះអង្គដង្កើរ ព្រះអង្គក្រពុំឈូក ព្រះអង្គ ស្វេតច្ឆ័ត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះជីវីវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្មែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថ ត្បិតយើងខ្ញុំបានចូលខ្លួនមកសុំធ្វើសម្បថសច្ចាប្រណិធាន ដើម្បីបំពេញតួនាទីជាភ្នាក់ងារនគរបាលយុត្តិធមិនាពេលនេះ ។

បើយើងខ្ញុំប្រព្រឹត្តល្មៀងឃ្លាងឃ្លាតចាកច្បាប់ មិនអនុវត្តត្រឹមត្រូវតាមច្បាប់ ដោយមានចេតនាទុច្ចរិត សូមអស់ទេពារ័ក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិទាំងអស់ បំផ្លាញយើងខ្ញុំឱ្យវិនាសលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង ខ្សែភ្លើងឆក់ រន្ទះបាញ់ ឡានម៉ូតូបុក ខ្លាខាំ ពស់ចឹក លុះអានាគតជាតិឱ្យព្រាត់ប្រាស់ និរាសឪពុកម្តាយ បងប្អូន កូនចៅ ឱ្យក្ររហោមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់ប្រាំរយជាតិ ។

បើយើងខ្ញុំប្រព្រឹត្តល្អទៀងត្រង់ ត្រឹមត្រូវតាមគន្លងច្បាប់ យកចិត្តទុកដាក់ប្រឹងប្រែងអនុវត្តការងារ ដោយស្មោះត្រង់ អស់ពីចិត្តពីថ្លើម សូមអស់ទេពារ័ក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិក្នុងលោកជួយឱ្យយើងខ្ញុំ មានអាយុវែងយឺនយូរ មានសេចក្តីសុខដុមរមនា មានសុខភាពល្អ មានទ្រព្យសម្បត្តិ មាស ប្រាក់ កែវកង ពិទូរ្យសូរ្យកាន្ត សម្បូរហូរហៀរ លុះអនាគតជាតិ បានជួបតែសេចក្តីល្អ មានទ្រព្យស្តុកស្តម្ភ កិត្តិយសថ្លៃថ្នូរ ចម្រុងចម្រើន ថ្កុំថ្កើងរុងរឿង សមដូចសេចក្តីបំណងប៉ងប្រាថ្នា កុំបីអាក់ខានឡើយ ។

# ព្រះរាជក្រម

នស/រកម/០៦១៣/០០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៣ នីតិកាលទី៣ ហើយ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រា មួយ.-**

មាត្រា២៤៧ (ដីកាដំណោះស្រាយ) មាត្រា៣៦៨ (រយៈពេលសម្រាប់ធ្វើបណ្តឹងទាស់) មាត្រា៣៧២ (បណ្តឹងទាស់ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី) និងមាត្រា៣៨២ (រយៈពេលប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី) នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា ២៤៧ថ្មី.- ដីកាដំណោះស្រាយ**

ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនទៅជំនុំជម្រះឬដីកាលើកលែងចោទប្រកាន់ ។

ប្រសិនបើយល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរសម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ ដីកាត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់ ។

ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់នៅក្នុងករណីដូចតទៅ ៖

១- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ។

២- ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ។

៣- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ។

៤- ករណីដែលបណ្តឹងអាជ្ញារលត់ ។

ដីកាដំណោះស្រាយជានិច្ចកាលត្រូវតែមានសំអាងហេតុ ។ ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ ។ ដីកាអាចជាដីកាបញ្ជូនទៅតុលាការជំនុំជម្រះចំពោះអំពើមួយចំនួន និងជាដីកាលើកលែងចោទប្រកាន់ចំពោះអំពើដទៃទៀត ។

ក្នុងករណីដែលសំណុំរឿងស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុច្រើន ចៅក្រមស៊ើបសួរអាចចេញដីកាដំណោះស្រាយចំពោះអង្គហេតុដែលការស៊ើបសួរបានចប់សព្វគ្រប់ និងបន្តការស៊ើបសួរចំពោះអង្គហេតុផ្សេងទៀតបាន។ ចៅក្រមស៊ើបសួរក៏អាចចេញដីកាលើកលែងចោទប្រកាន់ចំពោះជនត្រូវចោទដែលត្រូវបានស៊ើបសួររកឃើញថា មិនមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស ឬការចូលរួមប្រព្រឹត្តបទល្មើស និងធ្វើការស៊ើបសួររកអត្តសញ្ញាណជនល្មើសបន្តទៀតបាន ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

ក្នុងករណីដែលមានការលើកលែងចោទប្រកាន់ដោយមូលហេតុអត្តសញ្ញាណរបស់ជនត្រូវចោទមិនត្រូវបានស្គាល់ ឬក្នុងករណីដែលជនត្រូវចោទទទួលមរណភាព ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌតាមដីកាបញ្ជូនឲ្យសម្រេចរឹបអូសឧបករណ៍ សម្ភារៈ មូលនិធិ ផលទុនឬទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថា ឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស ។ ក្នុងករណីនេះ តុលាការព្រហ្មទណ្ឌត្រូវសម្រេចអំពីការរឹបអូសដោយសាលក្រមក្នុងសវនាការជាសាធារណៈ ដោយមានការចូលរួមពីតំណាងអយ្យការនិងបុគ្គលពាក់ព័ន្ធ ប្រសិនបើមាន ។ សាលក្រមដែលសម្រេចអំពីការរឹបអូសត្រូវបិទផ្សាយនៅទីកន្លែងដែលតុលាការបានចេញសាលក្រម និងផ្សាយជាសាធារណៈតាមសារព័ត៌មានឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ។

បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃវត្ថុដែលជាកម្មវត្ថុនៃការរឹបអូស មានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនោះបានក្នុងរយៈពេល ១ (មួយ) ខែ គិតពីថ្ងៃប្រកាសសាលក្រម ប្រសិនបើបុគ្គលនេះបានចូលរួមនៅក្នុងនីតិវិធីនៃការជំនុំជម្រះរបស់តុលាការ និងក្នុងរយៈពេល២ (ពីរ) ខែ គិតពីថ្ងៃប្រកាសផ្សាយជាសាធារណៈតាមសារព័ត៌មាន ឬមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ប្រសិនបើបុគ្គលនេះមិនបានចូលរួមនៅក្នុងនីតិវិធីតុលាការ ។ បែបបទ និងនីតិវិធីនៃការប្តឹងឧទ្ធរណ៍នេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនេះ ។

## មាត្រា ៣៦៨ថ្មី.- រយៈពេលសម្រាប់ធ្វើបណ្តឹងទាស់

បណ្តឹងទាស់ត្រូវតែធ្វើនៅក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ផ្តើមគិត ៖

- ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឲ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬ
- ពីថ្ងៃដែលពិរុទ្ធជននេះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះ មិនបានប្រគល់ឲ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ ។ ពិរុទ្ធជនត្រូវចាត់ទុកថា បានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម ក្នុងករណីដែលនីតិវិធីនៃការឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាម

បទប្បញ្ញត្តិដែលមានចែងក្នុងគន្ថីទី៧ ( ជីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង ) មាតិកាទី៤ ( ដីកាឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ) នៃក្រមនេះ ។

### មាត្រា ៣៧២ថ្មី.- បណ្តឹងទាស់ដែលធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចប្តឹងទាស់នឹងសាលក្រម ដែលសម្រេចដោយកំបាំងមុខខ្លួនបានដែរ ។ បណ្តឹងទាស់នេះ ត្រូវកំណត់ទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមតែប៉ុណ្ណោះ ។

បណ្តឹងទាស់ត្រូវធ្វើក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ គិតពី ៖

- ថ្ងៃឲ្យដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមបានប្រគល់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ ឬ
- ថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណីបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឲ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវចាត់ទុកថាបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រមក្នុងករណីដែលនីតិវិធីនៃការឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងគន្ថីទី៧ ( ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង) មាតិកាទី៤ (ដីកាឲ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ) នៃក្រមនេះ ។

បណ្តឹងទាស់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឲ្យប្តឹងទាស់ ។

បទប្បញ្ញត្តិនៃមាត្រានេះ ត្រូវយកទៅអនុវត្តលើបុគ្គលដែលតុលាការប្រកាសថា ត្រូវទទួលខុសត្រូវរដ្ឋប្បវេណីផងដែរ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ៣៨២ថ្មី.- រយៈពេលប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

ការប្ដឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវតែធ្វើក្នុងរយៈពេល១ (មួយ) ខែ ។

កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលប្រកាសសាលក្រម ។

កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកថាចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឲ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ ។

កាលណាសាលក្រមនោះជាសាលក្រមកំបាំងមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលផុតកំណត់ប្ដឹងទាស់ ។

**មាត្រាពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣

[illegible]

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្ដម សីហមុនី

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្ដីគោរពជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ហត្ថលេខា

អង្គ វង្ស វឌ្ឍានា

លេខ: ៥៩៣ស.ណ

សំណៅ[illegible]ជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមិថុនា ឆ្នាំ២០១៣

អគ្គ[illegible]រាជរដ្ឋាភិបាល

សយ សុខា